ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Mar-2015, 15:32
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី២៥៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍ *(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង) *(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ាង

លោក ហ្វីលីព រ៉ូជ័រ *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr. Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន *(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោកស្រី ជេត វណ្ណលី

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក សេង លាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក វៀល សន (2-TCW-860) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក រៀល សន** (2-TCW-860)

សួរដោយលោក សេង លាង ផ្ដើមពី ........................................ទំព័រ ៣
សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ........................................ទំព័រ ២២
សួរដោយលោក ឡោ ជុនធី ផ្ដើមពី........................................ទំព័រ ៦៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី វៀល សន ដែលនឹងផ្តើមសួរដេញដោលដោយសហព្រះរាជអាជ្ញាហើយនិងរួមទាំង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរយៈពេល១ថ្ងៃ។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក វៀល សន លោកនិងមេធាវីប្រឹក្សាលោក ឌុច ផារី មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៥:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់

សវនាការនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំព្យាបាលសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ដែលបានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះជាប្រចាំ មិនអាចអង្គុយយូរបាន និងផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៦:៤៧]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញ១ថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនា-ការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងរយៈពេលនៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[០៩:០៧:៣៩]

**លោក សេង លាង៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម ឯកឧត្តមអស់លោក ដែលមានវត្តមាននៅក្នុងសវនាការ នាពេលនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង លាង៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិ។ ថ្ងៃនេះ ខ្ញុំមានសំណួរលើប្រធានបទមួយចំនួន ចង់ចោទសួរទៅលោកសាក្សីដើម្បីឲ្យលោកសាក្សីជួយបំភ្លឺដល់អង្គសវនាការទាំងមូល។ ប្រធានបទទី១ គឺពាក់ព័ន្ធទៅនឹងជីវប្រវត្តិមួយចំនួនរបស់លោក។ ប្រធានបទទី២ គឺទាក់ទងទៅនឹងសហករណ៍។ ប្រធានបទទី៣ គឺពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្តចំពោះព្រះពុទ្ធសាសនា។ ប្រធានបទទី៤ គឺពាក់ព័ន្ធទៅនឹងការងារដែលគេតែងតាំងលោកធ្វើជាអនុប្រធានមន្ទីរពេទ្យនៅស្រុកត្រាំកក់។ បន្ទាប់មកទៀត សហការីអន្តរជាតិរបស់ខ្ញុំ នឹងមានសំណួរនៅលើប្រធានបទមួយចំនួនជាបន្តបន្ទាប់ទៀត។ ជាកិច្ចចាប់ផ្តើមខ្ញុំបានសូមចាប់ផ្តើមនូវសំណួរដូចតទៅ។

លោកសាក្សី នៅក្នុងកំណត់ហេតុនៃកិច្ចសម្ភាសន៍របស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3 -- 319.1.21។ នៅចម្លើយទី៣ លោកបានលើកឡើងថា -- ខ្ញុំសូម -- "ក្រោយរដ្ឋប្រហារសម្តេច សីហនុ រួចហើយ តាម៉ុក បានធ្វើចលនា ដោយក៏សាងកម្លាំង។ នៅពេលនោះខ្ញុំនិងតាម៉ុក នៅភូមិជិតគ្នា ខ្ញុំក៏បានចូលរួមក្នុងចលនានោះតែម្តង" ហើយនៅក្នុងចម្លើយទី៦ សំណួរសួរថា៖ "តើលោកជឿជាក់លើបដិវត្តខ្មែរក្រហមដែរឬទេ?" ចម្លើយឆ្លើយថា "ដំបូង ខ្ញុំជឿ ព្រោះគំនិតរបស់ខ្ញុំ គឺគំនិតរបស់កុម្មុយនីស្ត។ ដូច្នេះ ខ្ញុំចូលចិត្តនិងចូលរួមក្នុងចលនាបដិវត្តតែម្តង"។ ហើយបន្ទាប់មកទៀត នៅក្នុងចម្លើយលេខ២០០នៃកិច្ចសម្ភាសន៍ដដែលនេះ លោកបាននិយាយថា ខ្ញុំសូមដកស្រង់ "ដំបូង ខ្ញុំស្រឡាញ់បដិវត្តន៍ ប៉ុន្តែដល់ឮថាបដិវត្តន៍វប្បធម៌ ខ្ញុំលែងស្រឡាញ់តែម្តង"។

សំណួរចង់សួរថា តើលោកអាចពន្យល់ជូនអង្គសវនាការបានទេ តើមានហេតុអ្វីជាពិសេសដែលនាំឲ្យលោកលែងចូលចិត្តបដិវត្តន៍តទៅទៀត?

[០៩:១១:១៩]

**លោក រៀល សន៖**

**ឆ៖** បាទ បានជាខ្ញុំបាទលែងជឿបដិវត្តន៍តទៅទៀត ព្រោះខ្ញុំបាទឃើញ ខ្ញុំបាទឮថាធ្វើបដិវត្តន៍វប្បធម៌ ហើយបដិវត្តន៍វប្បធម៌នេះ ខ្ញុំបាទបានមើលឯកសារនៅពីក្មេង កាលប្រទេសចិនធ្វើបដិវត្តន៍ ធ្វើបដិវត្តន៍វប្បធម៌ស្លាប់អស់ប្រជាពលរដ្ឋច្រើនណាស់ រាប់ សាមសិបលានប្លាយនាក់។ អ៊ីចឹងបើនិយាយពីប្រទេសកម្ពុជាវិញ ខ្ញុំបើធ្វើបដិវត្តន៍វប្បធម៌ត្រូវស្លាប់ដែរ ព្រោះបានរៀនសូត្របានដឹងចេះ

ដឹងខ្លះ គេកម្ទេចចោល ព្រោះអ្នកចេះដឹង គឺធ្វើបដិវត្តន៍ប្បធម៌ គេត្រូវតែកម្ទេចៗចោល កសាងកម្លាំងថ្មី។ ហើយធាតុពិត ខ្ញុំបានឃើញការចាត់តាំងខ្សែរបស់អង្គការ គឺចាត់តាំងដូចខ្ញុំយល់មែន ព្រោះអ្នកដែលចេះដឹងនៅតាមភូមិឃុំ មិនសូវចាត់តាំងឲ្យធ្វើជាអីទេ ចាត់តាំងតែអ្នកល្ងង់ អត់សូវចេះ អត់សូវដឹង ខ្លះក៏មិនចេះអក្សរផងឲ្យធ្វើប្រធានក្រុម ប្រធានឃុំអីចឹងទៅ។ អាហ្នឹងបានខ្ញុំបាទលែងជឿងលើបដិវត្តវប្បធម៌នេះ ខ្ញុំខ្លាច។ សំណួរហ្នឹងវែង ខ្ញុំអស់យោបល់ ខ្ញុំអស់។

**ស៖** អរគុណលោកសាក្សី។ អ៊ីចឹង តាមដែលអ្វីដែលលោកយល់ បដិវត្តន៍វប្បធម៌ហ្នឹង តើមានន័យឲ្យចំតែម្តង វាយ៉ាងម៉េចដែរ អាចពន្យល់អត្ថន័យម្តងទៀតបានទេ?

**ឆ៖** បើតាមខ្ញុំយល់ថា ធ្វើបដិវត្តន៍វប្បធម៌ហ្នឹង ច្បាស់ជាកម្ទេចចោលអ្នកដែលចេះដឹងពីមុននិយាយរួម អ្នកចេះដឹងពីមុនដែលមិនបានចូលក្នុងជួរបដិវត្តន៍ហ្នឹង គឺកម្ទេចចោលអស់។ ហើយអ្នកដែលមិនគាំទ្ររបស់អង្គការហ្នឹង គឺកម្ទេចចោលតែម្តង ហើបមាត់មិនបានទេ ហើបមាត់កម្ទេចហើយ។

**ស៖** អរគុណលោកសាក្សី។ តាមដែលលោកលើកឡើង គឺលោកបាននិយាយថាភូមិរបស់លោកនៅជិតភូមិ តាម៉ុក ។ តើលោកអាចប្រាប់បានទេ ថាភូមិរបស់ តាម៉ុក ហ្នឹងគេហៅឈ្មោះថា ភូមិអីដែរ? ហើយវាមានចម្ងាយប៉ុន្មានពីភូមិរបស់លោក ទៅភូមិ តាម៉ុក ហ្នឹង?

[០៩:១៤:៥២]

**ឆ៖** បាទ តាម៉ុក គាត់រស់នៅក្នុងភូមិប្រគាប ឃុំត្រពាំងធំខាងត្បូង ហើយខ្ញុំបាទរស់នៅភូមិព្រៃតាឡី ឃុំត្រពាំងធំខាងជើង គឺព្រំប្រទល់ជាប់គ្នា។

**ស៖** តើលោកអាចប្រាប់បានទេថា នៅពេលដែលលោកជួបតាម៉ុកដំបូង តើជួបនៅឆ្នាំណាដែរ? តើគាត់ -- លោកស្គាល់គ្រួសាររបស់ តាម៉ុក ច្បាស់ដែរឬទេ?

**ឆ៖** បាទ ខ្ញុំជួបជាមួយគាត់ តាំងពីឆ្នាំ៧៥ហ្នឹង គឺឆ្នាំ៧៥ហ្នឹងជួបហ្នង គាត់ ឃើញគាត់ដើរមកផ្សារ ហើយជួបជាមួយគាត់។ ហើយគ្រួសារគាត់ ខ្ញុំស្គាល់ច្បាស់ គ្រួសារគាត់ឈ្មោះ យាយខឹម រស់នៅភូមិជិតគ្នា មិនឆ្ងាយពីគ្នា ប្រហែលជាដីអត់ដល់មួយគីឡូម៉ែត្រផង។

**ស៖** តើលោកធ្លាប់មានទំនាក់ទំនងអ្វីជាពិសេសជាមួយនឹងគ្រួសារ តាម៉ុក ដែរទេ មុននឹងជួបតាម៉ុកហ្នឹង?

**ឆ៖** បាទ មិនដែលសោះ។

**ស៖** លោកបានអះអាងថាលោកស្គាល់គ្រួសារតាម៉ុកច្បាស់។ តើលោកស្គាល់តាមរបៀបណា?

**ឆ៖** ស្គាល់តាមរបៀបអ្នកភូមិនៅជិតគ្នា មិនដឹងថាគាត់ធ្វើអីមិនធ្វើអី កាលនោះមិនដឹងទេ ប៉ុន ស្គាល់ ធ្លាប់ទៅព្រៃទៅផ្សេដឹកខស ដឹកអី ជួបគ្នាប៉ុណ្ណឹង។

**ស៖** អរគុណលោកសាក្សី។ ឥឡូវ ខ្ញុំបែរមកកិច្ចសម្ភាសន៍របស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ឯកសារ E3/5511 នៅត្រង់ចម្លើយៗលេខ២ លោកបានលើកឡើងថា៖ ប្រជាជនបាននិយាយថា -- ខ្ញុំសូមដកស្រង់៖ "ប្រជាជនបាននិយាយថា នៅក្នុងឆ្នាំ១៩៥៧ ឬឆ្នាំ១៩៥៨ ខៀវ សំផន បានមកជួប តាម៉ុក"។ ចំណុចនេះ ខ្ញុំចង់ឲ្យលោកសាក្សីជួយបញ្ជាក់ថា តើនៅក្នុងឆ្នាំ១៩៥៧-៥៨ ដែល ខៀវ សំផន មកជួបតាម៉ុក ឬក៏ក្នុងឆ្នាំ១៩៦៧-៦៨ នៅពេលដែល ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ចាកចេញពីភ្នំពេញទៅចូលរួមជាមួយចលនាតស៊ូ?

**ឆ៖** បាទ ខ្ញុំបាទមិនដឹងថាឆ្នាំណាច្បាស់លាស់ទេ ប៉ុន្តែ គ្រាន់តែប្រជាជនទូទាំងភូមិ នៅភូមិប្រគាប និងភូមិខ្ញុំបាទដែលនៅជិតគ្នាហ្នឹង ថាបាន បានដឹងថាលោក ខៀវ សំផន និងតាម៉ុក ទៅជួបគ្នានៅ -- មិនដឹងជួបគ្នានៅកន្លែងណា ប៉ុន្តែបានមកជួបគ្នា។

**ស៖** អរគុណលោកសាក្សី។ តើលោកអាចប្រាប់បានទេថា នរណាគេឲ្យពិតប្រាកដដែលបានប្រាប់លោកថា ខៀវ សំផន បានទៅជួប តាម៉ុក?

**ឆ៖** បាទ មិនពិតប្រាកដទេ ប៉ុន្តែ ប្រជាជននិយាយទាំងអស់តែគ្នា ឮថាតែអ៊ីចឹង ខ្ញុំមិនៗដឹងថាមួយណាពិតប្រាកដទេ។

[០៩:១៩:៥៤]

**ស៖** តើលោកមានដឹងអំពីហេតុផល ឬក៏មូលហេតុអ្វី បានជា ខៀវ សំផន ទៅជួបតាម៉ុកដែរឬទេ?

**ឆ៖** បាទកាលនោះមិនដឹងទេ គឺខ្ញុំក៏អត់ដឹង ប្រជាពលរដ្ឋហ្នឹងក៏អត់មាននរណាដឹងថា ជាៗអ្វីដែរ អត់ដឹងទេ មិនដឹងថា តាម៉ុកហ្នឹងគាត់ធ្វើអី ហើយលោក ខៀវ សំផន ហ្នឹងធ្វើអីក៏អត់ដឹងដែរព្រោះទើបតែចាប់ផ្តើមដំបូង។

**ស៖** អរគុណលោកសាក្សី។ ចំពោះខ្លួនលោកផ្ទាល់ តើលោកមានដែលធ្លាប់ជួប ខៀវ សំផន ដែរឬទេ ទាំងនៅក្នុងស្រុកត្រាំកក់របស់លោក ឬក៏នៅក្នុងខេត្តតាកែវទាំងមូល? ប្រសិនបើជួប តើជួបនៅពេលណា?

**ឆ៖** បាទ បើៗតាមខ្ញុំដឹងថា ខ្ញុំបានជួបម្តង ប៉ុន្តែមិនជួបផ្ទាល់ទេ គឺកាលនោះខ្ញុំបាទនៅតាម

ភូមិនៅធ្វើទំនប់ទឹកខ្ពបត្របែក ហើយកាលនោះប្រពន្ធតាម៉ុក យាយខឹម ហ្នឹង ឃើញគាត់រែកទូលអីរបេញរបុញ ខ្ញុំបាទមានកង់នៅក្បែរកន្លែងធ្វើទំនប់ហ្នឹងក៏ជួយដឹកៗអីវ៉ាន់គាត់ទៅ មាននំអន្សម ហើយគាត់ទូលនំពងទាមួយឡាំងអីចឹង ទៅដល់ៗកន្លែងភូមិចំបក់ពណ្ណរាយហ្នឹង ពីដើមហៅភូមិចំបក់ពណ្ណរាយ ឥឡូវហៅភូមិស្ទឹង ព្រៃឫស្សីច្រើនណាស់ភូមិហ្នឹង សុទ្ធតែព្រៃឫស្សី។ អីចឹងទៅដល់ក្នុងព្រៃឫស្សីហ្នឹង ក៏គាត់ថា អ្នែងនៅហ្នឹងហើយ ដាក់អីវ៉ាន់ហ្នឹង ហើយនោះលោកៗខៀវ សំផន។ ខ្ញុំបានឃើញមួយភ្លែត ហ្នឹង ដឹងខៀវ សំផនៗ បើខ្ញុំអត់ដែលឃើញផង ប៉ុន្តែគាត់ប្រាប់អីចឹង យាយខឹមហ្នឹង យាយខឹម ប្រពន្ធតាម៉ុក។

[០៩:២២:២៣]

**ស៖** អរគុណលោកសាក្សី។ ឥឡូវខ្ញុំឆ្លងទៅប្រធានបទថ្មីមួយទៀតពាក់ព័ន្ធជាមួយនឹងសហ-ករណ៍។ នៅក្នុងកិច្ចសម្ភាសន៍មួយរបស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5511 ត្រង់ចម្លើយលេខ៣។ លោកបាននិយាយថា ខ្ញុំសូមដកស្រង់៖ “បន្ទាប់ពីឆ្នាំ១៩៧៥ សហករណ៍ត្រូវបានបង្កើតឡើង ហើយមានមនុស្សជាច្រើនត្រូវបានស្លាប់នៅពេលនោះ” ហើយបន្ទាប់មកទៀតនៅឃ្លាខាងក្រោមលោកបាននិយាយថា “យើងពុំមានអាហារបរិភោគ និងសម្លៀកបំពាក់គ្រប់គ្រាន់ឡើយ”។ សំណួរសួរថា តើនៅពេលណាពិតប្រាកដដែលសហករណ៍ត្រូវបានបង្កើតឡើងនៅក្នុងឃុំរបស់លោក គឺនៅឃុំត្រពាំងធំខាងជើង?

**ឆ៖** បាទ ខ្ញុំភ្លេចថ្ងៃខែហើយ ប៉ុន្តែដល់សហករណ៍បង្កើតឡើង គឺចាប់បង្កើតសហករណ៍ គឺចាប់ប្រមូលអីវ៉ាន់ ចាន ឆ្នាំង ស្រូវអង្ករអី ប្រមូលយកទៅដាក់នៅកន្លែងសហករណ៍តែម្តង។

**ស៖** អរគុណ លោកសាក្សី។ តើលោកសាក្សីអាចប្រាប់បានទេ ថាការបង្កើតសហរកណ៍នោះបង្កើតឡើងភ្លាមក្រោយពីឆ្នាំ៧៥ ក្រោយពីការបែកឆ្នាំ៧៥ហ្នឹង ឬក៏បង្កើតនៅចុងឆ្នាំ៧៥ហ្នឹង?

[០៩:២៤:២២]

**ឆ៖** បាទ បង្កើតសហករណ៍ បង្កើតនៅចុងឆ្នាំ៧៥។ ហើយបង្កើតសហករណ៍បើតាមនៅក្នុងស្រុក១០៥ហ្នឹង គឺបង្កើតនៅក្នុងឃុំខ្ញុំបាទហ្នឹង គឺមុនគេហ្នង ហើយក៏បានបន្តបន្ទាប់ទៅឃុំផ្សេងៗ។

**ស៖** អរគុណលោកសាក្សី។ ហេតុអ្វីបានជាលោកនិយាយថា មានមនុស្សស្លាប់ច្រើនបន្ទាប់ពីសហករណ៍ត្រូវបានបង្កើតឡើង?

**ឆ៖** ក្រោយពីបង្កើតសហករណ៍ហ្នឹង ចេះតែបាត់មនុស្សក្នុងភូមិ។ យប់ឡើងមានអ្នកមកហៅហើយទៅបាត់ៗ។ ឧទាហរណ៍ដូចជា ពូខ្ញុំ ពូបង្កើតហ្នឹង គាត់រអ៊ូរទាំជាមួយសហករណ៍ច្រើន ថាអីចេះ ថាអីចុះ ស្រាប់តែយប់ឡើងបាត់ខ្លួនអត់ឃើញមកវិញរហូតដល់ឥឡូវហ្នឹង។

**ស៖** អរគុណលោកសាក្សីដែលបានឆ្លើយបំភ្លឺនឹងពូរបស់លោក។ ប៉ុន្តែ ខ្ញុំនឹងមានសំណួរសួរទៅកាន់ពាក់ព័ន្ធនឹងពូរបស់លោកនៅក្នុងពេលបន្តិចទៀតនេះ។ ខ្ញុំនឹងត្រឡប់ទៅសួរវិញ។ ឥឡូវនេះ ខ្ញុំបន្តសំណួរទៅមុខទៀតថា តើសហករណ៍នេះវាប៉ះ -- ការបង្កើតឡើងនូវសហករណ៍នេះវាធ្វើឲ្យប៉ះពាល់អ្វីខ្លះដល់ផ្គត់ផ្គង់ចំណីអាហារឲ្យដល់ប្រជាជនហូបចុក?

[០៩:២៦:២០]

**ឆ៖** បាទ សហករណ៍នេះបង្កើតឡើង កាលដំបូងឡើងបង្កើតសហករណ៍ ខ្ញុំបាទក៏អរដែរថាបានហូបរួមអីចឹងក៏វាស្រួល អ្នកអត់ក៏មកហូបជាមួយអ្នកមាន អីចឹងថាស្រួល។ ប៉ុន្តែធាតុពិត ដល់ក្រោយមក ខ្ញុំឃើញថាបង្កើតសហរណ៍ ឧទាហរណ៍នៅក្នុងគ្រួសារខ្ញុំមួយ មួយគ្រួសារដាំត្រសក់បានពីរស្រែសម្រាប់មួយគ្រួសារ ដល់ធ្វើសហករណ៍ ដាំដំណាំ ដាំបន្លែបង្ការអីហ្នឹង បានតែពីរបីស្រែដែរមួយភូមិ អីចឹងហូបមិនគ្រប់គ្រាន់។ អីចឹងប្រជាពលរដ្ឋបាតុភាព ឡូឡាអីពេញសហករណ៍ កាលមុនដំបូងមិនទាន់សូវខ្លាចអីច្រើន ប្រជាពលរដ្ឋច្រើនតែឡូឡា ចាស់ក្មេងអីហ្នឹង ក៏ធ្វើឲ្យសហករណ៍ហ្នឹងទៅជាមិនល្អទៅវិញ។

**ស៖** អរគុណលោកសាក្សី។ ឥឡូវ ពាក់ព័ន្ធជាមួយនឹងការខ្វះខាតចំណីអាហារវិញម្តង។ លោកបានលើកឡើងយ៉ាងដូច្នេះនៅក្នុងចម្លើយទី៣ នៃកិច្ចសម្ភាសន៍របស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/5511។ អីចឹង សុំដកស្រង់៖ "បើមាននរណាម្នាក់ត្អូញត្អែរពីអាហារហូបមិនគ្រប់គ្រាន់ ហើយមានគេឮ អ្នកនោះត្រូវគេហៅទៅនៅពេលយប់ និងមិនដែលត្រឡប់មកវិញឡើយ"។ សំណួរសួរថា តាមការចងចាំរបស់លោក តើមានមនុស្សណាម្នាក់ត្រូវបានបាត់ខ្លួនបន្ទាប់ពីត្អូញត្អែរអំពីអាហារហូបមិនគ្រប់គ្រាន់នៅក្នុងសហករណ៍ដែរឬទេ?

[០៩:២៨:៣១]

**ឆ៖** បាទ មានប្រជាពលរដ្ឋសឹងទាំងអស់ ប៉ុន្តែគ្រាន់តែមិនសូវចេញមុខ ដូចជាពូខ្ញុំចេញមុខខ្លាំងជាងគេ។ ចោទអីចេះចោទអីចុះថា ធ្វើសហករណ៍មិនល្អអីចឹងទៅ ក៏បាត់ខ្លួនបាត់ទៅ។

**ស៖** បាទ អរគុណ។

**លោក សេង លាង៖**

លោកប្រធានដើម្បីបន្តសំណួរទៅមុខទៀត ខ្ញុំសុំអនុញ្ញាតលោកប្រធាន មេត្តាអនុញ្ញាតឲ្យខ្ញុំផ្តល់ឯកសារមួយ គឺឯកសារ E3/4108 ដែលឯកសារនេះ គឺជារបាយការណ៍ពីឃុំខ្ពបត្របែក។ លោកប្រធានខ្ញុំសុំអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក សេង លាង៖**

លោកសាក្សី ឯកសារនេះគឺជារបាយការណ៍ពីឃុំខ្ពបត្របែក ចុះកាលបរិច្ឆេទថ្ងៃទី៨ ខែឧសភា ឆ្នាំ៧៧ ចុះហត្ថលេខាដោយកម្មាភិបាលម្នាក់ឈ្មោះ ចំ។ លិខិតបានកំណត់អត្តសញ្ញាណនូវអតីតទាហានលន់នល់ ពីរនាក់ ដែលមានម្នាក់ជាកាប៉ូរ៉ាល់ និងម្នាក់ទៀតគឺពាក់ស័ក្តិ៣ ដែលបានធ្វើការរិះគន់បដិវត្តន៍ និងត្អូញត្អែរអំពីការហូបមិនគ្រប់គ្រាន់។ ម្នាក់ក្នុងចំណោមអ្នកទាំងពីរបាននិយាយថា ខ្ញុំសូមដកស្រង់៖ “ធ្វើបដិវត្តន៍សង្គមនិយមស្អី រកតែស្អីស៊ីគ្មាន”។ ម្នាក់ទៀតបានត្អូញត្អែរថា ខ្ញុំសូមដកស្រង់ “ឃុំត្រពាំងធំខាងជើងបានកាប់ជ្រូកស៊ីមិនអស់សេរីតាមចិត្ត សល់ពេញៗតែឃ្លាំង ងើបពីដេកស៊ី ភ្ញាក់ពីដេកដើរលេងឯងឯងវិញខំចង់ងាប់នៅតែអត់ គេសល់ចុកឃ្លាំង”។ សំណួរខ្ញុំចង់សួរថា តើលោកស្គាល់មេដឹកនាំខ្មែរក្រហមម្នាក់មកពីឃុំខ្ពបត្របែក ឈ្មោះ ចំ ដែរឬទេ? តើ ចំ ហ្នឹងមានទំនាក់ទំនងអ្វីជាមួយតាម៉ុក ដែរ?

[០៩:៣១:១៣]

**ឆ៖** បាទ ខ្ញុំបាទស្គាល់ តាចំ។ តាចំ ជាមេឃុំខ្ពបត្របែក ហើយគាត់ជាប្អូនរបស់តាម៉ុក បង្កើត។

**ស៖** អរគុណលោកសាក្សី។ ឥឡូវត្រឡប់មកចម្លើយទី៣ នៃកិច្ចសម្ភាសន៍របស់លោកក្នុងឯកសារ E3/5511 លោកបាននិយាយថា ហើយខ្ញុំសូមដកស្រង់៖ “ពូរបស់ខ្ញុំ ឡុង នាក់ ត្រូវបានចោទប្រកាន់ថាក្បត់អង្គការ គាត់ត្រូវគេហៅ ហើយគាត់ក៏បាត់ខ្លួនទៅ”។ សូមលោកសាក្សីមេត្តាជួយបញ្ជាក់ឲ្យបានច្បាស់ម្តងទៀត អំពីមូលហេតុអ្វីឲ្យពិតប្រាកដ លម្អិតបន្តិចនូវការឃាត់ខ្លួន ពូរបស់លោកនោះ?

**ឆ៖** បាទ ការឃាត់ខ្លួនរបស់ពូខ្ញុំបាទហ្នឹង ដូចខ្ញុំបានជម្រាបខាងលើ គាត់បាតុភាពពីរឿងសហករណ៍ ហើយជាពិសេស គឺគាត់បាតុភាពថា ថ្ងៃក្រោយនឹងក្លាយជាកុម្មុយនីស្ត គាត់មិនចង់ធ្វើជាមនុស្សកុម្មុយនីស្តអីអីចឹង។

**ស៖** អរគុណ។ តើលោកសាក្សីដឹងទេថា នរណាគេជាអ្នកមកហៅគាត់ ហើយអ្នកណាគេជា

អ្នកបញ្ជាមកហៅ លោកអាចដឹងទេ?

**ឆ៖** ខ្ញុំបាទ មិនដឹងទេ ខ្ញុំបាទនៅឆ្ងាយពីគាត់ដែរ ហើយយប់គ្មានអ្នកណាដឹង។ សួរប្រពន្ធកូនអីថាអត់ដឹង គ្រាន់តែដឹងថាមនុស្សមកហៅ ប៉ុន្តែមិនដឹងអ្នកណា ព្រោះយប់។

**ស៖** ចាប់តាំងពីពេលដែលគាត់ គេហៅទៅក្រៅ រហូតមកទល់បច្ចុប្បន្ន តើលោកមានដែរជួបគាត់ដែរឬទេ?

**ឆ៖** បាទ តាំងហៅពីគាត់ទៅបាត់ រហូតទល់សព្វថ្ងៃនេះ គឺអត់ដែលឃើញគាត់ទេ ធ្វើបុណ្យឲ្យគាត់ពីរបីដងទៅហើយ។

[០៩:៣៤:១១]

**ស៖** អរគុណលោកសាក្សី។ តើលោកសាក្សីអាចជួយបញ្ជាក់បានទេថា ពីមុនពេល និងក្នុងអំឡុងពេលរបបគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ តើឪពុករបស់លោកធ្វើអ្វីដែរ?

**ឆ៖** កាលពីមុនរបបនោះ ពុខ្ញុំបាទធ្វើស្រែ ធ្វើតែស្រែរហូតហ្នឹង ធ្វើស្រែចម្ការតិចតួចហ្នឹង។

**ស៖** សូមលោកជួយបញ្ជាក់ផងថា នៅក្នុងអំឡុងពេលរបបខ្មែរក្រហមនោះ គាត់មានតួនាទីអីដែរ ឬក៏ជាប្រជាជនសាមញ្ញធម្មតា?

**ឆ៖** បាទ គាត់ជាប្រជាជនធម្មតា។

**ស៖** អរគុណលោកសាក្សី។ ឥឡូវត្រឡប់មកអំឡុងពេលពីឆ្នាំ៧៥-៧៦ ដែលជាពេលដែលលោកត្រូវបានគេចាត់តាំងឲ្យធ្វើការនៅមន្ទីរពេទ្យត្រាំកក់។ លោកបាននិយាយយ៉ាង -- លោកបាននិយាយយ៉ាងដូច្នេះ នៅក្នុងចម្លើយទី៤ នៃកិច្ចសម្ភាសន៍របស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5511។ ខ្ញុំសូមដកស្រង់៖ "គេមិនឲ្យខ្ញុំនៅជួបជុំគ្នាជាមួយនឹងគ្រួសាររបស់ខ្ញុំទេ។ គេបញ្ជូនខ្ញុំទៅធ្វើការងារនៅអង្គភាពជាង។ កូនរបស់ខ្ញុំត្រូវគេបញ្ជូនទៅកន្លែងផ្សេងដើម្បីឃ្វាលគោ ចំណែកប្រពន្ធរបស់ខ្ញុំរស់នៅក្នុងសហករណ៍។ ខ្ញុំអាចសុំជួបប្រពន្ធកូន -- កូនប្រពន្ធ ប៉ុន្តែមិនអាចធ្វើឡើងញឹកញាប់បានទេ។ អ្នកខ្លះសុំច្បាប់មកលេងគ្រួសារ ប៉ុន្តែគេអត់ឲ្យ ហើយគាត់លួចរត់ទៅជួបគ្រួសារ បើមានគេដឹងអ្នកនោះត្រូវបាត់ខ្លួន"។ សំណួរសួរថា ទាក់ទងនឹងថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ តើនៅពេលណាដែលគ្រួសាររបស់លោកត្រូវគេបំបែក ហើយលែងឲ្យរស់នៅជាមួយប្រពន្ធ និងកូនរបស់លោកតទៅទៀត?

[០៩:៣៧:១៧]

**ឆ៖** បាទ គ្រួសារខ្ញុំបែកគ្នាតាំងពីចាប់បង្កើតសហករណ៍មក ធ្វើសហករណ៍ក៏បែកគ្នារហូត។

**ស៖** អរគុណលោកសាក្សី។ ពាក់ព័ន្ធនឹងបញ្ហានេះ តើមានកម្មាភិបាលខ្មែរក្រហមណាម្នាក់នៅក្នុងឃុំ ឬស្រុករបស់លោក ដែលធ្លាប់ពន្យល់ពីមូលហេតុដែលអង្គការលែងអនុញ្ញាតឱ្យរស់នៅដោយសេរីជាមួយប្រពន្ធនិងកូនរបស់លោក ឬអនុញ្ញាតឱ្យមកលេងពួកគេតាមចិត្តដែលលោកចង់ដែរឬទេ? ធ្លាប់មានគេពន្យល់ទេ?

**ឆ៖** បាទ អត់មានអ្នកណាដែលពន្យល់ខ្ញុំពីរឿងនេះ។

**ស៖** អរគុណលោកសាក្សី។ ពាក់ព័ន្ធជាមួយនឹងសេរីភាពក្នុងការមកជួបជុំប្រពន្ធកូននោះ ដែលលោកបានលើកឡើងថា លោកអាចសុំច្បាប់ជួបប្រពន្ធកូន ប៉ុន្តែមិនអាចធ្វើញឹកញាប់បានទេ ហើយអ្នកខ្លះសុំច្បាប់មកលេងគ្រួសារ ប៉ុន្តែគេអត់ឱ្យ ហើយគេ -- បើគាត់លួចរត់ទៅជួបគ្រួសារ គេ បើមានគេដឹងអ្នកនោះត្រូវបាត់ខ្លួន។ លោកអាចពន្យល់បានទេ ពីអ្វីដែលលោកលើកឡើងនៅទីនេះ?

**ឆ៖** បាទ នេះជាប្រធានអង្គភាពនិយាយប្រាប់។ ប្រជុំនិយាយប្រាប់ថា "បើប្រសិនណាជាអ្នកណាហ៊ានទៅជួបប្រពន្ធកូនមិនសុំច្បាប់ ហើយច្បាប់មិនអនុញ្ញាតនោះ នឹងមិនបានសុខឡើយ នោះនឹងបាត់ខ្លួន។

[០៩:៣៩:៤២]

**ស៖** តើប្រធានអង្គភាពរបស់លោកឈ្មោះអីដែរ?

**ឆ៖** ប្រធានអង្គភាពខ្ញុំបាទឈ្មោះ ម៉ន ស្លាប់បាត់ហើយ។

**ស៖** តើបទបញ្ជានោះគាត់ជាចេញដោយខ្លួនគាត់តែម្តង ឬក៏ជាទូទៅនៅក្នុងសហករណ៍របស់លោក គេមានការតឹងរ៉ឹងចំពោះការសុំច្បាប់អនុញ្ញាតទៅលេខប្រពន្ធកូនយ៉ាងដូច្នេះ?

**ឆ៖** បាទ ធាតុពិត ខ្ញុំអត់ដឹងទេ ប៉ុន្តែពេលប្រជុំជីវភាពអីម្តងៗ គាត់ប្រាប់អ៊ីចឹង គាត់ប្រាប់ថាដូច្នេះ។

**ស៖** ឥឡូវនិយាយពីប្រពន្ធរបស់លោកវិញ តើប្រពន្ធរបស់លោកត្រូវបានគេចាត់តាំងឱ្យទៅរស់នៅសហករណ៍ណាដែរ?

**ឆ៖** ប្រពន្ធខ្ញុំបាទ គេចាត់តាំងឱ្យទៅនៅ រស់នៅក្នុងសហករណ៍ភូមិតាសួន នៅក្នុងឃុំត្រពាំងធំខាងជើងហ្នឹងដែរ។

**ស៖** អរគុណលោកសាក្សី។ នៅពេលដែលលោកជួបប្រពន្ធលោកម្តងៗ តើប្រពន្ធរបស់លោក

ដែលធ្លាប់ប្រាប់លោកទេ អំពីការហូបចុកនៅក្នុងសហករណ៍?

**ឆ៖** បាទ ធ្លាប់ៗប្រាប់ខ្ញុំបាទ ព្រោះគាត់នៅក្នុងសហករណ៍ហ្នឹង គាត់ជួយស្លបងប្អូនដែលនៅក្នុងចង្ក្រានហ្នឹង។ ហើយអីចឹងគាត់ គេប្រាប់ថាគ្មានម្ហូបគ្មានបន្លែតិចតួចអីចឹង ពិបាកអីចឹង គាត់ត្អូញត្អែរ ពីការលំបាកក្នុងការហូបចុក។

**ស៖** តើគាត់ដែលប្រាប់លោកថា ប្រជាជននៅក្នុងសហករណ៍របស់គាត់ហ្នឹងមានអាហារហូបចុកគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** បាទ គាត់ធ្លាប់ប្រាប់ខ្ញុំថា ហូបមិនគ្រប់ទេ បបរហូបមិនគ្រប់គ្រាន់។ សម្លម្ហូបអីហ្នឹងក៏មិនគ្រប់ដែរ ហូបចែកគ្នា ចែកគ្នាហូប មួយចានៗម្នាក់អីចឹងទៅ។

**ស៖** អរគុណលោកសាក្សី។ តើគាត់ដែលធ្លាប់ប្រាប់លោកអំពីការលំបាលចំពោះការងារនៅក្នុងសហករណ៍ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

**លោក វៀល សន៖**

**ឆ៖** គាត់ធ្លាប់ប្រាប់ខ្ញុំបាទថា នៅក្នុងសហករណ៍ហ្នឹពិបាកណាស់ ប៉ុន្តែចេះតែទ្រាំទម្រាំតែស្លាប់។

[០៩:៤៣:២៨]

**សួរដោយលោក សេង លាង៖**

**ស៖** អរគុណលោកសាក្សី។ ឥឡូវខ្ញុំឆ្លងទៅកាន់ប្រធានបទមួយទៀត ពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្តចំពោះព្រះពុទ្ធសាសនា។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ឯកសារលេខ E319.1.21 ត្រង់ចម្លើយ៤៥ ដល់ ៤៨។ លោកបានពិពណ៌នាអំពីពេលចាប់ផ្ដើមនៃរបបខ្មែរក្រហម ដែលលោកបានឃើញព្រះសង្ឃប្រហែល១០០អង្គ ត្រូវបានគេផ្សឹកនៅវត្តអង្គរកា។ ដំបូង តើលោកអាចប្រាប់យើងបានទេ អំពីទីតាំងរបស់វត្តអង្គរកាហ្នឹង តើស្ថិតនៅត្រង់ណាដែរ បើធៀបនឹងភូមិរបស់លោក?

**ឆ៖** បាទ វត្តអង្គរកានៅឆ្ងាយពីភូមិខ្ញុំប្រហែល២គីឡូម៉ែត្រ តាមផ្លូវផ្លូវពីអង្គតាសោមទៅផ្សារអង្គរកាហ្នឹង។ ចម្ងាយពីអង្គតាសោមទៅវត្តអង្គរកាចម្ងាយ ៨គីឡូជាង ជិត៩គីឡូ។

**សៈ** អរគុណលោកសាក្សី។ តើបន្ទាប់ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោកធ្លាប់ទៅកាន់វត្តអង្គរកា ឬក៏ទៅក្បែរនោះញឹកញាប់ដែរឬទេ?

**ផះ** ខ្ញុំមិនបានទៅញឹកញាប់ទេ។

**សៈ** អរគុណលោកសាក្សី។ អ៊ីចឹង សូមលោកមេត្តាប្រាប់តុលាការនូវអ្វីដែលលោកបានឃើញនៅវត្តអង្គរកាពាក់ព័ន្ធជាមួយនឹងព្រឹត្តិការណ៍នៃការផ្សឹកព្រះសង្ឃចំនួន ១០០អង្គផង។

**ផះ** បាទ ខ្ញុំបានឃើញថ្ងៃនោះ ឃើញកូនឡានហ្ស៊ីបមួយដឹកខោអាវខ្មៅទៅវត្តហ្នឹង។ ហើយខ្ញុំបាទ ហ្នឹងនៅ -- លោកនៅហ្នឹងច្រើនប្រហែល ១០០អង្គជាង ហើយយកចង្ហាន់ទៅប្រគេនលោក ឃើញឡានហ្ស៊ីបហ្នឹង ប៉ុន្តែមិនមែន -- អត់មានប្រជាជនច្រើនទេ មានតិចតួចទេដែលយកចង្ហាន់ទៅប្រគេនលោកហ្នឹង។ លោកឆាន់មិនគ្រប់គ្រាន់ទេ មានដាំបាយ ដាំអីនៅក្នុងវត្តហ្នឹងខ្លះ។ ឃើញឡាន កូនឡានហ្ស៊ីបតូចហ្នឹងដឹកខោអាវខ្មៅហ្នឹងមួយកូនឡានទៅដាក់នៅហ្នឹង។ ទៅដាក់ក្នុងវត្តហ្នឹងដើម្បី ថ្ងៃហ្នឹងគឺថ្ងៃផ្សឹកលោក។

[០៩:៤៧:០០]

**សៈ** តើនៅថ្ងៃផ្សឹកហ្នឹង លោកទាំងជាង១០០អង្គត្រូវផ្សឹកទាំងអស់តែម្តង ឬក៏យ៉ាងម៉េចដែរលោកអាចប្រាប់បានទេ?

**ផះ** ខ្ញុំបាទមិនឃើញទេ ព្រោះខ្ញុំបានត្រឡប់មកវិញ។ ប៉ុន្តែក្រែងក្រោយហ្នឹងមក គឺលោកដែលមានទីលំនៅនៅជិតៗហ្នឹងគឺស្លៀកខោអាវខ្មៅទាំងអស់។

**សៈ** អរគុណលោកសាក្សី។ លោកបានលើកឡើងនៅក្នុងចម្លើយលេខ៤៩ នៃកិច្ចសម្ភាសន៍ដដែល។ ខ្ញុំសូមដកស្រង់៖ "ខ្ញុំបានឃើញខ្មែរក្រហមវាយកម្ទេចរូបចម្លាក់ និងវិហារ ហើយនិងយករូបបដិមាតូចចេញពីវត្តបោះចោលទៅក្នុងទឹកនិងកប់ចោល"។ សំណួរសួរថា តើកម្មាភិបាលខ្មែរក្រហមរូបណាដែលលោកឃើញវាយកម្ទេច ឬក៏បានយករូបបដិមាព្រះពុទ្ធទៅបោះចោលនោះ?

**ផះ** បាទ ខ្ញុំបាទមិនដឹង មិនស្គាល់អ្នកដែលធ្វើនោះទេ ប៉ុន្តែច្រើននាក់ បួនដប់ម្ភៃនាក់អ៊ីចឹងទៅអាខ្លះវ៉ៃរូបចម្លាក់នៅជ្រុងវិហារ អាខ្លះសែងព្រះតូចៗហ្នឹងយកទៅបោះក្នុងទឹកទៅ អាខ្លះកាប់រណ្តៅដាក់ព្រះតូចៗជីករណ្តៅនៅមុខកុដិលោកហ្នឹងទម្លាក់កូនព្រះតូចៗក្នុងហ្នឹង ហើយកប់ទៅ។ ខ្ញុំបាទឃើញនេះដោយសារ ខ្ញុំបាទទៅរឿងលោកផ្សឹកហ្នឹង។

[០៩:៤៩:១៦]

**ស៖** អរគុណលោកសាក្សី។ ហើយនៅក្នុងចម្លើយទី៥០ នៃកិច្ចសម្ភាសន៍ដដែលគឺ E319.1.21 លោកបានផ្តល់សក្ខីកម្មដូចតទៅនេះ ខ្ញុំសូមដកស្រង់ "តាអ៊ិច ជាចៅអធិការវត្ត បានតវ៉ាជាមួយនឹងខ្មែរក្រហម ហើយគាត់បានទូងស្គរឲ្យប្រជាជនប្រឆាំងនឹងពួកខ្មែរក្រហម។ តែពេលនោះ ខ្ញុំមាន -- ពុំមានប្រជាជនណាប៊ានមកនោះទេ។ ខ្មែរក្រហមបានវាយគាត់ពីរបីព្រនង់ប៉ុណ្ណោះ"។ សំណួរសុំសួរលោកថា តើរឿងនេះ លោកបានឃើញដោយផ្ទាល់ភ្នែក ឬមួយលោកឮតាមគេប្រាប់ ដែលថាចៅអធិការវត្តអង្គរការូបនេះ ត្រូវបានគេវាយដោយដំបងដោយកម្លាំងរបស់ខ្មែរក្រហម?

**ឆ៖** បាទរឿងវាយលោកចៅអធិការនេះ គឺខ្ញុំមិនឃើញផ្ទាល់ទេទាន គ្រាន់តែឮគេប្រាប់ គឺមុននឹងគេផ្សឹកលោក។ វាយដោយសារលោកទូងស្គរហៅប្រជាពលរដ្ឋ មកប្រឆាំង។

**ស៖** សូមលោកជួយបញ្ជាក់ផង ថាអ្នកណាគេប្រាប់លោកពីរឿងនេះ?

**ប្រធានអង្គជំនុំ៖**

គឺកុំៗអាលទាន់ឆ្លើយតបសាក្សី ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិន។

**លោក រៀល សនៈ**

**ឆ៖** ខ្ញុំបាទមិនៗស្គាល់ទេ ប៉ុន្តែគេគ្រាន់តែប្រាប់ខ្ញុំ។

[០៩:៥១:៣៧]

**សួរដោយលោក សេង លាង៖**

**ស៖** តាមអ្វីដែលលោកលើកឡើងអម្បាញ់មិញ មានន័យថា ថ្ងៃដែលគេវាយព្រះចៅអធិការ និងថ្ងៃដែលគេផ្សឹកព្រះសង្ឃ គឺជាថ្ងៃពីរខុសគ្នាឬយ៉ាងណា?

**លោក រៀល សនៈ**

**ឆ៖** បាទ គឺថ្ងៃតែមួយ។

**ស៖** តើកើតឡើងនៅមុន ឬក៏ក្រោយ ឬក្នុងពេលដំណាលគ្នានៃការផ្សឹកហ្នឹង អាចប្រាប់បានទេ?

**ឆ៖** បាទ គឺនៅពេលផ្សឹកហ្នឹងតែម្តង។

**ស៖** តើលោកស្គាល់ តាអ៊ិច យូរហើយឬ? តើលោកធ្លាប់ទៅបន់ស្រន់នៅវត្តអង្គរកាដែរឬទេពីមុនមក?

**ឆ៖** បាទ ខ្ញុំស្គាល់ តាអ៊ិច ហ្នឹងយូរហើយ ធ្លាប់ទៅធ្វើបុណ្យទៅវត្តហ្នឹង ធ្លាប់ទៅជាញឹកញាប់។

[០៩:៥៣:២៦]

**ស៖** អរគុណលោកសាក្សី។ ឥឡូវ ខ្ញុំឆ្លងទៅប្រធានបទមួយទៀត ពាក់ព័ន្ធជាមួយនឹងតួនាទីរបស់លោកជាអនុប្រធានមន្ទីរពេទ្យស្រុកត្រាំកក់វិញម្ដង។ ខ្ញុំចង់ត្រឡប់ទៅអំឡុងពេលដែលលោកធ្វើការនៅក្នុងមន្ទីរពេទ្យមួយនៅក្នុងស្រុកត្រាំកក់។ នៅក្នុងចម្លើយទី១៤ នៃកិច្ចសម្ភាសន៍របស់លោក ឯកសារ E3/5511 លោកបានលើកឡើងថា គេចាត់ឲ្យលោកទៅធ្វើជាអនុប្រធានពេទ្យនៅក្នុងឆ្នាំ១៩៧៦ ដោយ តាជឹម និង តាគិត ។ សុំសួរលោកថា តាជឹម និង តាគិត ជានរណាដែរ?

**ឆ៖** បាទ តាជឹម និង តាគិត ជាគណៈស្រុក១០៥ ទាំងពីរនាក់ហ្នឹងគឺបងប្អូនបង្កើត។

**ស៖** តើមន្ទីរពេទ្យដែលគេចាត់តាំងឲ្យលោកទៅធ្វើការនោះ គឺជាមន្ទីរពេទ្យស្រុកសម្រាប់ស្រុកត្រាំកក់ទាំងមូលឬយ៉ាងណា?

[០៩:៥៥:០០]

**ឆ៖** បាទ មន្ទីរពេទ្យនោះ គឺជាមន្ទីរពេទ្យស្រុក១០៥ ស្រុកត្រាំកក់ហ្នឹងឯង។

**ស៖** អរគុណលោកសាក្សី។ តើលោកដឹងថា ហេតុអ្វីបានជា តាជឹម និង តាគិត ចាត់តាំងឲ្យលោកទៅធ្វើការនៅទីនោះដែរឬទេ?

**ឆ៖** បាទ បានជាតាជឹម ហើយនិងតាគិត ចាត់តាំងខ្ញុំបាទឲ្យទៅធ្វើនៅកន្លែងនោះ ព្រោះខ្ញុំបាទចេះចាក់ថ្នាំព្យាបាល ចេះឲ្យថ្នាំខ្លះៗនូវជំងឺផ្ដាសាយ គ្រុនរងារអីផ្សេងៗហ្នឹង គាត់ក៏ចាត់តាំងទៅ។

**ស៖** នៅក្នុងឯកសារនៃកិច្ចសម្ភាសន៍របស់លោក គឺឯកសារ E3/5511 ត្រង់សំណួរទី១៤ លោកបាននិយាយថា៖ "ខ្ញុំត្រូវបាន តាជឹម និង តាគិត បញ្ជូនមកធ្វើការនៅមន្ទីរពេទ្យ ដោយសារខ្ញុំអាចព្យាបាលដល់សមាជិកគ្រួសាររបស់ខ្ញុំ"។ តើជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** អរគុណលោកសាក្សី។ តើលោកធ្លាប់ មុនឆ្នាំ១៩៧៦ មុនពេលដែលលោកគេតែងតាំងលោកធ្វើការនៅមន្ទីរពេទ្យហ្នឹង តើលោកធ្លាប់ទទួលការបណ្ដុះបណ្ដាលពីវិជ្ជាពេទ្យដែរឬទេ?

**ឆ៖** បាទ គ្មានទេ។

[០៩:៥៦:២៥]

**ស៖** អរគុណលោកសាក្សី។ ឥឡូវ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់អំពីទីតាំងមន្ទីរពេទ្យម្ដង តើមន្ទីរពេទ្យរបស់លោកហ្នឹងមានទីតាំងស្ថិតនៅកន្លែងណា សូមជួយបញ្ជាក់ពីភូមិឃុំផង? តើមន្ទីរពេទ្យនោះស្ថិតនៅក្នុងវត្ត ឬក៏ស្ថិត ឬនៅជិតវត្តមួយឈ្មោះថា ត្រពាំងគល់ ឬយ៉ាងណា?

**ឆ៖** បាទ មន្ទីរពេទ្យស្រុក១០៥ គឺស្ថិតនៅក្នុងវត្តត្រពាំងគល់ មានលាក់ -- ស្ថិតនៅក្នុងភូមិត្រពាំងស្វាយ ឃុំត្រពាំងធំខាងជើង។

**សៈ** អរគុណលោកសាក្សី។ តើមន្ទីរស្រុកត្រាំកក់ហ្នឹង ជាមួយនឹងមន្ទីរពេទ្យ២២ ឬក៏ហៅថា ម-២២ ហ្នឹងជាមន្ទីរពេទ្យតែមួយ ឬក៏មន្ទីរពេទ្យផ្សេងគ្នា?

**ឆ៖** បាទ មន្ទីរពេទ្យស្រុកត្រាំ -- ស្រុក១០៥ និងមន្ទីរពេទ្យ២២ មិនទំនាក់ទំនងអីគ្នាទេ។ មន្ទីរពេទ្យ២២ គឺជាមន្ទីរពេទ្យយោធារបស់ភូមិភាគ។

**សៈ** តើលោកអាចបញ្ជាក់បានទេថា នៅក្នុងមន្ទីរពេទ្យរបស់លោកមានបុគ្គលិកប៉ុន្មាននាក់ដែរ?

**ឆ៖** មន្ទីរពេទ្យខ្ញុំបាទហ្នឹង កាលហ្នឹងបុគ្គលិកពេទ្យជាង៩០នាក់ ទាំងបុរស ទាំងស្ត្រី ទាំងអ្នកដាំបាយ ទាំងអ្នកដឹកឧសអី ជាង៩០នាក់។

**សៈ** លោកជាអនុប្រធានមន្ទីរពេទ្យ ចុះនរណាគេជាប្រធានមន្ទីរពេទ្យ?

[០៩:៥៩:៤៥]

**ឆ៖** បាទ ប្រធានពេទ្យមន្ទីរពេទ្យស្រុក១០៥ហ្នឹង មានប្រធានច្រើនណាស់ ប៉ុន្តែច្រើនតែនារី។ នៅមុនដំបូងគេគឺ នារីម៉េត។ ហើយផ្លាស់ពី នារីម៉េត មក១នារីយ៉ា ផ្លាស់ពីនារីយ៉ាមក មាននារីនាងចុងក្រោយផុតហ្នឹង ក្រោយហ្នឹងបែកមក បីនាក់។

**សៈ** លោកដឹងពីមូលហេតុអ្វីបានជាគេចាត់តាំងសុទ្ធតែនារីជាប្រធានមន្ទីរពេទ្យនេះដែរ?

**ឆ៖** បាទ បើតាមខ្ញុំដឹងថានារីពេទ្យមកចាត់តាំងឲ្យមកធ្វើជាប្រធាននេះ គឺជាបក្ខជនរបស់បក្សទាំងអស់គ្នាទាំងបីនាក់ហ្នឹងសុទ្ធតែបក្ខជន ប៉ុន្តែមិនមែនមកដំណាលគ្នាទេ គឺមួយ ពីរ បី បួន ប្រាំខែផ្លាស់គ្នា ផ្លាស់មកទៀតបាទ។

**សៈ** តាមអ្វីដែលលោកអះអាង ទាល់តែជាបក្ខជន ទើបអាចធ្វើជាប្រធានមន្ទីរពេទ្យបានឬយ៉ាងណា?

**ឆ៖** បាទ ព្រោះប្រធានមន្ទីរមួយៗ ដល់តែបក្ខជន បានធ្វើប្រធានបាន។

**សៈ** តើប្រធានមន្ទីរពេទ្យហ្នឹងគាត់មានជំនាញ ឬក៏ធ្លាប់ទទួលការបណ្តុះបណ្តាលពីវិជ្ជាពេទ្យដែរឬទេ?

**ឆ៖** បាទ ធាតុពិតទៅនារីទាំងបីនាក់ជាប្រធានខ្ញុំហ្នឹង គឺអត់ចេះសោះហ្មង វិជ្ជាពេទ្យគឺអត់មានចេះសោះ។ នារីម៉េត នោះមិនចេះអក្សរទៀតផង។

**សៈ** អរគុណ លោកសាក្សី។ ឥឡូវខ្ញុំចង់ឲ្យលោកជួយបញ្ជាក់បន្តិចអំពីមន្ទីរពេទ្យកម្រិតតំបន់សម្រាប់តំបន់១៣ និងមន្ទីរពេទ្យសម្រាប់ភូមិភាគនិរតី តើមានដែរឬទេ?

**ឆៈ** បាទ មន្ទីរៗពេទ្យតំបន់មាននៅមន្ទីរពេទ្យត្រពាំងរនាប ឯមន្ទីរពេទ្យភូមិភាគ មាននៅអង្គតាសោម និងនៅសាលាដើមចំបក់។

**សៈ** អរគុណលោកសាក្សី។ តើលោកអាចដឹងដែរឬទេ ថាតើមានសាច់ញាតិឬក៏បងប្អូន តាម៉ុកណាម្នាក់មានតួនាទីនៅមន្ទីរពេទ្យកម្រិតស្រុក កម្រិតតំបន់ ឬក៏ភូមិភាគដែរឬទេ? បើមានសូមលោកជួយបញ្ជាក់លម្អិតបន្តិចផង?

**ឆៈ** បាទ មន្ទីរពេទ្យតំបន់ មន្ទីរពេទ្យស្រុក និងមន្ទីរពេទ្យភូមិភាគ គឺមានមន្ទីរពេទ្យភូមិភាគហ្នឹងមានប្អូនតាម៉ុកស្រីឈ្មោះ យាយគឿន គាត់ធ្វើប្រធានមន្ទីរពេទ្យហ្នឹង។ យាយគឿន ប្អូនតាម៉ុក។

[១០:០៣:៥៧]

**សៈ** តើលោកដឹងរឿងនេះតាមរបៀបណាដែរ?

**ឆៈ** មន្ទីរពេទ្យនេះៗ នៅជិតខ្ញុំនៅជិតផ្សារអង្គតាសោម។ អ៊ីចឹងខ្ញុំបញ្ជូនអ្នកជំងឺខ្ញុំទៅៗពេទ្យតំបន់ក៏បាន ទៅពេទ្យភូមិភាគហ្នឹងក៏បាន បើមានអ្នកជំងឺខ្លាំងជួយសង្គ្រោះអី ខ្ញុំបញ្ជូនទៅបាន។

**សៈ** តើប្អូន តាម៉ុក ហ្នឹងគាត់មានវិជ្ជាពេទ្យ ឬក៏បានទទួលការបណ្តុះបណ្តាលពីវិជ្ជាពេទ្យដែរឬទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលៗទាន់ឆ្លើយតបសាក្សី រង់ចាំក្បាលមេក្រូហ្វូនប្រតិបត្តិការសិន។

**លោក រៀល សនៈ**

**ឆៈ** បាទ បើតាមខ្ញុំដឹងដូចជាមិនសូវចេះវិជ្ជាពេទ្យអីទេ។ គាត់មានបុគ្គលិកគាត់ដែលជាអ្នកបច្ចេកទេសនៅក្នុងហ្នឹងជួយព្យាបាល។

**សួរដោយលោក សេង លាង៖**

**សៈ** អរគុណលោកសាក្សី។ ឥឡូវ ខ្ញុំបែរមកកិច្ចសម្ភាសន៍របស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតគឺនៅក្នុងចម្លើយទី១៤ នៃឯកសារ E3/5511 លោកបានលើកឡើងថា បានទទួលការបណ្តុះបណ្តាលនៅក្រោយពេលដែលលោកត្រូវបានតែងតាំងឲ្យធ្វើការនៅមន្ទីរពេទ្យក្នុងឆ្នាំ១៩៧៦ និងលើកឡើងថា វគ្គបណ្តុះបណ្តាលនោះមានរយៈពេល៣ខែ។ ហើយក៏និយាយទៀតថា លោក

បានបណ្តុះបណ្តាលនៅមន្ទីរពេទ្យតំបន់ និងភូមិភាគដោយគ្រូបណ្តុះបណ្តាលឈ្មោះ សី និងក៏បានលើកឡើងថា លោកបានទទួលការបណ្តុះបណ្តាលខាងកាយវិភាគមនុស្ស។ សំណួរចង់សួរលោកថាតើលោកអាចប្រាប់បានទេថា នៅក្នុងខែណាមួយនៅក្នុងឆ្នាំ១៩៧៦នោះ ដែលលោកបានទទួលការបណ្តុះបណ្តាលរយៈពេល៣ខែនោះ?

[១០:០៦:៣០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញ លោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ចំពោះករណីនេះគឺថា ព្រះរាជអាជ្ញាគួរតែដាក់បញ្ចូលនៅកថាខណ្ឌទី២នៃប្រយោគនេះ គឺនិយាយអំពី៦ខែនៅក្នុងកថាខណ្ឌតែមួយ។ គឺដំបូងគឺ៣ខែចុងក្រោយបន្ទាប់មក៦ខែចុងក្រោយ។ ខ្ញុំមិនយល់ថា ហេតុអ្វីបានជាគាត់អានតែ៣ខែ ដកចោលនូវ៦ខែទៅវិញ។

**លោក សេង លាង៖**

សូមជម្រាបលោកប្រធានថា ខ្ញុំនៅមានសំណួរបន្ថែមទៀតពាក់ព័ន្ធនឹងវគ្គបណ្តុះបណ្តាលរយៈពេល៦ខែ។ ដូច្នេះពេលនេះ ខ្ញុំសួរមួយកំណាត់សិនពាក់ព័ន្ធវគ្គបណ្តុះបណ្តាលរយៈពេល៣ខែ ហើយតទៅក្រោយទៀត ខ្ញុំនឹងសួរបន្ថែមទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សាក្សីឆ្លើយតបនឹងសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញារងជាតិដែលព្រឹកមិញ -- ចុងក្រោយអម្បាញ់មិញនេះ។ លោកចាំសំណួរទេ? បើមិនចាំសំណួរ សហព្រះរាជអាជ្ញារងជាតិតាំងសំណួរអម្បាញ់មិញនេះសាជាថ្មីម្តងទៀត។

**សួរដោយលោក សេង លាង៖**

**ស៖** សំណួរ ខ្ញុំចង់សួរបញ្ជាក់ថា តើលោកអាចប្រាប់បានទេថា នៅក្នុងខែណាមួយក្នុងឆ្នាំ៧៦ ដែលលោកបានទទួលការបណ្តុះបណ្តាលរយៈពេល៣ខែ?

**ឆ៖** បាទ ក្នុងរយៈ៣ខែនោះ ខ្ញុំមិនដឹង ភ្លេចខែភ្លេចឆ្នាំអស់ហើយ ប៉ុន្តែ ទៅទទួលការបណ្តុះបណ្តាលហ្នឹង៣ខែ លើកទី១។

[១០:០៨:១៥]

**ស៖** តើលោកអាចដឹងទេថា តើលោកបញ្ចប់វគ្គបណ្តុះបណ្តាលនៅខែណាដែរ?

**ឆ៖** បាទ មិនដឹងទេ ព្រោះទៅរៀនវគ្គបីខែនុ៎ង មិនបានរៀនចប់ចុងចប់ដើមទេ។ រៀនឈប់ៗ អ៊ីចឹងទៅ បើគិតទៅ៣ខែហ្នឹងរៀនបានតែកន្លះខែ ឬក៏២០ថ្ងៃហ្នឹងក៏ឈប់បាត់ទៅ។ លែងរៀនទៅ។

**ស៖** លោកអាចប្រាប់បានទេថាៗ លោកចាប់ផ្តើមធ្វើការនៅមន្ទីរពេទ្យស្រុកហ្នឹងចាប់ពីថ្ងៃណាមក?

**ឆ៖** ខ្ញុំបាទភ្លេចហើយ ភ្លេចថ្ងៃហើយ ប៉ុន្តែប្រហែលជាឆ្នាំ៧៦ ជិតចូល៧៧ហ្នឹង។

**ស៖** អរគុណលោកសាក្សី។ ខ្ញុំមានសំណួរមួយទៀតពាក់ព័ន្ធជាមួយនឹងការបណ្តុះបណ្តាល។ ដែលលោកបាននិយាយថាលោកបានទទួលការបណ្តុះបណ្តាលខាងកាយវិភាគមនុស្ស តើមានន័យយ៉ាងណាដែរ? ជួយពន្យល់ជូនអង្គសវនាការស្តាប់ផង។

**ឆ៖** បាទ រៀនកាយវិភាគរបស់មនុស្សហ្នឹង គឺរៀនក្នុងតួគ្រោងឆ្អឹងរបស់មនុស្សយើងហ្នឹង មានឆ្អឹង មានពោះវៀន មានថ្លើម មានប្រមាត់ មានអីអ៊ីចេះ ទាំងអស់ ក្នុងខ្លួនមនុស្សហ្នឹងគឺរៀនទាំងអស់ហ្នុង។

**ស៖** លោកបានលើកឡើងមកខាងក្រោយទៀតថា លោកបានទទួលការបណ្តុះបណ្តាលបន្ថែមដែលមានរយៈពេល៦ខែ។ តើវគ្គបណ្តុះបណ្តាលទី២នោះធ្វើនៅកន្លែងណា និងពេលណាដែរ? សូមបញ្ជាក់ផង?

**ឆ៖** ខ្ញុំបាទរៀននៅវគ្គទី២នេះ នៅមន្ទីរពេទ្យតំបន់ សព្វថ្ងៃនៅត្រពាំងរនាប ហៅត្រពាំងរនាប។

**ស៖** ពេលណាដែរសូមជួយបញ្ជាក់ផង?

**ឆ៖** នៅក្នុងឆ្នាំ៧៦-៧៧ ចុង៧៧ហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សី មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:១៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក សេង លាង៖**

អរគុណលោកប្រធាន។

**សួរដោយលោក សេង លាង៖**

**ស៖** ឥឡូវខ្ញុំសូមឆ្លងទៅសំណួរមួយទៀត គឺនៅក្នុងចម្លើយលេខ៨ នៃកិច្ចសម្ភាសន៍របស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5511។ លោកបានលើកឡើងដូច្នេះថា ខ្ញុំសូមដកស្រង់៖ “មានប្រជាជនជាច្រើនធ្លាក់ខ្លួនឈឺ ដោយសារការធ្វើការហួសកម្លាំង និងពុំមានអាហារហូបគ្រប់គ្រាន់។ អ្នកដែលមិនអាចទៅធ្វើការដោយសារតែមានជំងឺ អ្នកនោះត្រូវគេបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ នៅទីនោះ អ្នកជំងឺបានទទួលការព្យាបាលសមស្រប ប៉ុន្តែពុំមានថ្នាំគ្រប់គ្រាន់”។ សំណួរ ចង់ឲ្យលោកសាក្សីជួយបញ្ជាក់មើលថា តើជាទូទៅអ្នកជំងឺដែលត្រូវគេបញ្ជូនទៅមន្ទីរពេទ្យត្រាំកក់របស់លោកនុ៎ង ភាគច្រើនបំផុតគឺមានជំងឺអីដែរ?

**លោក វៀល សន៖**

**ឆ៖** បាទ អ្នកជំងឺដែលបញ្ជូនមកមន្ទីរពេទ្យរបស់ខ្ញុំបាទ គឺភាគច្រើនៗជំងឺហើម រាករូស ហើយនិងគ្រុនចាញ់។

**ស៖** តើលោកអាចប្រាប់បានទេ ថាថ្នាំពេទ្យប្រភេទអ្វីខ្លះដែលមានខ្វះខាតបំផុតនៅក្នុងពេទ្យរបស់លោក?

**ឆ៖** បាទ ថ្នាំ ៗពេទ្យដែលខ្វះខាតក្នុងមន្ទីរពេទ្យ បើពិចារណាទៅ គឺខ្វះសឹងតែទាំងអស់ ប៉ុន្តែវាមិន -- វាមានខ្លះ ប៉ុន្តែវាមិនគ្រប់គ្រាន់។

[១០:៣៥:០០]

**ស៖** លោកអះអាង មានជំងឺជាច្រើនដូចជា ហើម រាករូសអីហ្នឹង តើថ្នាំប្រភេទហ្នឹងគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** បាទ ថ្នាំប្រភេទនោះមិនគ្រប់គ្រាន់ទេ។

**ស៖** ខ្ញុំឆ្លងទៅសំណួរមួយទៀត គឺនៅក្នុងចម្លើយលេខ១៤៧ ដែលក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយសហចៅក្រមស៊ើបអង្កេត គឺឯកសារ E319.1.21 លោកបាន -- គេសួរលោកថា៖ "នៅមន្ទីរពេទ្យរបស់លោកមានជំងឺចូលព្យាបាល និងអ្នកដេកពេទ្យប្រហែលប៉ុន្មាននាក់ក្នុង១ថ្ងៃ?" ហើយលោកឆ្លើយថា៖ "ផ្នែកបុរសមានប្រហែលជាង៣០នាក់ក្នុង១ថ្ងៃ ហើយមានអ្នកខ្លះធ្ងន់ពេកក៏ស្លាប់ទៅ។ ចំណែកផ្នែកនារីវិញ គឺមានជាង១០០នាក់ក្នុង១ថ្ងៃ"។ សំណួរឃើញថា ចំនួនរបស់អ្នកជំងឺស្ត្រីនៅមន្ទីរពេទ្យរបស់លោកគឺមានចំនួនច្រើនជាងបុរស។ មូលហេតុអ្វីដែលបណ្តាលឲ្យស្ត្រីមានជំងឺច្រើនជាងបុរសនៅក្នុងស្រុកត្រាំកក់ហ្នឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមិនមានការជំទាស់ទេ គ្រាន់តែថានៅក្នុងឯកសារជាភាសាអង់គ្លេសគឺសរសេរខុស គឺថាមានសរសេរថា "១៣" មិនមែន១០ ទេ ប៉ុន្តែខ្ញុំគិតថាប្រហែលជាការបកប្រែភាសាប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតប!

**លោក រៀល សន៖**

ម្តងទៀត?

**សួរដោយលោក សេង លាង៖**

**ស៖** សំណួរខ្ញុំសួរថា តើ--

**ប្រធានអង្គជំនុំ៖**

កុំអាល១ទាន់ឆ្លើយតប! ផ្អាកបន្តិចសិន មានបញ្ហារអាក់រអួលផ្នែកខាងម៉ាស៊ីនប្រតិចារឹក។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលពិនិត្យមើលដើម្បីជួសជុលឲ្យដំណើរការឡើងវិញ!

[១០:៣៨:០០]

*(មានបញ្ហាបច្ចេកទេស)*

[១០:៣៨:២២]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញៗបន្តទៀត។ អំមិញដូចជាមិនទាន់ឆ្លើយទេ ហើយតាំងសំណួរចុងក្រោយអម្បាញ់មិញសាជាថ្មីឡើងវិញ ដើម្បីសាក្សីឆ្លើយតប។

**សួរដោយលោក សេង លាង៖**

**ស៖** សំណួររបស់ខ្ញុំសួរថា មូលហេតុអ្វីបានជានៅក្នុងស្រុកត្រាំកក់ហ្នឹងមានអ្នកជំងឺជាស្ត្រីច្រើនជាងបុរស?

**លោក រៀល សន៖**

**ឆ៖** បាទ អ្នកជំងឺស្ត្រីមានច្រើនជាងបុរសនៅក្នុង -- មកមន្ទីរពេទ្យរបស់ស្រុក១០៥ គឺមកអំពីស្ត្រីមានកម្លាំងខ្សោយជាងបុរស ហើយហូបបាយមិនគ្រប់ ហើយធ្វើការអី ធ្វើការពលកម្មវាខ្លាំងពេកម៉្លោះហើយវាមកច្រើន។ ម៉្ងៃៗមកច្រើនណាស់។

**ស៖** ខ្ញុំនៅមានមួយសំណួរទៀត មុននឹងខ្ញុំបញ្ចប់ការសួរដេញដោលរបស់ខ្ញុំ។ សំណួរនេះគឺលោកបានលើកឡើងនៅក្នុងចម្លើយលេខ១៤៧ ដដែលថា មានជំងឺមួយចំនួនដែលត្រូវបញ្ជូនដល់មន្ទីររបស់លោកបានស្លាប់។ ខ្ញុំសូមដកស្រង់ថា៖ "ហើយមានអ្នកខ្លះធ្ងន់ពេកក៏ស្លាប់"។ តើលោកអាចពន្យល់បានទេថា ហេតុអ្វីដែលលោកបានលើកឡើងនេះ អ្វីដែលលោកបានលើកឡើងនេះមានន័យដូចម្តេចដែរ?

**ឆ៖** អ្នកជំងឺដែលធ្ងន់មកពី -- បញ្ជូនមកពីឃុំ គឺជួនកាលអីអ្នកជំងឺហ្នឹងឈឺពីកន្លែងការដ្ឋានមកមកដល់មន្ទីរពេទ្យឃុំខ្លាំងហើយ។ ហើយមន្ទីរពេទ្យឃុំបញ្ជូនមកទៀត ជួនកាលអីមកដល់កណ្តាលផ្លូវក៏ស្លាប់ទៅ ជួនកាលអីមកដល់មន្ទីរពេទ្យខ្ញុំស្លាប់ភ្លាម ហ្នឹងភ្លាមទៅ ក៏សែងសពយកទៅវិញទៅ។

**ស៖** អរគុណលោកសាក្សីដែលបានឆ្លើយសំណួរខ្ញុំជាហូរហែ។

[១០:៤០:៥៧]

**លោក សេង លាង៖**

ហើយលោកប្រធាន ខ្ញុំសូមបញ្ចប់សំណួរនៅពេលនេះ។ ហើយជាបន្តទៀតសហការីរបស់ខ្ញុំគាត់មានសំណួរបន្តទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

**សួរដោយលោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ឌេល លីសាក់។ ខ្ញុំនឹងសួរលោកនៅពេលព្រឹកនេះ ហើយនិងបន្តទៅដល់ពេលរសៀល។

**ស៖** ជាដំបូងខ្ញុំនឹងសួរលោកថាតើមន្ទីរពេទ្យស្រុករាយការណ៍ទៅប្រធាន ឬក៏ទៅមេស្រុកត្រាំកក់ដោយរបៀបណា? ដូច្នេះតើលោកអាចប្រាប់បានដែរឬទេថាតើមន្ទីរពេទ្យរាយការណ៍ទៅគណៈស្រុកត្រាំកក់ដោយរបៀបណា? ថាតើលោកសរសេរជារបាយការណ៍ ឬមួយក៏រាយការណ៍ដោយផ្ទាល់ៗមាត់ទៅគណៈស្រុកត្រាំកក់នោះ?

**ឆ៖** បាទ របៀបរបបរបាយការណ៍នៅមន្ទីរពេទ្យស្រុក១០៥ ខ្ញុំបាទមិនដែលធ្វើរបាយការណ៍នៅលើក្រដាសហើយបញ្ជូនទៅទេ គឺទៅធ្វើរបាយការណ៍ដោយផ្ទាល់មាត់នៅចំពោះមុខលោកប្រធានស្រុក។ មូលហេតុមកពីធ្វើរបាយការណ៍ក្នុងក្រដាសមិនដឹងធ្វើអី បើធ្វើទៅ បើថាអ្នកជំងឺច្រើនក៏អត់មានឃើញថ្នាំ ហើយបើអ្នកជំងឺអត់បាយហូបក៏អត់មានឃើញម្ហូបឃើញអង្ករអីមក នៅតែប៉ុណ្ណឹងដដែល។ អីចឹងរាយការណ៍មាត់ទទេ ហើយក៏ចេះតែសុខរហូតមកអត់មានបញ្ហា។

[១០:៤៣:១៣]

**ស៖** សូមអរគុណ។ តើលោកចូលរួមការប្រជុំដើម្បីរាយការណ៍ទៅគណៈស្រុកហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ ទៅធ្វើរបាយការណ៍ឲ្យគណៈស្រុក ជួនកាលទៅតែម្នាក់ឯងពេលដាច់ខែ ឬក៏មិនដាច់ខែក៏ទៅបានដែរ ឲ្យតែទៅរាយការណ៍ជូនគាត់។ ប៉ុន្តែបានតែរាយការណ៍ទៅ ប៉ុន្តែវាអត់មានផលប្រយោជន៍អីត្រឡប់មកវិញ គឺអត់។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើលោកជួបជាមួយនឹងគណៈស្រុកនៅកន្លែងណាដែរ? ហើយតើការប្រជុំហ្នឹងនិយាយអំពីអ្វីដែរ? សូមអរគុណ។

**ឆ៖** ខ្ញុំបាទ ជួបគណៈស្រុកនៅហ្នឹងមន្ទីរស្រុក។

**ស៖** តើលោកអាចប្រាប់បានទេថា តើមន្ទីរស្រុកហ្នឹងមានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** បាទ មន្ទីរស្រុកមានទីតាំងនៅផ្សារអង្គរកា គឺនៅផ្ទះ នៅក្នុងផ្ទះចិននៅក្នុងផ្សារហ្នឹង។

ក្រៅពីហ្នឹងអត់មានមនុស្សទេ អត់មានប្រជាជននៅទេ មានតែផ្សារទទេ មានតែផ្ទះទទេ។

**ស៖** ប្រមាណនាទីមុនលោកបាននិយាយថា លោកបានទៅរាយការណ៍ទៅប្រធានស្រុកដោយខ្លួនឯងផ្ទាល់។ ថាតើវាមានមូលហេតុអ្វីដែលប្រធានពេទ្យដែលលោកនិយាយថាមានស្រីបីនាក់ហ្នឹង ថាហេតុអ្វីបានជាស្ត្រីទាំងបីរូបហ្នឹងមិនចូលរួមនៅក្នុងកិច្ចប្រជុំហ្នឹង?

**ឆ៖** បាទ បើពីការធ្វើរបាយការណ៍ គឺបើនិយាយពីអ្នកជំងឺ អាហ្នឹងគឺខ្ញុំបាទទៅធ្វើរបាយការណ៍ តែបើការងារបក្ស អាហ្នឹងគឺបីនាក់ហ្នឹងជាអ្នកទៅ ទៅជួបជាមួយគណៈស្រុក។

[១០:៤៦:១៤]

**លោក ឌេល លីសាក់៖**

នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី E3/5511-- លោកប្រធាន នៅពេលនេះខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីផ្តល់ដល់សាក្សី ហើយនិងមេធាវីនូវកំណត់ហេតុស្តាប់ចម្លើយជាមួយសហចៅក្រមស៊ើបអង្កេត គឺ E3/5511 ហើយនិងឯកសារមួយទៀត គឺ E319.1.21។ ហើយខ្ញុំក៏សូមអនុញ្ញាតផ្តល់ឯកសាររបស់មជ្ឈមណ្ឌលឯកសារចំនួនពីរទៅសាក្សី គឺឯកសារ D។ គឺ D313/1.2.409 និង D313/1.2.410។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានដើម្បីផ្តល់នូវឯកសារទាំងបួននេះជូនទៅសាក្សី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១០:៤៧:៣៣]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំសូមផ្តល់ឯកសារនេះជូនទៅលោក ដើម្បីឲ្យលោកអាចពិនិត្យមើលបាន។ ឥឡូវនេះ ខ្ញុំនឹងយោងទៅលើចម្លើយទី១៥ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយទី១ របស់លោក គឺ E3/5511 នៅក្នុងចម្លើយទី១៥ លោកនិយាយអំពីការប្រជុំត្រីមាស "ខ្ញុំត្រូវបានគណៈស្រុកចោទសួរថាហេតុអ្វីបានជាមានករណីមានជំងឺរាក និងហើមច្រើន?"។ តើលោកអាចប្រាប់បានឬទេថា តើលោកប្រាប់គណៈស្រុកយ៉ាងដូចម្តេចនៅពេលដែលគេសួរលោកថា ហេតុអ្វីបានជាមានករណីមានជំងឺរាក និងហើមច្រើននៅក្នុងមន្ទីរពេទ្យនោះ?

**លោក រៀល សន៖**

**ផ៖** បាទ នៅៗពេលដែលខ្ញុំនិយាយប្រាប់គាត់ថា មានជំងឺរាក និងហើមច្រើននៅក្នុងមន្ទីរពេទ្យបណ្ដាលមកពីប្រជាពលរដ្ឋហ្នឹងខ្វះជីវជាតិ ខ្វះអាហារហូបគ្រប់គ្រាន់បានជាហើម ហើយបានជារាក។

**ស៖** ហើយលោកនិយាយថា គាត់ គឺថា -- ថាតើលោករាយការណ៍ទៅគណៈស្រុកទាំងមូលតែម្ដង ឬមួយក៏រាយការណ៍តែទៅប្រធានគណៈស្រុកតែមួយរូបទេ?

**ផ៖** បាទ រាយការណ៍ទៅតែប្រធានគណៈស្រុកមួយរូបទេ។

[១០:៤៩:២០]

**ស៖** តើប្រធានគណៈស្រុក ឆ្លើយតបយ៉ាងដូចម្ដេចនៅពេលដែលលោកនិយាយថា ប្រជាជនឈឺច្រើនដោយសារគ្មានអាហារ គ្មានអីហូបហ្នឹង។ តើគាត់ឆ្លើយមកលោកយ៉ាងដូចម្ដេចវិញ?

**ផ៖** គណៈស្រុកគាត់ឆ្លើយមកខ្ញុំថា ខ្ញុំវាយប្រហារសហករណ៍ មើលងាយសហករណ៍។

**ស៖** ថាតើលោកមានសួរទៅដល់ ឬក៏ស្នើដល់គណៈស្រុកឲ្យផ្ដល់អាហារបន្ថែមមកសហករណ៍ ឬក៏ផ្ដល់អាហារបន្ថែមមកមន្ទីរពេទ្យដែរឬទេ? ហើយប្រសិនបើលោកបានសួរ តើខាងគណៈស្រុកហ្នឹងគេឆ្លើយតបដោយរបៀបណា?

**ផ៖** បាទនៅពេលនោះ ខ្ញុំបាទមិនហ៊ានស្នើទេ ព្រោះស្នើញឹកញាប់ហើយ មិនដែលបាន។

**ស៖** នៅក្នុងចម្លើយបន្ទាប់របស់លោក គឺនៅក្នុងឯកសារ E3/5511 នៅសំណួរចម្លើយទី១៦ លោកបាននិយាយអំពីហេតុផលដែលថា គេផ្ដល់អង្ករ គឺការផ្ដល់អង្ករពីស្រុកមកលោក ខ្ញុំសូមដកស្រង់ "ខ្ញុំត្រូវបានទទួលការអនុញ្ញាតឲ្យយកអង្ករ៥០កំប៉ុង សម្រាប់អ្នកជំងឺ២៥០នាក់។ អង្ករបួនកំប៉ុងមានទម្ងន់ស្មើ១គីឡូក្រាម"។ សូមបញ្ចប់ការដកស្រង់។

តើលោកអាចប្រាប់បានទេ ថាតើនេះជារបបប្រចាំថ្ងៃ ឬមួយក៏ជារបបយ៉ាងដូចម្ដេចដែរ ដែលថាគេឲ្យអង្ករ៥០កំប៉ុង សម្រាប់អ្នកជំងឺ២៥០នាក់នោះ?

**ផ៖** បាទនេះជារបបប្រចាំថ្ងៃ។

**ស៖** ថាតើរបបហ្នឹង របបអង្ករហ្នឹងគឺគេឲ្យដូចគ្នារហូតរៀងរាល់ថ្ងៃក្នុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ឬមួយក៏យ៉ាងម៉េចដែរ?

[១០:៥១:៤៩]

**ផ៖** ខ្ញុំបាទមិនដឹងទេនៅកន្លែងផ្សេង ប៉ុន្តែនេះគឺខ្ញុំនិយាយតែនៅក្នុងកន្លែងខ្ញុំបាទ។

**ស៖** តើលោកចាំទេថា ការប្រជុំហ្នឹងធ្វើឡើងនៅឆ្នាំណា? ហើយតើប្រធានគណៈស្រុកហ្នឹងជាអ្នកណាដែរ នៅពេលដែល -- គឺនៅពេលដែលរាយការណ៍អំពីបញ្ហាកង្វះជីវជាតិ ហើយគេចោទប្រកាន់ថាលោកវាយប្រហារទៅលើសហករណ៍ ទៅលើអីនោះ។ តើវាកើតឡើងនៅពេលណាដែរ?

**ឆ៖** បាទខ្ញុំបាទភ្លេចឆ្នាំ ភ្លេចខែ ភ្លេចថ្ងៃហើយ ប៉ុន្តែគណៈ -- កាលនុ៎ង មានគណៈស្រុក មានតាចាយ, តាជឹម។ ជាពិសេស តាចាយ គាត់ថាខ្ញុំវាយប្រហារសហករណ៍គាត់ គេបង្កើតសហករណ៍ខ្ញុំវាយប្រហារ។

**ស៖** ឥឡូវនេះយើងពិភាក្សាអំពីគណៈស្រុក។ ដូច្នេះខ្ញុំចង់ដឹងថាតើអ្នកដែលបន្តតំណែងបន្តមកទៀតហ្នឹង គឺអ្នកបន្តតំណែងស្រុកត្រាំកក់ហ្នឹង គឺជានរណានៅក្នុងរបបខ្មែរក្រហមហ្នឹង? នៅក្នុងកិច្ច-សម្ភាសន៍របស់លោក គឺ E319.1.21 នៅចម្លើយ២១៣ លោកបានៗលើកឡើងពីស្ត្រីម្នាក់ឈ្មោះ ហំ -- ឈ្មោះ ខុម ដែលជាកូនស្រីរបស់ តាម៉ុក ហើយនិងជាប្រពន្ធរបស់ តាមុត គឺជាលេខស្រុក១០៥ ប៉ុន្តែនៅក្នុងពាក្យរបស់លោកគឺលោកនិយាយថា ខុម ហ្នឹងឆ្កួត។ ដូច្នេះ សូមលោកជម្រាបតុលាការបន្តិចមើល៍ថាតើយាយ ខុម ហ្នឹងគាត់ធ្វើ -- ថាតើយាយខុម ហ្នឹងជាមនុស្សបែបណាដែរ នៅពេលដែលគាត់ធ្វើជាប្រធានស្រុក ហើយតើមានអ្វីកើតឡើងចំពោះ យាយខុម នោះ?

[១០:៥៤:១៣]

**ឆ៖** បាទកាលនុង យាយខុម គាត់ជាគណៈស្រុក – លេខាស្រុក ប៉ុន្តែគាត់ៗឆ្កួត អត់ដឹងអីផងចេះតែនិយាយ ចេះតែថា ឃើញខ្ញុំអី ជួនកាលប្រើខ្ញុំឲ្យកាប់គ្រលុក ជីកគល់ស្វាយធំៗ ប៉ុនៗហ្នឹងអីចឹងទៅ។ ហើយខ្ញុំចេះតែខ្លាច ចេះតែធ្វើតាមគាត់។ គាត់ឆ្កួត។

**ស៖** តើលោកដឹងថាមានអីកើតឡើងចំពោះគាត់ក្រោយពេលដែលគាត់ឆ្កួតហ្នឹង?

**ឆ៖** ក្រោយពីគាត់ឆ្កួតមកហ្នឹង ខ្ញុំអត់ដឹងទេ ព្រោះគាត់នៅ -- ទៅនៅកំពង់សោមបាត់។ ខ្ញុំអត់ដឹង។

**ស៖** នៅក្នុងសំណួរ E3/5511 សំណួរទី១៣ លោកបាននិយាយអំពីមនុស្សដូចតទៅនេះ ដែលថាជាគណៈស្រុក។ ខ្ញុំសូមដកស្រង់៖ គឺមានឈ្មោះ តាចាយ តាគិត តាជឹម ហើយនិងតាសាន។ ហើយលោកបានបញ្ជាក់ថា តាគិត និង តាជឹម គឺជាបងប្អូនបង្កើត។ ហើយនៅក្នុងៗកំណត់ហេតុស្តាប់ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺ D313/1.2.409, អង់គ្លេសមានលេខ 00729041, ខ្មែរមានលេខ 00418824 និងបារាំងមានលេខ 00808621។ លោកបានបញ្ជាក់ថា ខ្ញុំសូមដកស្រង់៖ “សំណួរ៖

តើគណ:ៗស្រុកអីដែរ? ចម្លើយ៖ គឺតាគិត ដែលជាអ្នកបន្តវេនពី តាជឹម។ តាគិត គឺឡើងបន្តដោយ តាសាន ដែលជាប្អូនថ្លៃប្រុសរបស់តាម៉ុក"។ សូមបញ្ចប់ការដកស្រង់។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថា តាឈឹម គឺជា -- តាជឹម គឺជាប្រធានស្រុកត្រាំកក់ក្រោយ យាយខុម?

**ឆ៖** បាទ ធាតុពិត តាជឹម គាត់ប្រធានស្រុកត្រាំកក់ តាំងពីមុនយាយខុម ដល់គាត់ផ្លាស់ទៅចម្ការកៅស៊ូទៅ បានយាយខុមឡើងតាមក្រោយ។

[១០:៥៧:៣០]

**ស៖** ខ្ញុំនឹងលើកយកបញ្ហានេះមកពិភាក្សានៅពេលបន្តិចទៀតនេះ។ ក្រោយពេលដែល តាជឹម ហើយនិង យាយខុម តើតាមដែលលោកចាំ អ្នកណាដែលធ្វើការជាលេខាស្រុកបន្តទៀត គឺក្រៅពីតាគិត តាជឹម ហើយនិង យាយខុម នោះ?

**ឆ៖** បាទ ចុងក្រោយផុត មុននឹងបញ្ចប់របបនោះ គឺតាសាន ប្អូនថ្លៃតាម៉ុកហ្នឹងធ្វើលេខាស្រុកចុងក្រោយបំផុត – តាសាន។

**ស៖** ហើយលោកបានបញ្ជាក់ថា តាចាយ គឺជាលេខាស្រុក -- ពេលដែល -- តើលោកអាចបញ្ជាក់ទេថាគាត់ធ្វើជាប្រធានស្រុក ឬក៏លេខាស្រុកហ្នឹងនៅពេលណាដែរ? ថាតើអ្នកណាជាលេខាស្រុកមុន ហើយនិងក្រោយ តាចាយ នោះ?

**ឆ៖** ក្រោយៗតាចាយ មានតាគិត ហើយនិង តាជឹម។ ហើយបានដល់ក្រោយមក បានយាយខុម ហើយក្រោយមកទៀត បានតាសាន ប្អូនថ្លៃតាម៉ុកហ្នឹង។

**ស៖** លោកសាក្សី ឥឡូវនេះ ខ្ញុំនឹងជួយឲ្យលោកនឹកឃើញបន្តិចអំពីពេលវេលា ដែល តាជឹម ហើយនិង តាគិត ធ្វើជាលេខាស្រុក។ នៅក្នុងកិច្ចសម្ភាសន៍ E3/19 គឺកិច្ចសម្ភាសន៍ស្ដាប់ចម្លើយសាក្សី E3 -- E400, ខ្មែរមានលេខ 00373459, អង់គ្លេសមានលេខ 00379171 និងបារាំងមានលេខ 0042 6179។ ហើយខ្ញុំគិតថានេះគឺជាការសម្ភាសន៍របស់ តាឈឹម។ តាឈឹម បាននិយាយថាគាត់បានចាកចេញពីស្រុកត្រាំកក់ ហើយទៅកំពង់ចាមទៅចម្ការកៅស៊ូនៅខែកុម្ភៈ ឆ្នាំ៧៧ ហើយបន្ទាប់មកទៀតគាត់បាន -- គឺ បងគិត បានជំនួសតួនាទីជាលេខាស្រុករបស់គាត់។ ថាតើលោកចាំអំពីចំណុចទាំងអស់នេះទេ ដែលថា ជឹម គឺជាលេខាស្រុកក្រោយ យាយខុម, ហើយ ជឹម បន្តមកទៀតដោយបងគិត ដែល តាគិត ដែលជាបងប្អូនរបស់គាត់នោះ?

**ឆ៖** បាទ ខ្ញុំបាទចាំបាន។

**សះ** តើ តាគិត គឺជាមនុស្សដែលលោកស្គាល់ច្បាស់ដែរឬទេ?

**ផះ** បាទ តាគិត គឺជាមនុស្សដែលខ្ញុំស្គាល់ច្បាស់ជាងគេ។

[១១:០១:២០]

**សះ** ឥឡូវនេះ ខ្ញុំនឹងសួរអំពីមនុស្សផ្សេងទៀតដែលលោកបាននិយាយនៅក្នុងកិច្ចសម្ភាសន៍របស់លោកនៅក្នុងកំណត់ហេតុស្តាប់ចម្លើយគឺ D313/1.2.409, ខ្មែរមានលេខ 00418876, អង់គ្លេសមានលេខ 00729094, និងបារាំងមានលេខ 00808678។ លោកបាននិយាយអំពីកម្មាភិបាលពីរឈ្មោះ តាគារ ដែលត្រូវបានចាប់ខ្លួន។ តើលោកអាចប្រាប់បានទេថា តាគារ ហ្នឹងមានតួនាទីអ្វីនៅក្នុងស្រុកត្រាំកក់?

**ផះ** កាលពីដំបូងមុនបង្អស់ដែលចាប់ផ្តើមគឺ តាគារ នេះគាត់ជាលេខាស្រុកត្រាំកក់មុនដំបូង។ ប៉ុន្តែខ្ញុំបានជួបគាត់មិនដឹងបានប៉ុន្មានខែផងខ្ញុំភ្លេចហើយ ហើយក៏ដល់ឆ្នាំដែរក៏មិនដឹង ហើយគាត់ក៏បានបាត់ទៅ មិនដឹងទៅណាបាត់ទៅ។

**សះ** លោកបាននិយាយថាគេចាប់ខ្លួនគាត់ ថាតើលោកដឹងថាគេចាប់ខ្លួន តាគារ ហ្នឹងលោកដឹងដោយរបៀបណា?

**ផះ** ខ្ញុំបាទៗគ្រាន់តែដឹងថាពេលដែលរត់ចេញទៅ ពេលនោះ តាគិត គាត់ឈឺ ហើយគាត់នៅសម្រាន្តនៅផ្ទះមួយ ខ្ញុំនៅហ្នឹងដែរ ឃើញគាត់ជិះអាកូនកង់តូចៗទៅ ហើយគាត់និយាយប្រាប់ តាគិត ព្រោះមានតែ តាគិត ហើយខ្ញុំ ហើយនិងគាត់ទេបីនាក់នៅផ្ទះប្រជាពលរដ្ឋ ប្រាប់ថាគាត់ទៅដេកនៅហ្នឹង "ថាខ្ញុំនឹងលាបងទៅហើយ មិនដឹងទៅឯណាទេ ប្រហែលជាបាត់ហើយ" អ៊ីចឹងហើយក៏បាត់រហូតតាំងពីថ្ងៃហ្នឹងមករហូតទល់ឥឡូវហ្នឹងមក ខ្ញុំអត់ដឹង។

[១១:០៣:៤៦]

**សះ** ឥឡូវនេះយើងមានមនុស្សពីរនាក់ទៀតដែលខ្ញុំចង់សួរលោកនៅក្នុងចម្លើយទី១៣ នៃកំណត់ហេតុស្តាប់ចម្លើយសាក្សីគឺ E3/5511។ លោកបាននិយាយអំពីបុគ្គលម្នាក់ឈ្មោះ ដន ដែលមានតួនាទីជាអនុប្រធាន ឬក៏ប្រធានៗមន្ទីរស្រុក ហើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ ឌី.ស៊ី.ខេម គឺ D313/1.2.9-- ខ្មែរមានលេខ 004888, អង់គ្លេសមានលេខ 00729095 ដល់96 និងបារាំងមានលេខ 00808678។ លោកបាននិយាយអំពីមនុស្សម្នាក់ទៀតឈ្មោះ ភី គឺអ្នកដែល -- គឺមនុស្សដែលមានជើងបាក់ ហើយបន្តធ្វើជាប្រធានមន្ទីរស្រុកបន្ទាប់ពី -- មុន ដន។ ដូច្នេះខ្ញុំចង់សួរលោកថាតើ ភី ហើយនិង

ដន មានតួនាទីនិងការទទួលខុសត្រូវអ្វីខ្លះក្នុងនាមជាប្រធានមន្ទីរស្រុក ហើយថាតើមុខងាររបស់គេក្នុងនាមជាប្រធានមន្ទីរស្រុកហ្នឹងគឺខុសពីមនុស្សដូចជាឈ្មោះ ជឹម, គិត ហ្នឹង ខុសគ្នាដោយរបៀបណា?

**ឆៈ** បាទ ប្រធាន --ឈ្មោះ ភី និងឈ្មោះ ដន នេះនៅជាប្រធានមន្ទីរស្រុកនេះគឺគាត់គ្រាន់តែនៅចាំទទួលអីវ៉ាន់ដែលបញ្ជូនមកពីលើ មកពីតំបន់មក មានថ្នាំពេទ្យ មាន-- ឲ្យតែនេះគាត់គឺនៅកន្លែងពាណិជ្ជកម្ម នៅមន្ទីរស្រុកហ្នឹងដូចជាកន្លែងពាណិជ្ជកម្មស្រុកមួយអ៊ីចឹងដែរ។ បានអីពីតំបន់មក គាត់នៅចាំទទួលហ្នឹង ហើយចែកចាយទៅតាមឃុំ។

**សៈ** ហើយលោកបានបញ្ជាក់នៅក្នុងកំណត់ហេតុរបស់មជ្ឈមណ្ឌលឯកសារដដែល ដែលថា ភី គឺជាមនុស្សដែលកាចសាហាវ។ តើលោកមានន័យយ៉ាងដូចម្ដេចនៅពេលដែលថាគាត់ជាមនុស្សដែលកាចសាហាវ? ហើយហេតុអ្វីបានជាលោកថាគាត់ជាមនុស្សកាចសាហាវ?

[១១:០៦:៣៦]

**ឆៈ** បានជាខ្ញុំបាទថា ភី ជាមនុស្សកាចសាហាវ ខ្ញុំចាស់ជាងគាត់ ហើយគាត់នៅក្មេងបាក់ជើងពីក១ ប៉ុន្តែមកសម្លុតខ្ញុំដូចកូនក្មេងអ៊ីចឹង។ គាត់កាចណាស់ – ភី ហ្នឹងកាចណាស់ ប៉ុន្តែស្លាប់បាត់ហើយ។

**សៈ** នៅក្នុងឯកសារមួយទៀតគឺកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារគឺ D313/1.2.409 ខ្មែរមានលេខ 00418815, អង់គ្លេសមានលេខ 00729031, បារាំងមានលេខ 00808611។ លោកបានផ្ដល់នូវចម្លើយដូចតទៅនេះ អំពីពេលមួយដែលលោកពិភាក្សាអំពីលទ្ធភាពនៃការបង្កើនការផលិតឱសថ ហើយខ្ញុំសុំដកស្រង់អ្វីដែលលោកបាននិយាយ៖ "ខ្ញុំក៏ចង់ឲ្យបង្កើនការផលិត ប៉ុន្តែខ្ញុំត្រូវការវត្ថុធាតុដើម។ នៅពេលដែលខ្ញុំលើកយកបញ្ហានេះ ពួកគេនិយាយថាវាមិនអាចទៅរួចទេ។ ការលើកនូវបញ្ហានេះ ខ្ញុំធ្វើការវិនិច្ឆ័យដោយខ្លួនឯង។ ខ្ញុំវាយតម្លៃថាតើ ប្រសិនបើយើងមានអនុធន ហើយនិង --គឺថាគេចាត់ទុកខ្ញុំទៅជាអនុធន ឬក៏ជាបញ្ញាជនជាជាងកម្មករ"។ ថាតើអ្នកណាដែលគេរិះគន់លោកថាលោកជាអនុធន ឬក៏បញ្ញាជននៅពេលដែលលោកលើកឡើងអំពីគំនិតនៃការបង្កើនផលិតឱសថហ្នឹង។ អ្នកណាជាអ្នករិះគន់លោក?

**ឆៈ** បាទ នៅពេលនោះគឺ លេខាស្រុកហ្នឹងគឺ តាចាយហ្នង គាត់ថា គាត់វាយតម្លៃខ្ញុំថាអនុធនអី បញ្ញាជនអ៊ីចឹងទៅ គាត់ថា។ គឺតាចាយ។

[១១:០៩:០០]

**សៈ** ថាតើនេះគឺជាកិច្ចប្រជុំដដែលដែលគេរិះគន់ថាលោកធ្វើការវាយប្រហារទៅលើសហករណ៍

ដែលលោកនិយាយអំពីបញ្ហាខ្វះអាហារ ឬមួយក៏វាជាកិច្ចប្រជុំពីរផ្សេងដាច់ពីគ្នា?

**ឆ៖** ជាបញ្ហាពីរដាច់ពីគ្នា។

**ស៖** ហើយនៅក្នុងកិច្ចសម្ភាសន៍ដដែលនេះ គឺខ្មែរមានលេខ 00418817, អង់គ្លេសមានលេខ 00729033 និងបារាំងមានលេខ 00808613។ លោកបានផ្តល់នូវចម្លើយដូចតទៅនេះ “សំណួរ៖ តើអ្នកជំងឺស្លាប់នៅមន្ទីរមណ្ឌលនេះដែរឬទេ? ចម្លើយ៖ ដំបូងគឺមានតែមនុស្សពីរបីនាក់ប៉ុណ្ណោះដែលស្លាប់ម្តងម្កាល ប៉ុន្តែក្រោយមកទៀត គឺចំនួនស្លាប់បានកើនឡើងយ៉ាងខ្លាំង ដោយសារតែការមិនយកចិត្តទុកដាក់ និងកង្វះចំណីអាហារ។ ហើយបន្តមកទៀត និយាយដោយទូទៅ កង្វះអាហារ និងការមិនបានយកចិត្តទុកដាក់បាននាំឲ្យមានការស្លាប់ប្រាំនាក់ក្នុង១ថ្ងៃ នៅក្នុងរយៈពេលចុងក្រោយ”។ ថាតើលោកអាចប្រាប់បានទេថាហេតុអ្វីបានចំនួនមនុស្សដែលស្លាប់ដោយសារតែការខ្វះអាហារហ្នឹង កើនឡើងយ៉ាងខ្ពស់នៅក្នុងផ្នែក ឬក៏នៅក្នុងរយៈពេលចុងក្រោយនៃរបបខ្មែរក្រហមនោះ?

[១១:១០:៣៥]

**ឆ៖** កាលនោះ នៅដល់ពេលចុងក្រោយ គឺរឹតតែអត់ខ្លាំង ប្រជាពលរដ្ឋហ្នឹងអត់មានអីហូបហ្មង។ អ៊ីចឹងជំងឺហើម ជំងឺរាករូសហ្នឹងរឹតតែមានច្រើនឡើង។

**ស៖** ខ្ញុំដឹងថាលោកជាវេជ្ជបណ្ឌិត ហើយគេផ្តល់ការបណ្តុះបណ្តាលលោកក្នុងនាមជាពេទ្យ។ ដូច្នេះក្នុងនាមលោកជាពេទ្យ ថាតើនៅពេលដែលលោកឃើញអ្នកជំងឺស្លាប់ដោយសារខ្វះអាហារហ្នឹង តើលោកអាចពន្យល់បានថា ហេតុអ្វីបានជាមនុស្ស ឬក៏អ្នកជំងឺទាំងអស់ហ្នឹងស្លាប់ដោយសារបញ្ហាកង្វះជីវជាតិ?

**ឆ៖** បាទ បានជាខ្ញុំថាខ្វះជីវជាតិ ព្រោះមនុស្សយើងទាំងអស់គ្នាត្រូវការហូបចុកច្រើនគ្រប់មុខគ្រប់គ្រាន់។ ដល់ហូបអត់គ្រប់ វាកើតទៅជាជំងឺរាក ហើម – ហើមគឺខ្លាំងជាងគេ ហើមចេញទឹកពេញខ្លួន មកពីខ្វះខាតអាហារវាមិនគ្រប់គ្រាន់។

**ស៖** ថាតើភាគច្រើននៃអ្នកជំងឺដែលស្លាប់ដោយសារកង្វះជីវជាតិហ្នឹង គឺជាប្រជាជន១៧មេសា ឬក៏ជាអ្នកមូលដ្ឋាន?

**ឆ៖** បាទ ទាំងពីរ។ ប្រជាជនមូលដ្ឋានក៏ស្លាប់ ប្រជាជនថ្មីហ្នឹងក៏ស្លាប់ ដូចគ្នា។

**ស៖** បន្ទាប់ពីលេខាស្រុករិះគន់លោក ថាលោកវាយប្រហារទៅលើសហករណ៍ និងជាអនុធនជាបញ្ញាជន ថាតើលោកមានលើកយកបញ្ហាកង្វះជីវជាតិ និងកង្វះឱសថទៅប្រាប់ខាងគណៈស្រុកតទៅ

ទៀតទេ ឬមួយក៏លោកមិនប្រាប់ទេ?

**ផ៖** បាទ លែងប៉ានហើយ ខ្លាច – ខ្លាចណាស់ពេលនោះ។

[១១:១៣:៤១]

**ស៖** ឥឡូវនេះ ខ្ញុំនឹងលើកយកប្រធានបទថ្មី ទាក់ទងទៅនឹងការបោសសម្អាតខ្មាំង។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាមួយសហចៅក្រមស៊ើបអង្កេត លោកបាននិយាយថា លោកមានវត្តមាននៅក្នុងកិច្ចប្រជុំស្រុកត្រាំកក់ ដែលនៅពេលនោះគេឲ្យលោកនិយាយអំពីក្រុម ឬក៏ដែលគេបង្ហាញអំពីក្រុម ឬក៏ប្រភេទនៃមនុស្សដែលត្រូវបោសសំអាត។ គឺនៅក្នុងឯកសារ E319.1.21 នៅចម្លើយ៤០ដល់៤៣ លោកបានរៀបរាប់ថា គណៈស្រុកហ្នឹងរៀបរាប់អំពីប្រភេទមនុស្សដែលត្រូវបោសសម្អាត។ ខ្ញុំសូមរៀបរាប់ដូចតទៅ៖ "អ្នករាជការចាប់ពីជំទប់ទី១ នឹងត្រូវយកទៅសម្លាប់។ ចំពោះប៉ូលិសនិងទាហាន គឺចាប់ពីអ្នកដែលពាក់នាយចំណង់ នឹងត្រូវយកទៅសម្លាប់ចោល"។ ហើយបន្តមកសំណួរបន្ទាប់ "សំណួរ៖ អ៊ីចឹងមានន័យថាតើក្រៅពីមនុស្សខាងលើមានក្រុមមនុស្សណាផ្សេងទៀតដែរឬទេ? ឆ្លើយ៖ គឺមានប្រជាជនដែលចេះតែដើរនិយាយមិនល្អ ប្រឆាំងនឹងខ្មែរក្រហម ហើយនិងត្រូវគេវាយការណ៍ ហើយនិងត្រូវយកទៅសម្លាប់ចោល។ សំណួរ៖ នៅក្នុងចំណោមប្រជាជនដែលជាអ្នកប្រឆាំង តើគេបានបញ្ជាក់ថាជាអ្នកសក្តិភូមិ ចិន សេ.អ៊ី.អា កាហ្សេបេ ខ្មែរក្រោម ចាម ឬក៏អ្នកកាន់ព្រះពុទ្ធសាសនាដែរឬទេ? ឆ្លើយ៖ ខ្ញុំបានឮថា អ្នកដែលមកពីខ្មែរកម្ពុជាក្រោមត្រូវបានចោទប្រកាន់ថា ជាកា.ហ្សេ.បេ និង គិញយួន។ នៅក្នុងកិច្ចប្រជុំនោះ ក៏បានលើកឡើងថា ត្រូវសម្លាប់ខ្មែរក្រហមទាំងអស់នោះផងដែរ"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់បញ្ជាក់ជាមួយលោកឲ្យបានច្បាស់ថាតើមានតែការប្រជុំតែមួយ ដែលគេបង្គាប់ឲ្យមានការបញ្ជាបែបនេះ ឬមួយក៏វាមានការប្រជុំជាច្រើនដែលគេពិភាក្សាអំពីបញ្ហាបោសសម្អាតនេះ?

[១១:១៦:០៧]

**ផ៖** បាទ គឺការពិភាក្សាអំពីការបោសសម្អាតនេះ គឺខ្ញុំដឹងតែកន្លែងខ្ញុំប្រជុំហ្នឹងទេ គឺកន្លែងផ្សេងខ្ញុំអត់ដឹងទេ ព្រោះអត់ដែលទៅចូលរួម។ ដឹងតែនៅកន្លែងដែលខ្ញុំប្រជុំហ្នឹង។

**ស៖** ចាតើការប្រជុំហ្នឹង គេធ្វើនៅកន្លែងណាដែរ?

**ផ៖** បាទ ប្រជុំកាលនោះ ប្រជុំនៅមានចង្ក្រានបាយមួយ នៅផ្សារអង្គរកាហ្នឹង។ ឥឡូវធ្វើទៅជាវិទ្យាល័យទៅហើយ។ ប្រជុំនៅកន្លែងហ្នឹង នៅកន្លែងចង្ក្រានបាយហ្នឹង។

**សៈ** តើកម្មាភិបាលស្រុកប៉ុន្មាននាក់ដែលមកចូលរួមក្នុងកិច្ចប្រជុំនោះ? ថាតើមានមេឃុំមកចូលរួមដែរឬទេ?

**ឆៈ** បាទ អង្កាល់នោះ ខ្ញុំភ្លេចហើយ ប៉ុន្តែមានឃុំជិតៗហ្នឹងមកចូលរួម ព្រោះអីមានបងប្អូនមកពីភ្នំពេញអីច្រើន មកពីតាកែវ ដែលជម្លៀសមកហ្នឹងច្រើន។ អីចឹងគេប្រជុំនៅកន្លែងហ្នឹង គឺមានឃុំត្រពាំងធំខាងជើង ខាងត្បូង ជាងទងអីតែប៉ុណ្ណឹង។ តែពីរបីឃុំទេ ខ្ញុំភ្លេច មិនដឹងអ្នកណាមកខ្លះ។

**សៈ** នៅក្នុងកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតទី១ គឺ E3/5511 នៅចម្លើយទី៩ លោកបានបញ្ជាក់ដូចតទៅនេះ៖ "ប្រធានស្រុក ប្រធានឃុំ ប្រធានភូមិ ត្រូវបានគេអញ្ជើញទៅចូលរួមនៅក្នុងសន្និសីទ។ អ្នកចូលរួមអង្គប្រជុំត្រូវបានគេប្រាប់ថាតើប្រជាជនប្រភេទណាខ្លះដែលត្រូវកម្ទេច។ (ហើយបន្តមកបន្តិច) សន្និសីទនេះមានការចូលរួមដោយគណៈស្រុក មានការកម្ទេចតាមផែនការ។ ប្រជាជនដែលគេកំណត់ថាត្រូវកម្ទេចនោះ នៅផ្នែកយោធាដែលមានតំណែងចាប់ពីអាក់ស៊ីដង់ឡើងទៅ។ ចំពោះអ្នកធ្វើការនៅក្នុងផ្នែករដ្ឋបាលគឺចាប់ពីជំទប់ទី១ ឡើងទៅ"។ ដូច្នេះ ខ្ញុំចង់បញ្ជាក់ទៅលើចំណុចមួយនៅក្នុងកិច្ចសម្ភាសន៍មួយទៀតជាមួយសហចៅក្រមស៊ើបអង្កេត លោកនិយាយថា អ្នកដែលត្រូវបោសសម្អាតទាហាន គឺចាប់ពីកាប៉ូរ៉ាល់ឡើងទៅ គឺមិនមែនជាឋានៈអាក់ស៊ីដង់នោះទេ។ ដូច្នេះ នៅពេលដែលយើងមើលការបកប្រែជាភាសាបារាំងវិញ គឺឋានៈជាយោធា គឺរៀបរាប់ដូចគ្នានៅក្នុងសម្ភាសន៍ទាំងពីរ គឺអាក់ស៊ីដង់។ ហើយនៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាលោកក៏បានបញ្ជាក់ផងដែរអំពីឋានៈដែលត្រូវសម្លាប់ គឺអ្នកដែលមានឋានៈចាប់ពីអាក់ស៊ីដង់ឡើងទៅ។ ដូច្នេះ តើលោកអាចបញ្ជាក់បានដែរឬទេ? គឺឯកសារ D1.9.1.2, ខ្មែរមាន 00418851, អង់គ្លេស 007790 និងបារាំងមានលេខ 00808649។ ដូច្នេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើលោកចង់មានន័យយ៉ាងម៉េចដែលថាជាឋានៈផ្សេងៗហ្នឹង។ ដូច្នេះខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យបានច្បាស់នៅក្នុងពាក្យជាភាសាខ្មែរទាក់ទងទៅនឹងឋានៈ ឬក៏ទាក់ទងទៅនឹងស័ក្តិរបស់ទាហានដែលត្រូវគេបោសសម្អាតនោះ?

**ឆៈ** បាទ កាលនោះ ប្រជុំហើយ គាត់ប្រាប់តែម្តងថា "ឲ្យបោសសម្អាតឲ្យអស់ បើទាហានគិតតាំងចាប់តាំងពីពាក់អាក់ស៊ីឡង់ឡើងទៅ ហើយបើផ្នែករដ្ឋបាលគិតពីជំទប់លេខ១ឡើងទៅ គឺបោស-សម្អាតឲ្យស្អាតតែម្តង"។

**សៈ** ថាតើអ្នកណាជាអ្នកតំណាងស្រុកដែលមកផ្តល់ការបញ្ជា ឬក៏ការណែនាំបែបនេះនៅក្នុងកិច្ចប្រជុំពេលនោះ?

**ឆ៖** កាលនោះ មានតាចាយ តែម្នាក់ទេ ប៉ុន្តែមានឃុំពីរបីចូលរួមដែរ។ តែតាចាយ ម្នាក់គាត់ទេ។

[១១:២១:៤៣]

**ស៖** លោកបានផ្តល់សក្ខីកម្មថាមេឃុំមានវត្តមាននៅក្នុងកិច្ចប្រជុំ គឺនៅក្នុងកិច្ចប្រជុំដែលគណៈស្រុកបានផ្តល់ការណែនាំអំពីទាហានលន់នល់ និងមន្ត្រីរដ្ឋការដែលត្រូវបោសសម្អាត ហើយក៏មានរបាយការណ៍មួយចំនួនពីឃុំដែលបង្ហាញអំពីការចាប់ខ្លួនកងទ័ព និងមន្ត្រីរដ្ឋការរបបលន់នល់។ ឥឡូវនេះខ្ញុំសូមបង្ហាញនូវរបាយការណ៍មួយចំនួន។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារជូនទៅដល់សាក្សីគឺ E3/2048, E3/2435 និង E3/4103 និង E3/2917។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារទាំងអស់នេះជូនទៅសាក្សី ហើយខ្ញុំនឹងពិភាក្សាពីឯកសារមួយៗ ហើយខ្ញុំសូមអនុញ្ញាតលោកប្រធានផងដែរ ដើម្បីបង្ហាញនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១១:២៣:១៣]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំបានប្រគល់ឯកសារមួយចំនួន ដូច្នេះខ្ញុំនឹងពិភាក្សាជាមួយលោកមួយឯកសារម្តងៗ។ ទី១ គឺ E3/2048, ខ្មែរមានលេខ 00079089, អង់គ្លេសមានលេខ 00276562 ដល់ 63, និងបារាំងមានលេខ 00611659។ នេះគឺជារបាយការណ៍ពីស្រុកត្រាំកក់ គឺរបាយការណ៍ជូនស្រុកត្រាំកក់ពីជាងទង ដែលចុះឈ្មោះដោយ -- ចុះហត្ថលេខាដោយ មួន ចុះថ្ងៃទី៣០ ខែមេសា ៧៧។ ហើយវាបានបញ្ជាក់ដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ បន្ទាប់ -- "ក្រោយពីបានទទួលការណែនាំជាបន្តបន្ទាប់ពីអង្គការក្នុងការប្រុងប្រយ័ត្នខ្មាំង បូកបោសសម្អាត ពួកទាហានខ្មាំងដែលមានបណ្តាលស័ក្តិក្នុងនោះបានតាមដានពីនិត្យ និងឃើញមានឈ្មោះដូចខាងក្រោម"។ សូមបញ្ចប់ការដកស្រង់។

តើលោកចាំទេថា ឈ្មោះគណៈស្រុកមកពីឃុំជាងទងឈ្មោះ ហឿន នោះដែរឬទេ? -- ឈ្មោះ មឿន ដែរឬទេ?

**លោក រៀល សន៖**

**ឆ៖** បាទ មិនមែនឈ្មោះ មឿន ទេ ឈ្មោះ ហឿន (នារី) – ហឿន។

**ស៖** ហើយរបាយការណ៍បន្តនៅក្នុងឯកសារដែលខ្ញុំបង្ហាញជូនលោកគឺ E3/2048 នៅទំព័រខ្មែរ មានលេខ 00079091, អង់គ្លេសមានលេខ 00276564, បារាំងមានលេខ 00611661។ នេះគឺជារបាយការណ៍មកពីឃុំតាភេម ចុះហត្ថលេខាដោយឈ្មោះ គិត ដែលបានបញ្ជូននៅថ្ងៃ ក្បែរនឹងថ្ងៃ -- ឯកសារមុនគឺថ្ងៃ២៨ មេសា ៧៧។ ហើយក្នុងរបាយការណ៍នេះបាននិយាយអំពីធ្វើការពិនិត្យ និងបោសសម្អាតខ្មាំងដែលមានបណ្ដាស័ក្តិក្រោយពីបានទទួលនូវមតិណែនាំរបស់បក្ស”។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់សួរលោកថាតើមានកម្មាភិបាលនៅក្នុងស្រុកផ្សេងមួយទៀត ឈ្មោះ គិត ដែរឬទេ ដែលជាអ្នកតំណាងឲ្យប្រធានឃុំតាភេម គឺ -- តាភីម។ តើជា គិត តែមួយ? ឈ្មោះ គិត តែមួយ -- ឈ្មោះ ឃិត ហ្នឹង គឺដូចឈ្មោះ គិត ដែលជាគណៈលេខាស្រុកដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលស្គាល់ឈ្មោះហ្នឹងផង។ ឈ្មោះ ឃិត ហ្នឹងអត់ដែលស្គាល់។

[១១:២៦:៤៩]

**ស៖** ហើយឯកសារបន្ទាប់គឺ E3/2435 គឺជារបាយការណ៍ពីឃុំអង្គតាសោម ផ្ញើជូនអង្គការស្រុក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ៧៧។ ឯកសារនោះគឺបានបញ្ជាក់ថា ខ្ញុំសូមដកស្រង់៖ “អ្នកមានបណ្ដាស័ក្តិ២ ឬ១ យើងខ្ញុំទាក់ទង មិត្តយន យោធាស្រុកយកល្ងាចនេះហើយ” ហើយខ្ញុំគិតថាឯកសារនេះ គឺមាននៅក្នុងទំព័រទី២នៃរបាយការណ៍។ ដូច្នេះខ្ញុំចង់សួរលោកថា តើលោកស្គាល់ មិត្តយន ដែលជាយោធានោះដែរឬទេ?

**ឆ៖** បាទ មិនស្គាល់ទេ អត់ស្គាល់។ ឈ្មោះ យន ហ្នឹងអត់ស្គាល់។

**ស៖** ហើយខ្ញុំមានឯកសារពីរទៀត គឺមកពីឃុំពពេល។ ទី១ គឺឯកសារ E3/4103, ខ្មែរមានលេខ 00143476 គឺនៅខាងស្ដាំដៃនៃទំព័រ។ អង់គ្លេសមានលេខ 00322133, បារាំងមានលេខ 00612838។ ឯកសារនេះចុះថ្ងៃទី១១ ខែមេសា មកពីកម្មាភិបាលនៃឃុំពពេលឈ្មោះ ឈន ដែលរាយ-ការណ៍ទៅស្រុក។ ខ្ញុំសូមដកស្រង់ “សម្រាប់អ្នកដែលមានឋានៈ យើងនឹងបញ្ជូនទៅលោកម្ដងមួយៗ” សូមបញ្ចប់ការដកស្រង់។ ហើយមួយខែក្រោយមកទៀត នៅក្នុងខែឧសភា ៧៧ នៅក្នុងឯកសារបន្ទាប់ គឺ E3/2917 គឺឃុំដដែលហ្នឹងរាយការណ៍ទៅស្រុក គឺថាមានគ្រួសារយោធា១០៦នាក់ ក្នុងនោះមានចំនួន៣៩៣នាក់ ត្រូវបានកម្ទេចដោយអង្គការ ឬក៏ស្លាប់។ ហើយឃុំកំពុងតែតាមដានមើលគ្រួសារបន្ថែម ដើម្បីរកឲ្យឃើញថាតើពួកគេហ្នឹងមាននៅសល់អ្នកដែលជាយោធាដែរឬក៏អត់? ដូច្នេះ ជាដំបូងខ្ញុំចង់សួរថាតើលោកស្គាល់កម្មាភិបាលមកពីឃុំពពេល ឈ្មោះ ជន ដែរឬទេ?

[១១:៣០:៥៨]

**ផះ** បាទ ខ្ញុំបាទអត់ស្គាល់ទេឃុំពេល ឆ្ងាយណាស់អត់ស្គាល់ មិនស្គាល់ឈ្មោះមេឃុំ ប៉ុន្តែស្គាល់ឈ្មោះឃុំ មេឃុំអត់ស្គាល់។

**សះ** លោកបាននិយាយអំពីស្ត្រីម្នាក់ឈ្មោះ បឿន ដែលជាប្រធាន ដែលជាមេឃុំជាងទង។ ថាតើ បឿន -- ថាតើគាត់ហ្នឹងជាប្តីរបស់ យាយបឿន ដែរឬទេ? -- មែនឬទេ?

**ផះ** បាទ ប្តីយាយបឿន ឈ្មោះៗ ជន ដែរ ប៉ុន្តែមិនដឹងនៅរស់ ឬក៏ស្លាប់បាត់ហើយ ខ្ញុំអត់ដឹង។

**សះ** តើលោកចាំទេថា យាយបឿន មានវត្តមាននៅក្នុងកិច្ចប្រជុំដែលគណៈស្រុកគេបានបង្គាប់អំពីការបោសសម្អាតទាហាន និងមន្ត្រីរដ្ឋការលន់ នល់ នោះដែរឬទេ?

**ផះ** បាទ អត់មានវត្តមានគាត់ទេ នៅពេលនោះ គ្មាន។

**សះ** ឯកសារទាំងអស់ដែលខ្ញុំបានបង្ហាញពីឃុំចំនួនបួននៅស្រុកត្រាំកក់នោះ គឺជាឯកសារដែលធ្វើឡើងនៅក្នុងខែតែមួយ គឺក្នុងខែឧសភា ដល់ខែមេសា ឆ្នាំ៧៧។ តើឯកសារទាំងបួនហ្នឹងធ្វើឲ្យលោកនឹកឃើញអំពីពេលវេលានៃការចូលរួមក្នុងកិច្ចប្រជុំដែលគេផ្តល់ការណែនាំឲ្យបោសសម្អាតមន្ត្រីរដ្ឋការ និងយោធាលន់ នល់ដែរឬទេ? ហើយតើលោកអាចចាំបានដែរឬទេ ថាតើ -- ប្រសិនបើធៀបជាមួយនឹងខែមេសា ៧៧ ហ្នឹង តើការប្រជុំណែនាំឲ្យបោសសម្អាតហ្នឹងគេធ្វើនៅមុន ឬក្រោយខែមេសា ឆ្នាំ៧៧?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ទៅនឹងការសួរសំណួរនេះ ព្រោះថាវាជាសំណួរនាំមុខ។ វាមិនមែនជាវិធីសាស្ត្រល្អក្នុងការសួរសាក្សីដែលផ្តល់នូវចម្លើយទាំងអស់អំពីកាលបរិច្ឆេទ បន្ទាប់មកឲ្យសាក្សីគាត់ឆ្លើយថា អះអាងតាមតែប៉ុណ្ណោះ។ សួរថាវាមានប្រយោជន៍អី?

[១១:៣២:៤៧]

**លោក ឌេល លីសាក់៖**

ខ្ញុំសូមបញ្ជាក់ថា ហេតុផលដែលខ្ញុំផ្តល់ឯកសារដើម្បីឲ្យសាក្សីគាត់យល់ ហើយអាចនឹកឃើញ។ ដូច្នេះ សំណួរមិនមែនជាការនាំមុខទេ ខ្ញុំគ្រាន់តែសួរថា តើមុន ឬក៏ក្រោយខែមេសា ឆ្នាំ៧៧។ វាមិនមែន

ជាសំណួរនាំមុខទេ ផ្ទុយទៅវិញ គឺវាជាសំណួរមិននាំមុខ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី។ ហើយអង្គជំនុំជម្រះត្រូវការស្ដាប់នូវចម្លើយតបរបស់សាក្សី នៅចំពោះសំណួរចុងក្រោយដែលសួរឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ។

សាក្សីឆ្លើយតបទៅនឹងសំណួរ!

**លោក រៀល សន៖**

**ឆ៖** សួរម្ដងទៀត ខ្ញុំភ្លេចហើយអំមិញ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ថាតើឯកសារទាំងអស់ហ្នឹងធ្វើឲ្យលោកនឹកឃើញអំពីពេលវេលានៃការប្រជុំ ដែលលោកចូលរួម គឺការប្រជុំដែលគេផ្ដល់ការណែនាំឲ្យបោសសម្អាតទាហាន និងមន្ត្រីរាជការលន់ នល់។ តើលោកចាំ ថាតើការប្រជុំណែនាំនេះ គេធ្វើឡើងនៅមុន ឬក៏នៅក្រោយខែមេសា ឆ្នាំ៧៧?

**ឆ៖** អង្គប្រជុំៗនេះ គេធ្វើមុនៗឆ្នាំ៧៧។

[១១:៣៤:២៨]

**ស៖** លោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្តមួយសំណួរទៀតមុននឹងខ្ញុំប្ដូរប្រធានបទ។ តើលោកចាំទេ ថាតើការប្រជុំហ្នឹងគឺស្ថិតនៅក្នុងពេលដែលលោកធ្វើការនៅមន្ទីរពេទ្យស្រុក។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ប្រជុំហ្នឹងគឺនៅពេលដែលខ្ញុំនៅធ្វើការនៅមន្ទីរពេទ្យស្រុក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសហព្រះរាជអាជ្ញារងអន្តរជាតិ។ បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយនិងសាមសិបនាទី។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោម

សាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៥ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣១:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការកិច្ចនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** បាទ យើងបាននិយាយគ្នាអំពីកិច្ចប្រជុំមួយដែលលោកបានចូលរួម ដែលៗលេខាស្រុកបានចូលរួមពន្យល់អំពីប្រភេទប្រជាជនដែលត្រូវបោសសម្អាត។ ហើយខ្ញុំបានសួរលោកថា -- អំពីការចងចាំរបស់លោកទៅណា ថាតើ ប្រធាន -- ចៅហ្វាយស្រុក ឬលេខាស្រុកមានវត្តមានឬក៏អត់? នៅក្នុងឯកសាររបស់លោក គឺ E3/19.1.21 នៅត្រង់ចម្លើយ១៣៥ទៅដល់១៣៩ គឺឈ្មោះកិច្ចប្រជុំមួយដែលមានលេខាស្រុកឈ្មោះ កម ជឹម។ “តើប្រធាន ចៅហ្វាយស្រុកឈ្មោះអី? ឈ្មោះ ជឹម” ហើយត្រង់ចម្លើយលេខ៣៩៖ “តើ ជឹម ជាចៅហ្វាយនោះ គឺមានប្រាប់ប្រជាជនអំពីប្រភេទប្រជាជនដែលត្រូវបោសសម្អាតទេ? ចម្លើយថា៖ គាត់បានពន្យល់ដូច្នេះមែន”។ តើនេះជួយរំឭកដល់ការចងចាំរបស់លោកថាលេខាស្រុកដែលធ្វើជាអធិបតីភាពក្នុងកិច្ចប្រជុំឈ្មោះ ជឹម ឬក៏អត់ ដែលនិយាយអំពីការបោសសម្អាតនោះ?

[១៣:៣៣:៥៥]

**លោក រៀល សន៖**

**ឆ៖** បាទ គឺឈ្មោះ ជឹម ជាអ្នកនិយាយ។

**សៈ** លោកចាំទេ តើ ឆាយ មានវត្តមាននៅក្នុងពេលប្រជុំហ្នឹងទេ?

**ឆៈ** ចាយទេហេ? បាទ តាចាយ ក៏នៅក្នុងនុំងដែរ។

**សៈ** លោកបានលើកឡើងថា នៅក្នុងកិច្ចប្រជុំដែលនេះ គឺឯកសារ E3/19.1.21 ត្រង់សំណួរ-ចម្លើយលេខ៤៣ ថាលោកបានឮថាប្រជាជនមកពីកម្ពុជាក្រោមត្រូវបានចោទប្រកាន់ថាជាភ្នាក់ងារយួន ហើយខ្មែរក្រោមគឺថាត្រូវតែសម្លាប់ចោល។ ភស្តុតាងដែលអង្គជំនុំជម្រះទទួលយកនោះគឺមានបញ្ជីមកពីឃុំប្រាំមួយខុសៗគ្នា ដែលកំណត់ថាខ្មែរក្រោម។ ក្នុងនោះក៏មាននៅក្នុងឯកសារពីរបប លន់ នល់ គឺពីមេសា ទៅដល់ឧសភា ១៩៧៧។ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញជូនសាក្សីនូវបញ្ជីស្ដីអំពីប្រជាជនខ្មែរក្រោមចំនួនពីរគឺ E3/2281 – E3/2281។ សុំការអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក ឌេល លីសាក់៖**

**សៈ** លោកសាក្សី ឯកសារដែលបង្ហាញជូនលោកនេះគឺជារបាយការណ៍ ចុះហត្ថលេខាដោយកម្មាភិបាលម្នាក់ឈ្មោះ ម៉ុន ចុះថ្ងៃទី៤ ខែឧសភា ១៩៧៧ មានចំណងជើងថា “បញ្ជីប្រជាជនក្រោមមកពីឃុំត្រពាំងធំជើង” គឺឃុំរបស់លោកដែលកំណត់ថាប្រជាជនខ្មែរក្រោម ៧៣គ្រួសាររស់នៅក្នុងឃុំហ្នឹង រួមទាំងពីអ្នកមានមុខងារពីរបបមុន ហើយនិងអ្នកដែលមានបុណ្យស័ក្តិ និងអ្នកដែលជាអតីតកងទ័ព។ លោកសាក្សី តើ ម៉ុន ដែលចុះហត្ថលេខាលើរបាយការណ៍នេះ ជាអ្នកណាដែរ?

**ឆៈ** ម៉ុន នេះគឺជាមេឃុំត្រពាំងធំខាងជើង។

**សៈ** តើ ម៉ុន គឺជាមេឃុំម្នាក់ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំដែលលោករៀបរាប់ថាមានគេណែនាំថាតើប្រជាជនប្រភេទណាដែលត្រូវបោសសម្អាតនោះ។ តើ ម៉ុន ហ្នឹងឬជាអ្នកចុះហត្ថលេខា?

**ឆៈ** បាទ។

[១៣:៣៧:១៩]

**សៈ** សូមមើល លោកមើលបញ្ជីប្រជាជនខ្មែរក្រោមហ្នឹង តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថាតើគ្រួសារខ្មែរក្រោមនៅក្នុងបញ្ជីហ្នឹង គឺប្រជាជនដែលមានប្រភពចេញមកពីឃុំត្រពាំងធំខាងជើងឬ? ឬក៏ជាប្រជាជនដែលត្រូវបានគេជម្លៀសហើយមកតាំង ដូចជាគេដាក់ទៅតាំងលំនៅដ្ឋានមួយប្រជាជនខ្មែរក្រោមមកពីភ្នំពេញ ឬក៏ផ្នែកផ្សេងទៀតឬ?

**ឆ៖** តាមពិត ខ្ញុំៗភ្លេចអស់ មិនស្គាល់ៗ តើឈ្មោះនេះជាឈ្មោះអ្នកនៅកម្ពុជាក្រោមដែរឬអត់ទេ ខ្ញុំភ្លេចហើយ ហើយខ្ញុំក៏មិនបានស្គាល់ទាំងអស់គ្នាដែរ។

**ស៖** លោកសាក្សី ខ្ញុំសូមបង្ហាញឯកសារពីរមកពីឃុំពពេល។

**លោក ឌេល លីសាក់៖**

លោកប្រធានសុំការអនុញ្ញាត ឯកសារនេះគឺឯកសារ E3/2262, E3/2917។ បាទសូមបង្ហាញឯកសារពីរនេះជូនសាក្សីមើល។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

លោក កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមការបញ្ជាក់ពីតំណាងសហព្រះរាជអាជ្ញា គឺឯកសារបង្ហាញ E3/2281។ អ៊ីចឹងមែនទេ? ហើយសាក្សីគេបានប្រាប់ថាបញ្ជីនេះគឺមានគ្រួសារប្រជាជនខ្មែរក្រោម ប៉ុន្តែខ្ញុំមើលអត់ឃើញមានបញ្ជីហ្នឹងទេ នៅក្នុងឯកសារនេះ។ ដូច្នេះប្រសិនបើសហព្រះរាជអាជ្ញារងអាចជម្រាបជូនថាតើនៅកន្លែងណានៃឯកសារនេះ?

**លោក ឌេល លីសាក់៖**

គឺនេះគឺជាឯកសារមួយដែលមានការបកប្រែផ្សេងគ្នា។ ខ្មែរ ឯកសារខ្មែរដើមគឺ គេបកប្រែ --

គឺជាភាសាបារាំងនិយាយពីខ្មែរកម្ពុជាក្រោម ដល់ពេលភាសាអង់គ្លេសគឺថាបាត់កន្លែងហ្នឹង។

[១៣:៤០:០៩]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកតំណាងសហព្រះរាជអាជ្ញាដែលបានពន្យល់នេះ។ គឺយើងកំពុងក្រឡេករកមើលទៅវាអត់ឃើញ មានបញ្ហា។

លោកប្រធាន ពីរយៈ -- អង្គភាពបកប្រែភាសាមានភាពខុសគ្នារវាងការបកប្រែជាភាសាអង់គ្លេសនិងភាសាបារាំង។ ដូចជាពាក្យ “បោសសម្អាត”។ ពាក្យនេះ គឺបាត់ប្រហែលជា២០ដងឯណោះ ហើយនៅក្នុងអត្ថបទភាសាអង់គ្លេសក្រៅពី -- ដូចជាពាក្យថា “កម្ទេច”នេះ – “ក.ទ” គឺគេបកថា គឺជា “ខេ.ធី” ហើយក៏សួរថាតើ “ខេ.ធី” មានយ៉ាងម៉េចថាទុកឲ្យភាគីជាអ្នកកំណត់។ អ៊ីចឹងឯងបានទើបជា

ភាគីជំទាស់ទៅលើពាក្យពេចន៍នេះ។ ប៉ុន្តែឥឡូវនេះ ចំណុចឆកល្វែងមួយទៀតគឺថា ក្នុងអត្ថបទអង់គ្លេស គឺបាត់បង់ -- ខុសពីការបកប្រែទៅជាភាសាបារាំង។ ដូច្នេះ យើងមានបញ្ហាធំដុំនៅត្រង់កន្លែងនេះ។ ដូច្នេះ យើងខ្ញុំសង្ឃឹមថាការបកប្រែគឺថាត្រូវបកប្រែឲ្យបានដូចគ្នា ទាំងភាសាបារាំង និងភាសាអង់គ្លេស។

**លោក ខេល លីសាក់៖**

លោកប្រធានសុំការអនុញ្ញាត។ នេះគឺជាបញ្ហាដែលអាចដោះស្រាយ គឺថាមានឯកសាររាប់ពាន់ទំព័រដែលបានបកប្រែដាក់ក្នុងសំណុំរឿង។ មិនមានការបកប្រែណាវាល្អឥតខ្ចោះបានទេ។ វាតែងតែមានភាពខ្វះចន្លោះ បើសិនណាជាមាន អ៊ីចឹងដាក់ទៅចូលខាងផ្នែកអង្គភាពបកប្រែភាសាទៅ។ យើងគិតថា កាលណារកឃើញមួយ ដាក់ជូនទៅអង្គភាពបកប្រែភាសាមួយទៅ សុំឲ្យមានការកែតម្រូវជាការរួចរាល់ហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

បើសិនណាខ្ញុំមិនយកចិត្តទុកដាក់ទេគឺវាៗអាច គឺគ្មានណា -- វាកន្លងផុតទៅហើយ គ្មានអ្នកណាអាចនឹងដឹងទេ។ នេះមិនមែនជាបញ្ហាលម្អិត ប៉ុន្តែវាជាបញ្ហាចម្បង។ គួរណាស់តែមិនត្រូវមានកំហុសណាមួយរវាងការបកប្រែក្នុងចំណោមភាសាទាំងនេះទេ។ បញ្ហាចម្បង វាអាចមានការប៉ះពាល់ទៅដល់សាក្សីរូបនេះផ្ទាល់តែម្តង។ អ៊ីចឹង បើសិនណាជាយើងយកឯកសារមួយនេះទៅប្រៀបធៀបទៅនឹងឯកសាររាប់ពាន់ទៀតគឺថា ខ្ញុំគិតថាមិនជាការត្រឹមត្រូវនោះទេ។

[១៣:៤២:៥២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៧:២០]

**ប្រធានអង្គជំនុំ៖**

បាទ ហើយបញ្ហានេះបានជាកើតមានហើយ ទី១ គឺឯកសារជាភាសាខ្មែរ ដែលជាឯកសារដើម ដូច្នេះបញ្ហានេះ គឺយើងផ្អែកទៅលើឯកសារខ្មែរជាមូលដ្ឋាននៅក្នុងការពិភាក្សានេះ។ ទី២ ខាងការិយាល័យសហព្រះរាជអាជ្ញាបានជ្រាបអំពីបញ្ហាខុសគ្នារវាងការបកប្រែពីភាសាខ្មែរ មកភាសាបារាំងត្រូវគ្នា ហើយនិងទៅភាសាអង់គ្លេសខុសហើយ ប៉ុន្តែខាងតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបែរជាទុកបញ្ហានេះនៅស្ងៀមមិនបញ្ជូនទៅឲ្យអង្គភាពបកប្រែភាសាដើម្បីកែតម្រូវមុនពេលដេញដោល ហើយយកបញ្ហានេះមកប្រឈម ចំណាយពេលពិភាក្សានៅទីនេះ កើតបញ្ហាដដែលៗទៅវិញ។ ចាប់ពីពេលអំណឹះតទៅ

បើមានករណីបែបនេះ គឺសូមឲ្យរៀបចំនូវ បញ្ជូនទៅខាងអង្គភាពបកប្រែ ឲ្យបកប្រែភាសានេះ ឲ្យបានកែតម្រូវ ឲ្យបានត្រឹមត្រូវ ហើយជូនភាគីជ្រាបជាមុន មុនពេលពិភាក្សាដេញដោល។

បញ្ហាទី៣ ភាគីទាំងអស់សុទ្ធតែមានភាគីជាតិ។ ដូច្នេះភាគីជាតិ ជាពិសេសមេធាវីការពារក្ដីដែលលើកឡើងនេះ គឺក៏មានភាគីជាតិដែរ។ ភាគីជាតិត្រូវរួមយ៉ាងសកម្មនៅក្នុងការបញ្ជាក់អំពីភាពត្រឹមត្រូវនៃឯកសារដើម ដែលជាឯកសារភាសាខ្មែរ ដើម្បីឲ្យកិច្ចដំណើរការហ្នឹងវាបានជជែកពិភាក្សាទៅ បានទៅមុខល្អ ហើយចំណែកឯកន្លងមកនេះ យើងបានធ្វើជាច្រើនលើក ច្រើនសាហើយ ដោយចាត់ឲ្យមន្ត្រីជាន់ខ្ពស់នៃ-- មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្របសម្រួលជាមួយនឹងអង្គភាពបកប្រែភាសា ដើម្បីធ្វើយ៉ាងណាឲ្យការបកប្រែភាសាហ្នឹង ទាំងឯកសារដែលមានកន្លងមក ទាំងមានកំហុសនេះ ហើយនិងការបកប្រែទៅថ្ងៃមុខឲ្យបាន ឲ្យបានសុក្រឹត។ អានេះយើងបានធ្វើម្ដងហើយម្ដងទៀត យើងធ្វើញឹកញាប់។ ប៉ុន្តែបច្ច័យវានៅតែមាន ដោយសារមូលហេតុសំណុំរឿងក្ដីនេះ មានឯកសារវាច្រើន រាប់លានឯកសារឯណោះ រាប់លានទំព័រឯណោះ អ៊ីចឹងហើយបានជាវាមានបញ្ហា។ អ៊ីចឹងបញ្ហានេះទំនងជាអាចដោះស្រាយបញ្ហានេះបានទៅថ្ងៃមុខ។

សូមអញ្ជើញបន្តលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៣:៤៩:៤០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំគឺថា កាលណាឃើញមានចន្លោះប្រយោងណាមួយ យើងខ្ញុំនឹងជម្រាបជូនតែម្ដង។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំទើបតែឲ្យឯកសារពីរទៅលោកមកពីឃុំពពេល។ ឯកសារ E3/2917 គឺជារបាយការណ៍ផ្ញើពីឃុំពពេល នៅដើមខែឧសភា ១៩៧៧ ដែលនិយាយថា ខ្មែរ -- គ្រួសារខ្មែរក្រោម ៦៤គ្រួសារត្រូវបានទទួល ហើយនិងដោះដូរជាមួយវៀតណាម។ ឯកសារ E3/2262 គឺជាបញ្ជីដែលកំណត់ថា ខ្មែរក្រោម៦៤គ្រួសាររស់នៅក្នុងឃុំពពេលនេះដែរ រួមទាំងអ្នកដែលមានមុខងារពីរបបចាស់ផង។ លោកបាននិយាយនៅក្នុងកិច្ចសម្ភាសន៍ E3/19.1.21 ត្រង់ចម្លើយ៩៧ ដែលថា៖ “ខ្មែរ ប្រជាជនខ្មែរក្រោមថ្មី។ មានន័យថា អ្នកដែលទើបតែមករស់នៅទីនេះ គឺមិនមែនអ្នកដែលធ្លាប់រស់នៅភូមិស្រុកនេះក្នុងរយៈពេលយូរមកហើយនោះទេ”។ បញ្ចប់ការដកស្រង់។ គឺត្រូវបានខ្មែរក្រហមកំណត់មុខសញ្ញា។

សំណួរខ្ញុំតើប្រជាជនខ្មែរក្រោមថ្មី ដែលលោកថាជាគោលដៅនោះ គឺត្រូវបានទទួល និងដោះដូរជាមួយនឹងប្រជាជនវៀតណាម។ អ៊ីចឹងទេ?

[១៣:៥១:៣៥]

**លោក រៀល សនះ**

**ឆះ** អារឿងដោះដូរជាមួយវៀតណាម គឺខ្ញុំអត់ដឹងទេ។ ដឹងតែថាប្រជាជនកម្ពុជាក្រោមថ្មីដែលមកអត់មានកូនមានចៅ មកពីរនាក់ប្តីប្រពន្ធហ្នឹង ហ្នឹងជាមុខសញ្ញា។

**សះ** សូមលោកពន្យល់លម្អិតបន្តិចមក តើប្រជាជនដែលគេកំណត់ជាគោលដៅនេះ ជាអ្នកណា?

**ឆះ** ប្រជាជនជាគោលដៅហ្នឹង គឺប្រជាជនកម្ពុជាក្រោមដែលទើបនឹងមកថ្មីហ្នឹង មកតែពីរនាក់ប្តីប្រពន្ធក្តី ឬក៏មកជាពួកសុទ្ធតែចាស់ៗអត់មានកូនក្មេងហ្នឹង គឺគេសំដៅថាជាគិញយួន ជាអ៊ីចឹងហ្សេ.កា.បេ បាទ។

**សះ** ចុះចំណុចសំខាន់នោះ សំខាន់ត្រង់ថាគេមានកូន ឬក៏មិនចាំបាច់មានកូនមកជាមួយ?

**ឆះ** ចំណុចសំខាន់ហ្នឹង គឺអ្នកដែលមកអត់មានកូនហ្នឹង គឺមកធ្វើការឲ្យយួនតែម្តង បើតាមការណែនាំពីខាងលើ។

**សះ** ខ្ញុំបានបង្ហាញលោកនូវឧទាហរណ៍ពីរ ចេញពីបញ្ជីដែលរៀបចំឡើងដោយឃុំកំណត់ប្រជាជនខ្មែរក្រោមថាជាមុខសញ្ញា។ តើនៅក្នុងកិច្ចប្រជុំដែលលោកបានចូលរួមនោះ ឬក៏នៅពេលណាមួយទៀតដែលគេបានណែនាំឲ្យរៀបចំបញ្ជីប្រជាជនខ្មែរក្រោមរស់នៅក្នុងឃុំនីមួយៗហ្នឹង?

**ឆះ** បាទ គឺគេប្រជុំណែនាំមេឃុំ មេភូមិអីទាំងអស់ហ្នឹង ឲ្យធ្វើបញ្ជីឡើង។

**សះ** លោកចាំទេ អ្នកណាដែលអ្នកបានផ្តល់ជាបញ្ជានេះ មកបញ្ជាឲ្យថ្នាក់ឃុំរៀបចំបញ្ជីហ្នឹង?

**ឆះ** បាទ គឺគណៈស្រុក។

[១៣:៥៤:៤៧]

**សះ** ខ្ញុំចង់សួរលោកអំពីចម្លើយមួយចំនួនដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត។ ទី១ គឺឯកសារ E3/5511 ត្រង់ចម្លើយលេខ១០ លោកបានឆ្លើយដូចតទៅ សូមដកស្រង់៖ "ប្រជាជនវៀតណាមគឺគេមិនបាននិយាយនៅក្នុងកិច្ចប្រជុំនោះទេ។ ប៉ុន្តែក្រោយមកប្រជាជនវៀតណាមដែលរស់នៅទីនេះជាយូរមកហើយបានបាត់ខ្លួនអស់"។ បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំសួរថាតើប្រជាជនវៀតណាមទាំងអស់នេះដែលរស់នៅទាំងអស់នេះ បានបាត់ខ្លួន ហើយបើបាត់ខ្លួន បាត់ខ្លួននៅពេលណា?

**ឆ៖** ប្រជាជនវៀតណាមទាំងអស់នោះបាត់ខ្លួននៅពេលយប់ ឬក៏ពេលកំពុងធ្វើការ ធ្វើការពលកម្មនៅតាមប្រឡាយ តាមអីហ្នឹង។ វាហៅយកទៅបាត់អស់។

**សៈ** នៅក្នុងកិច្ចសម្ភាសន៍មួយទៀតគឺឯកសារ E319.1.21 ត្រង់សំណួរចម្លើយ១០៣ គឺដូចសួរដូចតទៅ៖ "ថាតើលោកដឹងថាខ្មែរ ប្រជាជនខ្មែរក្រោមត្រូវគេបញ្ជូនទៅក្រាំងតាចាន់ ឬគុក២០៤ ដោយរបៀបណា? ឆ្លើយ៖ ចំពោះខ្ញុំ ខ្ញុំមិនដឹងទេ ប៉ុន្តែគុក២០៤ ខ្ញុំដឹងដោយសារមន្ទីរពេទ្យរបស់ខ្ញុំស្ថិតនៅជាប់នឹងថ្នល់ ហើយខ្ញុំបានឃើញគេបណ្តើរមនុស្សប្រហែលជាង២០នាក់ នៅស្រុកគីរីវង់ កាត់តាមកន្លែងរបស់ខ្ញុំ ហើយពួកគេបានឈប់នៅកន្លែងរបស់ខ្ញុំដើម្បីសុំថ្នាំ។ ពេលនោះ ខ្ញុំសួរថាស្អីគេហ្នឹង? គេប្រាប់ថា គេសុទ្ធតែជាពួក កា.ហ្សេ.បេ និងគិញយួន ហើយពួកគេថានឹងយកទៅដាក់គុក២០៤"។ សូមលោកជម្រាបជូនអង្គជំនុំជម្រះ ថាតើគុក២០៤ មានទីតាំងនៅឯណា? ហើយគុក២០៤នេះ មានចម្ងាយប៉ុន្មានពីមន្ទីរពេទ្យរបស់លោក?

[១៣:៥៧:២០]

**ឆ៖** គុក២០៤នេះ ស្ថិតនៅក្នុងភូមិព្រៃក្តួច សព្វថ្ងៃ ឃុំអូរសារាយ ស្ថិតចម្ងាយប្រហែល ១៧-១៨ គីឡូម៉ែត្រពីមន្ទីរពេទ្យខ្ញុំកាលនោះ។

**សៈ** លោកចាំទេ តើឆ្នាំណាដែរនៅពេលដែលលោកឃើញប្រជាជន២០នាក់ហ្នឹង ត្រូវបានចាប់ខ្លួនហើយនិងយកនាំទៅគុក២០៤ នៅពេលណាដែរ?

**ឆ៖** ខ្ញុំបាទភ្លេចឆ្នាំដែរ យូរពេក ប្រហែលជាអត់បានគិតផង។

**សៈ** ខ្ញុំសូមឱ្យលោកបញ្ជាក់ចំណុចមួយ។ តើលោកជឿថា ក្រុមមនុស្ស២០នាក់ហ្នឹងគឺជាខ្មែរក្រោមឬ? តើគេប្រាប់លោកថាគេជាខ្មែរក្រោមដែរឬទេ? ឬក៏កម្មាភិបាលដែលចាប់អ្នកទាំងនោះបានប្រាប់ថា គឺពួកអ្នក២០នាក់នេះ គឺត្រូវគេចោទថា កា.ហ្សេ.បេ ឬក៏ភ្នាក់ងារយួន តើ -- សូមលោកពន្យល់បន្តិចមើល៍។

**ឆ៖** បាទ ខ្ញុំគ្រាន់តែដឹងថា អ្នកដែលយកទៅហ្នឹងប្រាប់ថាជាប្រជាជនកម្ពុជាក្រោម មិនដឹងថា -- គេអត់មានប្រាប់ថាជា កា.ហ្សេ.បេ ឬជាអីទេ ប៉ុនគេថាជាប្រជាជនកម្ពុជាក្រោម ព្រោះអ្នកដែលទៅជាមួយគេហ្នឹងគឺមិនមែនមកជួបខ្ញុំទេ ជួបតែអ្នកបណ្តើរ មានស្ពាយកាំភ្លើងមានអី មកសុំថ្នាំសុំអីនៅមន្ទីរពេទ្យហ្នឹង។

**សៈ** តើលោកដឹងទេ ប្រជាជនដែលគេបណ្តើរអ្នកទោសហ្នឹងទៅ ជាកម្មាភិបាលមកពីស្រុក

ត្រាំកក់ ឬក៏កម្មាភិបាលមកពីតំបន់? តើអ្នកដែលបណ្ដើរអ្នកទោសហ្នឹងទៅ ជាអ្នកណា?

**ឆ៖** ខ្ញុំបាទមិនស្គាល់ឈ្មោះទេ ប៉ុន្តែគ្រាន់តែថា គេប្រាប់ខ្ញុំបាទ ថាគេនៅស្រុកគីរីវង់ៗ ស្រុក ១០៩។ កាលនោះគេហៅស្រុក១០៩។

[១៤:០០:០០]

**ស៖** ហើយថាតើលោកដឹងថាគុក២០៤ ជាគុកស្រុក ឬក៏គុកតំបន់ ឬក៏ជាគុកភូមិភាគ?

**ឆ៖** ខ្ញុំមិនបានដឹងថាគុក២០៤ ជាគុកតំបន់ ឬស្រុកទេ ប៉ុន្តែធាតុពិតគឺនៅក្នុងស្រុក១០៥ ហ្នឹងតែម្ដង។

**ស៖** តើលោកមានបានឃើញទីតាំងគុក២០៤ទេក្រោយរបបខ្មែរក្រហមដួលរលំទៅ? ហើយបើសិនជាបានទៅមើលមែន តើ សូមលោកជម្រាបជូនអង្គជំនុំជម្រះបន្តិចមកអំពីគុក២០៤ នេះ។

**ឆ៖** គុក២០៤នេះ បើតាមខ្ញុំទៅឃើញវាបាក់ខ្ទេចខ្ទីអស់ទៅហើយ។ មានអគារពីរតូចៗធ្វើអំពីស្លឹក ប្រក់ស្លឹក ជញ្ជាំងស្លឹក តូចៗទេ។ ហើយខ្ញុំទៅឃើញហ្នឹងវាខ្ទេចខ្ទាំអស់ហើយ ខ្ញុំទៅធ្វើចម្ការក្បែរហ្នឹង នៅក្បែរភ្នំដាច់ និងភ្នំពាំង។ ហើយឃើញមាន ដែលទៅធ្វើ -- ប្រជាជនខ្លះទៅធ្វើស្រែនៅចំកន្លែងកណ្ដាលពីលើហ្នឹង មានឃើញឆ្អឹងខ្មោច មានឃើញឆ្អឹងក្បាលខ្មោច ប៉ុន្តែមិនច្រើនទេ តិចតួច។

**ស៖** តើលោកបានឃើញឆ្អឹងនេះដោយផ្ទាល់ភ្នែកឬ? ឬក៏គេប្រាប់លោកថាគេបានឃើញឆ្អឹងខ្មោចហ្នឹង?

**ឆ៖** ខ្ញុំចុះពីធ្វើចម្ការមក -- ចុះពីកាប់ព្រៃធ្វើចម្ការមកឃើញក្បាលខ្មោចពីរបីនៅក្នុងព្រៃក្បែរហ្នឹង មានឆ្អឹងជើង ឆ្អឹងដៃអី នៅជិតៗហ្នឹងពីរបីហ្នឹង មិនច្រើនទេ គ្រាន់តែមានឃើញឆ្អឹង ដែលប្រជាជនគាត់ធ្វើស្រែហើយ គាត់បោះទៅគាត់មិនកប់ ព្រោះសុទ្ធតែមានតែឆ្អឹង គាត់អត់កប់។

[១៤:០២:៤៦]

**ស៖** ប្រជាជនមួយក្រុមផ្សេងទៀតដែលលោកនិយាយថា ថ្នាក់ស្រុកបានណែនាំឱ្យបោសសម្អាត ហើយខ្ញុំសូមដកស្រង់ចេញពីចម្លើយរបស់លោក គឺប្រជាជនដែលនាំគ្នានិយាយអំពីរបបខ្មែរក្រហម -- លោកប្រធានក្នុងពេលនេះ សូមបង្ហាញឯកសារជូនទៅសាក្សីគឺឯកសារ E3/4093 គឺ E4093។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីខ្ញុំសូមផ្ដល់ឯកសារពីរ គឺ E3/4093, ERN ជាភាសាខ្មែរគឺ 00270786 ដល់ 87, អង់គ្លេស 00831487, បារាំង 00729674។ នេះគឺជាឯកសារមកពីតាសាន ចុះថ្ងៃទី៧ ខែសីហា ១៩៧៨ ដែលផ្ដល់ការណែនាំឲ្យបោសសម្អាតស្ត្រីមេម៉ាយប្រាំ មកពីឃុំត្រពាំងធំជើង គឺបានណែនាំមកដល់សមមិត្ត ម៉េង។ ឯកសារ ERN គឺ 0027788 ដល់ 89, អង់គ្លេស 0083 -- បារាំង 00729674 ដល់ 75 ដែលជាកំណត់ត្រាមកពី ម៉េង ចុះថ្ងៃទី៨ សីហា ១៩៧៨។ គឺថាវាជារបាយ-ការណ៍មកពីត្រពាំងធំជើង ស្ដីអំពីស្ត្រីមេម៉ាយប្រាំនាក់ដែលរិះគន់ដល់បដិវត្តន៍ ហើយមានផែនការរត់ទៅវៀតណាម។ សំណួររបស់ខ្ញុំ លោកស្គាល់ទេថា សមមិត្តម៉េង ហ្នឹងជាអ្នកណាដែរ?

**ឆ៖** បាទ អត់ស្គាល់។ ខ្ញុំអត់ស្គាល់ផង។

**ស៖** ហើយលោកដឹងទេថាតើមានកងមួយហៅថា "កងមេម៉ាយ" នៅឃុំត្រពាំងធំខាងជើងនេះ មានកងមេម៉ាយអ៊ីចឹងទេ?

**ឆ៖** បាទ មានៗកងមេម៉ាយមួយកង។

[១៤:០៦:០៧]

**ស៖** ហើយសូមលោកជម្រាបមើល ថាតើកងមេម៉ាយនេះជាកងអ្វីដែរ?

**ឆ៖** កងមេម៉ាយនេះ គឺជាមនុស្សស្រីដែលអត់មានប្ដីទាំងអស់គ្នាមួយកងហ្នឹង អត់មានប្ដីទេ ទាំងបងប្អូនប្រជាជនមកពីភ្នំពេញ ទាំងមូលដ្ឋានហ្នឹងគឺអត់មានប្ដី ទៅនៅហ្នឹងជាមួយគ្នា ធ្វើការងារជាមួយគ្នា។

**ស៖** លោកដឹងទេហេតុអ្វីបានជាស្ត្រីទាំងអស់នេះគេដាក់នៅកងមួយដាច់ដោយឡែកអ៊ីចឹង?

**ឆ៖** ខ្ញុំបាទៗមិនដឹងមូលហេតុអីទេរឿងមេម៉ាយហ្នឹង អត់ដឹងទេ ចង់ធ្វើម៉េច ខ្ញុំអត់។

**ស៖** សូមបង្ហាញលោកនូវចម្លើយដែលលោកជូនឆ្លើយមជ្ឈមណ្ឌលឯកសារ គឺឯកសារ D313/1.2.409 គឺERN ខ្មែរ 00418846, អង់គ្លេស 00729063 ហើយបារាំង 00808645។ ហើយលោកឆ្លើយដូចតទៅនេះ គឺជាចម្លើយដែលលោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជា៖ "ចំពោះពាក្យថានយោបាយនិងខ្មាំង គឺនិយាយអំពីខ្មាំងដែលជ្រាបចូលពីក្នុងចំណោមអ្នកជំងឺ ឬក៏អ្នកដទៃទៀត។ យើងត្រូវបានគេបញ្ជាឲ្យរើករកខ្មាំងទាំងអស់នេះ"។ សំណួររបស់ខ្ញុំ ថាតើអ្នកណាដែលបញ្ជាទៅដល់ពេទ្យស្រុកឲ្យកំណត់មុខ រើកមុខរកខ្មាំងក្នុងចំណោមជំងឺទាំងនេះ?

**ឆ៖** គឺគណៈស្រុក គឺលេខាស្រុក។

[១៤:០៨:២៩]

**ស៖** តើមានលេខាស្រុកពិសេស ឬក៏លេខាស្រុកណាមួយគាត់បញ្ជាដោយផ្ទាល់ ឬមួយក៏ជាបញ្ជាទូទៅ ទៅថ្នាក់ស្រុក?

**ឆ៖** គឺគាត់បញ្ជាទូទៅ ទូទៅទាំងអស់ មិនថាតែមន្ទីរពេទ្យទេ នៅតាមភូមិនៅតាមអីទាំងអស់ដូចគ្នា។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរសំណួរលោកពីរបីពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួនទៀត អំពីការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា គឺទស្សនាវដ្តីទង់បដិវត្ត។

**លោក ឌេល លីសាក់៖**

ជាដំបូងខ្ញុំសូមអនុញ្ញាតផ្តល់ជូនឯកសារ គឺទស្សនាវដ្តីទង់បដិវត្តខែមេសា ឆ្នាំ៧៧ គឺឯកសារ E3/742។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ឯកសារនេះគឺទស្សនាវដ្តីទង់បដិវត្ត៍ចុះខែមេសា ឆ្នាំ៧៧។ នេះគឺជារយៈពេលដែលយើងពិភាក្សានេះ គឺរយៈពេលក្នុងខែមេសា ឆ្នាំ៧៧។ ហើយយើងមើលទៅផ្នែកចុងក្រោយនៃទស្សនាវដ្តីនេះ គឺនៅទំព័រចុងក្រោយបំផុត នៅចុងបញ្ចប់នេះ គឺថាកម្មាភិបាលបក្សត្រូវបានគេបង្គាប់ដូចតទៅនេះ។ ខ្ញុំសូមដកស្រង់៖ “ទី១ គ្រប់មូលដ្ឋានទាំងអស់ ហើយនិងគ្រប់កងទាំងអស់ត្រូវតែរៀបចំការសិក្សាឯកសារនេះ ទី២ គឺចាំបាច់ត្រូវតែមានការសិក្សាឲ្យបានលម្អិតជារួម ហើយសិក្សាជាក្រុម ឬក៏ជាបុគ្គល”។ សូមបញ្ចប់ការដកស្រង់។ ឥឡូវនេះ ខ្ញុំចង់អាននូវទស្សនាវដ្តីទង់បដិវត្តមួយចំនួនដែលខ្ញុំចង់ឲ្យលោកស្តាប់ ហើយបន្ទាប់មកខ្ញុំចង់ដឹងថាតើលោកចាំថាធ្លាប់ទទួលការបញ្ជា ឬក៏ការបង្គាប់អំពីបញ្ហានេះ គឺថាតើខាងមេដឹកនាំស្រុកត្រាំកក់ធ្លាប់ប្រាប់លោកដែរឬទេ ឯកសារទី១ គឺខ្មែរមានលេខ 0006 2986, អង់គ្លេសមានលេខ 00478986, បារាំងមានលេខ 00999754 ដែលមានការដកស្រង់ដូចតទៅនេះ៖ “ចំពោះខ្មាំងដែលជា អេ.អ៊ី.អា, កា.ហ្សេ,បេ និងភ្នាក់ងារយួន។ ផ្តែបម្រើចោកទាបរបស់ខ្មាំងដែលលួចបង្កប់ចូលទៅក្នុងបដិវត្តន៍របស់យើង ទាំងនៅក្នុងជួរបដិវត្តន៍របស់យើង” ហើយចុះមកក្រោម

បន្តិច "យើងត្រូវតែបន្តវៃ ហើយកម្ទេចពួកវាពីកន្លែងរបស់យើង ហើយបន្ទាប់មកទៀតត្រូវតែការពារ មិនឲ្យពួកវាប៉ះពាល់យើងបាននៅក្នុងអំឡុងឆ្នាំ៧៧ ហើយកម្ទេចបន្ថែមទៀត ដូច្នេះពួកវាមិនអាចងើបក្បាលបាននោះឡើយ"។ សូមបញ្ចប់ការដកស្រង់។

[១៤:១២:២២]

ឃ្លាទី២ ដែលខ្ញុំចង់និយាយផងដែរ គឺខ្មែរមានលេខ 00062991, អង់គ្លេសមានលេខ 0047 8501 និងបារាំងមានលេខ 00499758។ "ចាំបាច់ត្រូវបញ្ចូលមនោគមវិជ្ជា និងបោសសម្អាតមហាជនដើម្បីស្វែងរកខ្មាំង វាយតម្លៃអំពីខ្មាំង វិភាគពីខ្មាំង តាមដានខ្មាំង កៀបសង្កត់ខ្មាំង ចាប់ខ្មាំង ហើយនិងកម្ទេចខ្មាំង ដើម្បីធ្វើឲ្យខ្មាំងធ្លាក់ខ្លួនដូចជាកណ្តុរដែលត្រូវបាន -- ដែលប្រជាជនព័ទ្ធកម្ទេច"។

ហើយនិងឃ្លាចុងក្រោយដែលខ្ញុំចង់អានឲ្យលោកស្តាប់ផងដែរ គឺមាន ខ្មែរមានលេខ 00062 994, អង់គ្លេសមានលេខ 00478502 ដល់ 03 និងបារាំងមានលេខ 00499760។ ខ្ញុំសូមអាននូវការដកស្រង់ "ទីតាំងនីមួយៗត្រូវតែមានតួនាទីដឹកនាំក្នុងការជំរុញបេសកកម្មទៅមុខដើម្បី ចាប់ ពង្រីក និងបង្កើនអំណាចបដិវត្តន៍សង្គមនិយម។ ដូច្នេះហើយដើម្បីឲ្យអំណាចបដិវត្តន៍សង្គមនិយម និងយកជ័យជម្នះលើខ្មាំង ហើយនិងលើជ័យជម្នះលើវណ្ណៈបះបោរមួយចំនួន។ យកជ័យជម្នះទៅលើកម្មសិទ្ធិឯកជន ហើយនិងកម្ទេចឲ្យហ្មត់ដើម្បីការពារមិនឲ្យវាងើបក្បាលមកវិញបាន ទោះបីថាពួកគេនៅទីណា ទោះបីថាពួកគេពួននៅក្នុងទីតាំងណាមួយក៏ដោយ"។ សូមបញ្ចប់ការដកស្រង់។

លោកសាក្សី ថាតើលោកចាំថា បានឃើញទស្សនាវដ្តីបែបនេះត្រូវបានគេលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំដែលលោកធ្លាប់ចូលរួមដែរឬទេ?

**ឆ៖** បាទ ទង់ៗ ទស្សនាវដ្តីទង់បដិវត្តនេះ ខ្ញុំអត់ដែលឃើញសោះតែម្តង។ មិនដែលបានជួបមិនដែលបានឃើញ។

**ស៖** តើលោកចាំទេ ថាតើទស្សនាវដ្តីទង់បដិវត្តធ្លាប់ -- តើលោកធ្លាប់ស្តាប់គេអានទង់បដិវត្តនៅពេលដែលលោកចូលរួមកិច្ចប្រជុំថ្នាក់ស្រុកដែរឬទេ?

**ឆ៖** បាទ អត់ដែរបានទេ អត់ដែលបានស្តាប់ទេ។

**ស៖** តើលោកធ្លាប់បានទទួលទស្សនាវដ្តីទង់បដិវត្ត ឬក៏តើលោកធ្លាប់ទទួលការបង្គាប់ ឬក៏ការបញ្ជាដែលស្របទៅនឹងអ្វីដែលខ្ញុំទើបតែអានជូនលោកស្តាប់អម្បាញ់មិញដែរឬទេ ដែលថាកម្មាភិបាលត្រូវតែស្វែងរកខ្មាំង។ តើលោកធ្លាប់ទទួលការបង្គាប់បញ្ជាបែបនេះដែរឬទេ?

**ឆ៖** បាទ អត់មានដែលទេ។

[១៤:១៥:៥០]

**លោក ឌេល លីសាក់៖**

លោកប្រធាន ឯកសារបន្តដែលខ្ញុំសូមអនុញ្ញាតផ្តល់ជូនសាក្សី គឺឯកសារE3/135 និង E3/289។ គឺឯកសារ E3/135 ជាទស្សនាវដ្តី គឺនៅថ្ងៃ -- នៅខែតុលា -- ខែកក្កដា ឆ្នាំ៧៧ ជាការផ្សព្វផ្សាយវិទ្យុរបស់បក្សកុម្មុយនីស្តកម្ពុជា -- របស់កម្ពុជាប្រជាធិបតេយ្យ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំមានការជំទាស់។ យើងទើបតែកំណត់បានថា សាក្សីក៏មិនដែលឃើញទស្សនាវដ្តីទង់បដិវត្តន៍នោះទេ។ ហើយខ្ញុំដឹងថាលោកប្រធានអនុញ្ញាតឲ្យបង្ហាញឯកសារ ប៉ុន្តែយើងមិនទាន់បានកំណត់ថាតើសាក្សីធ្លាប់ឃើញឯកសារនេះឬក៏អត់? ដូច្នេះ ប្រសិនបើយើងមិនទាន់សួរសាក្សីថាគាត់ធ្លាប់ឃើញឬក៏មិនធ្លាប់ឃើញ។ ដូច្នេះ យើងមិនគួរបង្ហាញទេ នេះជាហេតុផលដែលខ្ញុំជំទាស់។

**លោក ឌេល លីសាក់៖**

លោកប្រធាននេះគឺជាឯកសារពីរផ្សេងគ្នា ដែលត្រូវបានប្រកាស គឺជាទស្សនាវដ្តីទង់បដិវត្ត ដែលផ្តល់កិត្តិយសដល់ស្រុកត្រាំកក់។ ហើយមួយទៀត គឺផ្សព្វផ្សាយតាមវិទ្យុ។ ដូច្នេះ គឺថាខ្ញុំផ្តល់ឯកសារទាំងពីរទៅឲ្យសាក្សីដើម្បីពិនិត្យមើល ថាតើសាក្សីគាត់អាចនឹកឃើញអំពីបញ្ហានេះដែរឬក៏អត់?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី។ ហើយអង្គជំនុំជម្រះអនុញ្ញាតដាក់បង្ហាញឯកសារនេះ ហើយនិងមេធាវី អ៊ំ! សាក្សីពិនិត្យឯកសារ ហើយនិងរង់ចាំឆ្លើយតបទៅនឹងសំណួរដែលសហព្រះរាជអាជ្ញារងអន្តរជាតិនឹងសួរចំពោះលោកពាក់ព័ន្ធនឹងឯកសារនៅចំពោះមុខលោកនាពេលនេះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជាកំណត់ប្រតិចារឹក គឺឯកសារដែលខ្ញុំដក E3/289 ដែលជាការផ្សព្វផ្សាយតាមវិទ្យុ គឺនៅខ្មែរមានលេខ 01064303 ដល់ 307, អង់គ្លេសមានលេខ 00168509 ដល់ 511 និងភាសាបារាំង

មានលេខ 01066907 ដល់ 910។ លោកសាក្សី ហេតុផលដែលខ្ញុំផ្តល់ឯកសារនេះជូនលោក គឺថានៅថ្ងៃ៣០ មិថុនា ៧៧ គឺប្រហែលជា២ខែក្រោយពេលដែលមានការ -- ក្រោយពេលដែលមានហេតុការណ៍នៃការបោសសម្អាតនុ៎ង គឺថាគណៈមជ្ឈិមៗ បក្សកុម្មុយនីស្តកម្ពុជាបានផ្តល់ទង់កិត្តិយសក្រហមទៅស្រុកត្រាំកក់ ដែលចាត់ទុកថាវាជាស្រុកគំរូនៅក្នុងចំណោមស្រុកគំរូទាំងបីក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយពានរង្វាន់នេះត្រូវបានប្រកាសនៅក្នុងទស្សនាវដ្តីទង់បដិវត្ត។ នៅក្នុងទស្សនាវដ្តីដែលខ្ញុំប្រគល់ជូនលោក ហើយវាត្រូវបានផ្សព្វផ្សាយនៅក្នុងវិទ្យុដែលជាឯកសារទី២ ដែលខ្ញុំប្រគល់ជូនលោកផងដែរ។ ដូច្នេះ ខ្ញុំចង់សួរលោក ថាតើលោកធ្លាប់ឮថា ស្រុកត្រាំកក់ត្រូវបានមេដឹកនាំខ្មែរក្រហមទទួលស្គាល់ថាជាស្រុកគំរូនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[១៤:១៩:៣៩]

**ឆ៖** បាទ មិនដែលៗឮថា មិនដែលប្រាប់។

**ស៖** នៅព្រឹកនេះ លោកបានប្រាប់សហការីរបស់ខ្ញុំ ដែលថា បានៗឃើញ ខៀវ សំផន ម្តងនៅក្នុងស្រុកត្រាំកក់។ ដូច្នេះ ខ្ញុំចង់ដឹងថាក្រៅពី ខៀវ សំផន តើលោកធ្លាប់ឃើញមេដឹកនាំខ្មែរក្រហមណាផ្សេងទៀតដែលធ្លាប់មកស្រុកត្រាំកក់ដែរឬទេ?

**ឆ៖** បាទ មិនដែលឃើញទេ។

**ស៖** ចុះ តាម៉ុក វិញ? តើលោកធ្លាប់ឃើញគាត់ប៉ុន្មានដងដែរចន្លោះថ្ងៃ១៧ មេសា ៧៥ ដល់ថ្ងៃ០៦ មករា ៧៩?

**ឆ៖** ឃើញ បី-បួនដងៗ បីទៅបួនដង ខ្ញុំភ្លេច។

**ស៖** តើលោកអាចប្រាប់បានដែរឬទេ--

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងផ្អាកបន្តិចសិន។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ទាក់ទងនឹងសំណួររបស់សហព្រះរាជអាជ្ញាដែលទំនងធ្វើឱ្យមានការយល់ច្រឡំទៅលើសម្តីសាក្សី ដែលសាក្សីបានបញ្ជាក់នៅពេលដែលសួរពីមុនមក គឺគាត់ថាគាត់ឃើញលោក ខៀវ សំផន នៅក្នុងចន្លោះឆ្នាំទស្សវត្សរ៍ពី៥៧-៥៨ ហើយតំណាងសហព្រះរាជអាជ្ញាជាតិបានសួរបញ្ជាក់ទៅលើឆ្នាំហ្នឹងដោយបញ្ជាក់ថាតើវា៦៧-៦៨ដែរឬទេ? បាទក៏ប៉ុន្តែ

អម្បាញ់មិញនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានទាញយកឆ្នាំទាក់ទងនឹង តាម៉ុក ដែលសួរទី១ សួរពី ខៀវ សំផន ដល់ក្រោយមកសួរពី តាម៉ុក ដែលបញ្ជាក់នៅឆ្នាំ១៩៧៥ ដល់១៩៧៩ វិញ។ ដូច្នេះវាធ្វើឱ្យមានការភ័ន្តច្រឡំទៅលើពេលវេលាដែលសាក្សីបានឃើញលោក ខៀវ សំផន។ នេះខ្ញុំសូមធ្វើការកត់សម្គាល់តែប៉ុណ្ណោះ។ សូមអរគុណ។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមឆ្លើយដោយសង្ខេប។ ខ្ញុំមិន-- ខ្ញុំគិតថាមេធាវីការពារក្ដីមានការយល់ច្រឡំទៅលើភស្តុតាងសាក្សីផ្តល់សក្ខីកម្មពីរ។ ទី១គាត់ឮថា ខៀវ សំផន មកជួបប្រជុំជាមួយ តាម៉ុក ប្រហែលជាឆ្នាំ៥៨-៥៩ ឬក៏៦៨-៦៩ ប៉ុន្តែទី២ គាត់ផ្តល់ចម្លើយថានៅពេលដែលគាត់ធ្វើការនៅទំនប់កំពង់ត្របែក គឺថាគាត់ជួប តាម៉ុក ហើយបានឃើញ ខៀវ សំផន។ នេះជាហេតុការណ៍ពីរផ្សេងដាច់ពីគ្នា ហើយយើងមិនមានការភ្ជាប់អ្វីនោះឡើយ យើងគ្រាន់តែសាកសួរសាក្សី ថាតើគាត់ឃើញ តាម៉ុក នៅពេលណាតែប៉ុណ្ណោះ។

[១៤:២២:៥៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក អានេះគ្រាន់តែគេកត់សម្គាល់ទេណ៎ះ! ភាគីខាងនេះអត់មានជំទាស់អីទេ។ អនុញ្ញាតឱ្យសួរណេះ! លោកអត់មានជំទាស់ទេ អំមិញយើងមិនបាច់សម្រេចអីទៀតទេ។

**លោក គង់ សំអុន៖**

ដោយសារតំណាងសហព្រះរាជអាជ្ញាលើកពីអង្គហេតុថ្មីទាក់ទងនឹងថា សាក្សីបានឃើញលោក ខៀវ សំផន នៅកំពង់ត្របែក ប៉ុន្តែខ្ញុំយល់ថាសាក្សីមិនទាន់បានឆ្លើយនៅចំណុចនេះទេ។ ដូច្នេះការលើកនេះវាអាចធ្វើឱ្យមានការភ័ន្តច្រឡំទៀតបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ តាំងសំណួរសារជាថ្មីចំពោះសាក្សីពាក់ព័ន្ធនឹងសំណួរចុងក្រោយអម្បាញ់មិញនេះ។

**លោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សីលោកបាននិយាយថា លោកធ្លាប់ជួប តាម៉ុក ប្រហែលជា -- ឃើញ តាម៉ុក ប្រហែលជាបីបួនដង នៅក្នុងរបបខ្មែរក្រហម តើលោកឃើញ តាម៉ុក នៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំបានឃើញ តាម៉ុក គាត់ជិះឡានដើរតាមៗផ្លូវក្បែរកន្លែងខ្ញុំធ្វើការ ឃើញជិះ ឃើញតែជិះឡានទេ ដែលឈប់នៅកន្លែងខ្ញុំតែម្តងគត់ ឈប់ហើយមិនចូលទៀត។

**ស៖** នៅពេលដែលលោកឃើញហ្នឹង តើលោកមានបានជជែកជាមួយ តាម៉ុក ទេ? គឺថានៅពេលដែល តាម៉ុក គាត់បើកឡានតាមផ្លូវក្បែរពេទ្យហ្នឹង លោកមានបានជួបជជែកជាមួយគាត់ដែរទេ?

**ឆ៖** ខ្ញុំបាទអត់បានជួបទេ គ្រាន់តែឃើញហ្នឹងរត់ពួនបាត់ ខ្លាច។

[១៤:២៥:០០]

**ស៖** ហេតុអ្វីបានជាលោកខ្លាច តាម៉ុក?

**ឆ៖** បាទ មិនដឹងម៉េច ខ្លាចហ្មង។ មិនមែនខ្លាចតែខ្ញុំទេ គេគ្រប់គ្នាខ្លាចច្រើនដែរហ្នឹង។ គ្រាន់តែឃើញរត់ពួនបាត់ហើយ មិនហ៊ានទៅជិត។

**ស៖** នៅពេលដែលយើងនិយាយអំពី តាម៉ុក ខ្ញុំចង់សួរសំណួរពីរបីទាក់ទងទៅនឹងសាច់ញាតិរបស់គាត់ ហើយជាពិសេស ថាតើសាច់ញាតិរបស់គាត់ហ្នឹងមានតួនាទីអ្វីនៅក្នុងរបបខ្មែរក្រហម? នៅព្រឹកនេះលោកបានប្រាប់សហការីរបស់ខ្ញុំ បងរបស់ តាម៉ុក។ បងប្អូនតាម៉ុក ឈ្មោះ ឆាំ។ តើគាត់មានបងប្អូនឈ្មោះ ដុង ដែរឬទេ? តើមានបងប្អូនឈ្មោះ ចំ ដែរឬទេ តាម៉ុក?

**ឆ៖** តាម៉ុក មានប្អូនប្រុសមួយឈ្មោះ ចំ ជាមេឃុំខ្ពបត្របែក។

**ស៖** ប្រហែលជាខ្ញុំអានឈ្មោះមិនច្បាស់មើលទៅ។ ខ្ញុំនិយាយបងប្អូន ប្អូនតាម៉ុកមួយទៀតដែលខ្ញុំជឿថាឈ្មោះ ដុង ឬក៏ ចុង។ តើលោកដឹងថា ចុង ឬក៏ ដុង ហ្នឹងមានតួនាទីអ្វីដែរនៅក្នុងរបបនោះ?

**ឆ៖** បាទ ខ្ញុំបាទដឹង។ គាត់មានប្អូនទៀត។ ប្អូនមួយទៀតឈ្មោះ ចុង។ ចុងហ្នឹងធ្វើលេខាស្រុកនៅស្រុក៥៥ គឺស្រុកព្រៃកប្បាស។

**ស៖** ហើយនៅព្រឹកនេះ លោកបាននិយាយអំពីប្អូនស្រីតាម៉ុក ឈ្មោះ ហឿន ដែលមានតួនាទីនៅមន្ទីរពេទ្យភូមិភាគ ឬក៏តំបន់។ តើប្អូនស្រីគាត់មួយហ្នឹងឬ ជាប្រពន្ធរបស់តាសាន?

**ឆ៖** បាទ យាយ គឿន គឺជាប្រពន្ធរបស់ តាសាន។

**ស៖** ហើយខ្ញុំចង់បញ្ជាក់បន្តិចអំពីបញ្ហាពេទ្យតំបន់។ នៅក្នុងឯកសារកិច្ចសម្ភាសន៍របស់លោក គឺ D313/1.2.409, ខ្មែរមានលេខ 00418835, អង់គ្លេសមានលេខ 00729050, និងបារាំងមានលេខ 00808631 លោកបានបញ្ជាក់ដូចតទៅនេះ ខ្ញុំសុំដកស្រង់៖ "មន្ទីរសុខាភិបាលតំបន់ស្ថិតនៅសាលាគោកចំបក់ និងត្រពាំងរនាម"។ សុំបញ្ចប់ការដកស្រង់។

ខ្ញុំចង់ឲ្យលោកបញ្ជាក់ទៅលើចំណុចពីរ។ តើនៅក្នុងតំបន់មួយមានមន្ទីរពេទ្យតំបន់លើសពីមួយ ឬក៏អត់ ហើយថាតើ យឿន ហ្នឹងធ្វើអ្វីនៅទីនោះ?

**ឆ៖** បាទពេទ្យភូមិភាគ ពេទ្យសម្រាប់ព្យាបាលប្រជាពលរដ្ឋមានមួយនៅសាលាដើមចំបក់ហ្នឹង ហើយពេទ្យយោធាសម្រាប់ព្យាបាលយោធាហ្នឹង មួយនៅ២២ ហើយនិងពេទ្យតំបន់នៅ ពេទ្យខេត្តហ្នឹង នៅត្រពាំងរនាមហ្នឹង សម្រាប់ព្យាបាលប្រជាពលរដ្ឋ។

[១៤:២៩:៣៥]

**ស៖** ហើយពេទ្យយោធាវិញដែលយើងហៅថាពេទ្យ២២ហ្នឹង តើមានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** ពេទ្យ២២ មានទីតាំងនៅក្នុងភូមិពោធិ៍ដុះ ឃុំត្រពាំងធំខាងជើង។

**ស៖** តើពេទ្យហ្នឹងឬ គឺជាពេទ្យដែល គឿន គាត់ធ្វើការនៅ?

**ឆ៖** ពេទ្យដែល យាយគឿន ធ្វើការគឺ ពេទ្យសាលាដើមចំបក់។

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយអំពីកូនស្រី តាម៉ុក។ ខ្ញុំបានពិភាក្សារួចមកហើយអំពីកូនស្រីឈ្មោះ ខុម ដែលលោកបានបញ្ជាក់រួចមកហើយថា ជាប្រធាន -- ជាលេខាស្រុកត្រាំកក់។ ដូច្នេះ ខ្ញុំចង់ដឹងថា តើ តាម៉ុក មានកូនស្រីមួយទៀតឈ្មោះ ហៅ ឬក៏ ហូ ហើយថាតើកូនស្រីគាត់ហ្នឹងមានតួនាទីអ្វីដែរក្នុង របបខ្មែរក្រហម?

**ឆ៖** បាទ ខ្ញុំ កូនស្រីតាម៉ុក ខ្ញុំស្គាល់តែ យាយខុម មួយទេ ក្រៅពីហ្នឹងអត់ អត់ដែលឃើញ អត់ឃើញនៅផ្ទះផង។

**ស៖** អ៊ីចឹងបានន័យថា លោកអត់ចាំថាលោកស្គាល់កូនស្រីគាត់មួយទៀតទេ ហើយអត់ដឹងថា តើកូនស្រីគាត់មួយទៀតហ្នឹងមានតួនាទីអ្វីនៅភូមិភាគនិរតីទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

[១៤:៣១:៤៧]

**ស៖** ឥឡូវនេះ ខ្ញុំចង់លើកឡើងនូវឯកសារមួយដែលលោកបាននិយាយ គឺលោកនិយាយអំពី ដំណើរទស្សនកិច្ចនៅគុកក្រាំងតាចាន់ នៅក្នុងកិច្ចសម្ភាសន៍ E319/1.21 នៃចម្លើយ១២៥ លោកបាន រៀបរាប់អំពីគុកក្រាំងតាចាន់ ហើយលោកបានផ្តល់ចម្លើយដូចតទៅនេះ “អ្នកទោសជាច្រើនស្លាប់ដោយ សារជំងឺគ្រុនចាញ់។ តាជឹម នៅពេលនោះជាគណៈស្រុកបានសរសេរសំបុត្រនៅមន្ទីរពេទ្យរបស់ខ្ញុំ ដើម្បីអាចទៅបាញ់ថ្នាំ ដេ.ដេ.តេ ដើម្បីសម្លាប់មូស។ ពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំបានឃើញអ្នកទោស

ជាច្រើន"។ ហើយបន្តមកបន្តិច គឺចម្លើយ១២៨ដល់ចម្លើយ១៣០៖ "តើលោកបានឃើញអ្នកទោសត្រូវបានគេដាក់ខ្នោះដែរឬទេ? លោកឆ្លើយថា៖ "ខ្ញុំបានឃើញអ្នកទោសសុទ្ធតែដេក មានប្រហែលបីបួនជួរ។ សំណួរ៖ នៅពេលនោះ តើលោកបាននិយាយជាមួយប្រធានគុកក្រាំងតាចាន់ដែរឬទេ? ឆ្លើយ៖ បាទ ខ្ញុំបានទៅនិយាយជាមួយគាត់ ហើយគាត់បានណែនាំកន្លែងឲ្យខ្ញុំបាញ់ថ្នាំ។ សំណួរ៖ តើលោកបានទៅបាញ់ថ្នាំគុកក្រាំងតាចាន់ប៉ុន្មានដង? ឆ្លើយ៖ តែម្តងប៉ុណ្ណោះ"។ លោកបានបញ្ជាក់នៅក្នុងចម្លើយនេះថា មានអ្នកទោសជាច្រើនបានស្លាប់ដោយសារគ្រុនចាញ់។ ដូច្នេះខ្ញុំចង់ដឹងថាតើលោកដឹងដោយរបៀបណា?

[១៤:៣៣:៣៣]

**ឆ៖** បាទ ខ្ញុំបាទដឹងដោយសារ បើមិនអ្នកទោសស្លាប់ដោយសារគ្រុនចាញ់ គឺមិនមានហៅខ្ញុំមកបាញ់ថ្នាំថា មូសខ្លាច្រើនអីច្រើនទេ។

**ស៖** តើលោកចាំដែរឬទេ ថានៅពេលណាដែលទៅបាញ់ថ្នាំនៅក្រាំងតាចាន់ហ្នឹង តើលោកចាំទេថានៅឆ្នាំណា?

**ឆ៖** បាទ ភ្លេច មិនដឹងឆ្នាំប៉ុន្មានដែរ ភ្លេច ខ្ញុំភ្លេច អត់បានគិត។

**ស៖** លោកបានបញ្ជាក់ថា នៅពេលដែលលោកទៅដល់ទីនោះ លោកបាននិយាយជាមួយមេគុកក្រាំងតាចាន់ ដែលផ្តល់នូវការណែនាំ ដែលប្រាប់លោកថាត្រូវបាញ់ថ្នាំនៅកន្លែង។ ដូច្នេះ ខ្ញុំចង់ដឹងថាតើប្រធានគុកមួយណាដែលលោកបានជួបនិយាយនោះ?

**ឆ៖** ប្រធានគុកហ្នឹងឈ្មោះ អាន់ – ឈ្មោះ អាន់ បានណែនាំខ្ញុំឲ្យបាញ់ថ្នាំ។

**ស៖** តើលោកចាំទេថា លោកទៅក្រាំងតាចាន់នៅថ្ងៃនុំងប្រហែលជាប៉ុន្មានម៉ោង ឬក៏ប៉ុន្មាននាទីដែរ នៅពេលដែលលោកទៅបាញ់ថ្នាំនោះ?

**ឆ៖** បាទ ទៅប្រហែលកន្លះម៉ោង បាញ់ថ្នាំអស់មួយធុង១ម្នាក់ ប្រាំធុង។ ប្រហែលកន្លះម៉ោង។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោក គឺ E3/5511 នៅសំណួរទី១៨ លោកបានឆ្លើយដូចតទៅនេះ៖ "នៅពេលដែលបាញ់ថ្នាំសម្លាប់សត្វល្អិត ខ្ញុំឃើញមនុស្សម្នាក់មកពីហាណូយ គាត់ក៏ជាអ្នកទោសដែរ ប៉ុន្តែគាត់នៅក្រៅគុក។ ខ្ញុំបានផ្តាំគាត់ឲ្យជួយមើល ហាន ផង"។ ខ្ញុំនឹងសួរលោកនៅពេលបន្តិចទៀតនេះ អំពីឈ្មោះ ហាន។ ប៉ុន្តែឥឡូវនេះ ខ្ញុំចង់ពិភាក្សាអំពីបុរស -- មនុស្សម្នាក់មកពីហាណូយ។ ដូច្នេះខ្ញុំចង់ដឹងថាតើមនុស្សម្នាក់មកពីហាណូយហ្នឹងជានរណា? ហើយហេតុអ្វីបានជាលោកដឹងថាគាត់មកពីហាណូយ?

[១៤:៣៦:២១]

**ធ៖** បាទ ជាខ្ញុំដឹងថាគាត់មកពីហាណូយ ព្រោះពេលដែលគាត់ -- អង្កាល់ដែលគាត់មកពីហាណូយភ្លាម គាត់ដើរធ្វើការជាមួយមេឃុំ គ្រប់តែឃុំហ្នឹង បន្តិចទៅឃុំនេះ បន្តិចទៅឃុំនោះ ហើយគាត់ទៅហាណូយតាំងពីនៅអាយុ១៣ឆ្នាំ ហើយចាស់ហើយបានមកវិញ។ ស្គាល់គាត់ដោយសារគាត់ដើរតាមភូមិ។

**ស៖** អ៊ីចឹងបានន័យថា គាត់នៅហាណូយ ហើយគាត់ត្រឡប់មកវិញមានតួនាទីនៅស្រុកត្រាំកក់ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ? តើលោកចាទេថា គាត់មានឈ្មោះអ្វី?

**ធ៖** គាត់ឈ្មោះ ជា។

**ស៖** ពាក់ព័ន្ធទៅនឹងការទៅក្រាំងតាចាន់ហ្នឹង តើលោកចាំទេថាមានអ្នកទោសប្រហែលជាប៉ុន្មាននាក់ដែលនៅទីនោះ គឺនៅពេលលោកទៅថ្ងៃហ្នឹងលោកឃើញអ្នកទោសមានចំនួនប្រហែលប៉ុន្មាននាក់ដែរ?

**ធ៖** ខ្ញុំបាទល្ងួចអើតមើលតែមួយអគារ ឃើញដេកបួនជួរ។ បើតាមខ្ញុំវាយតម្លៃ មួយអគារហ្នឹងវែងជាងគេប្រហែលជាជាងមួយរយនាក់ ដេកទាំងអស់។ មើលមួយភ្លែតក៏ដើរចេញទៅ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមចូលទៅប្រធានបទមួយទៀត តើខ្ញុំ -- លោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្តនៅពេលនេះ ឬក៏សម្រាកសិន សឹមខ្ញុំបន្តប្រធានបទថ្មីលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ ដល់ពេលសមល្មមសម្រាកដែរហើយ។ បាទ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នកជំនាញដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០២:០១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំមានប្រធានបទមួយទៀត ដែលខ្ញុំត្រូវសួរលោកសម្រាប់ថ្ងៃនេះ គឺពាក់ព័ន្ធទៅនឹងការចាប់ខ្លួនកម្មាភិបាលមួយចំនួន មកពីត្រាំកក់ ភូមិភាគនិរតី ជាពិសេស គឺការចាប់ខ្លួននារីពេទ្យដែលលោកបានឆ្លើយនោះ។ នៅក្នុងកិច្ចសម្ភាសន៍មួយ ឯកសារ E319.1.21 នៅត្រង់ចម្លើយ១៣២ លោកបានផ្តល់សក្ខីកម្មដូចតទៅ ទាក់ទងទៅនឹងការចាប់នារីពេទ្យឈ្មោះ ហាន ដែលមកពីមន្ទីរពេទ្យរបស់លោក សូមដកស្រង់៖ “មានលិខិតមួយមកពីស្រុកបង្គាប់ឲ្យដេញនារីនោះចោល ហើយគេយកនារីនោះ ចេញពីពេទ្យហើយបញ្ជូនទៅគុកក្រាំងតាចាន់។ ពួកគេបានប្រាប់ខ្ញុំថាស្ត្រីហ្នឹងគឺមានទំនាក់ទំនងជាមួយ តាកង ដែលជាកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ម្នាក់”។ បញ្ចប់ការដកស្រង់។ ហើយនៅសំណួរចម្លើយ១៣៤ សូមដកស្រង់៖ “តាកង ត្រូវបាន ប៉ុល ពត ចាប់ខ្លួន ហើយនារីម្នាក់នោះធ្លាប់នៅជាមួយនឹង តាកង។ ដូច្នេះហើយក៏ត្រូវគេចាប់ខ្លួន ដោយជាប់ខ្សែរបស់តាកង”។ បញ្ចប់ការដកស្រង់។ លោកសាក្សី ថាតើលោកអាចជម្រាបជូនតុលាការថាតើ តាកង នេះជាអ្នកណាដែរ?

**លោក រៀល សន៖**

**ឆ៖** បាទ តាកង ជាប្រធានមន្ទីរពេទ្យ២២។ ហើយកាលនោះនារី ហាន ហ្នឹង នៅជាមួយគាត់។

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ កង គឺជាប្រធានមន្ទីរពេទ្យ២២ ប្រធានភូមិភាគ២២ ហើយហើយ នារីហាន ក៏ធ្លាប់ធ្វើការជាមួយនឹងកងនៅពេលនោះ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើលោកបានជួប ហាន ទេ នៅពេលដែលលោកទៅបាញ់ថ្នាំសម្លាប់សត្វល្អិតនៅឯក្រាំង

តាចាន់នោះ?

[១៥:០៥:០០]

**ឆ៖** បាទខ្ញុំជួប ជួបនារី ហាន នៅកំពុងអង្គុយដាំបាយមួយកូនឆ្នាំង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញជូនឯកសារនូវ -- សាក្សី នូវឯកសារពីរ គឺ E3/4164 និង ឯកសារ E3/4145 ជាបញ្ជីអ្នកទោសមកក្រាំងតាចាន់ដែលខ្ញុំត្រូវតាំងសំណួរសួរទៅសាក្សីរូបនេះ។ សូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំបានជូនឯកសារពីរច្បាប់ទៅលោក ឯកសារទី១ គឺ E3/4164 ហើយទំព័រដែលពាក់ព័ន្ធ ខ្មែរគឺ 00079337 ដល់ 38, អង់គ្លេស 00973147, បារាំង 00937104 ។ នេះជាបញ្ជីដែលមានចំណងជើងថា "ប្រវត្តិរូបសង្ខេបរបស់អ្នកទោសនៅមន្ទីរអប់រំស្រុកត្រាំកក់"។ ហើយខ្ញុំចង់និយាយសំដៅទៅលើមនុស្សលេខរៀងទី២ និងទី៣។ ទី៣ គឺស្ត្រីម្នាក់ដែលមានឈ្មោះ អ៊ុច ហាន ជានារីពេទ្យ អាយុ២៦ឆ្នាំ មកពីត្រពាំងគល់ ដែលបានចាប់ខ្លួននៅ៧ថ្ងៃទី២៣ ឧសភា ១៩៧៧។ ហើយ អ៊ុច ហាន នេះត្រូវបានបញ្ជាក់ថា ជាប់ពាក់ព័ន្ធក្នុងការឆ្លើយតបជាមួយ -- ទាក់ទងជាមួយនឹង ហាន ហើយ និង កង, ហាន។ តើស្ត្រីនេះជា -- អ៊ុច ហាន នេះជាស្ត្រីដែលថាចាប់ខ្លួននៅមន្ទីរពេទ្យរបស់លោក ហើយបញ្ជូនទៅក្រាំងតាចាន់ហ្នឹង ឬក៏មិនមែនទេ?

**លោក វៀល សន៖**

**ឆ៖** បាទនារីហ្នឹងពិតប្រាកដមែន។

**ស៖** ដូច្នេះវាច្បាស់ហើយថា ហាន គឺជាអ្នកទោសម្នាក់ដែលរស់រានមានជីវិតពីគុកក្រាំងតាចាន់ដែលក្រោយមកត្រូវបានគេដោះលែងនោះ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ

**ស៖** លោកចាំទេថា គេលែងនារី ហាន នេះនៅពេលណា លែងចេញពីគុកក្រាំងតាចាន់?

[១៥:០៨:៣០]

**ឆ៖** បាទខ្ញុំអត់ដឹង អត់ដឹងគេលែងពីអង្គាល់។

**ស៖** មានសិទ្ធិ -- នារីពេទ្យមួយទៀត គឺនៅក្នុងបញ្ជីពីរដែលខ្ញុំបានផ្ដល់ជូនលោកនេះ ដែលមានលេខរៀងជាប់នឹង អ៊ុច ហាន ឈ្មោះ វង សារុន – នារីពេទ្យអាយុ២៧ឆ្នាំ មកពីមន្ទីរពេទ្យ២២ ដែលត្រូវបានចាប់ខ្លួននៅថ្ងៃខែឆ្នាំតែមួយ គឺនៅថ្ងៃទី២៣ ឧសភា ១៩៧៧។ ហើយមតិយោបល់ ពាក់ព័ន្ធទៅនឹងស្ត្រីនោះ គឺដូចគ្នា ដោយសារថាអ្នកទាំងពីរហ្នឹង ដែលត្រូវបានគេឆ្លើយជាប់ពាក់ព័ន្ធទៅនឹង ហាង់ ហើយនិង កង។

លោកដែលមានស្គាល់នារីពេទ្យម្នាក់ឈ្មោះ វង សារឿន -- សារុន ហ្នឹងទេ?

**ឆ៖** បាទខ្ញុំអត់ៗដែលស្គាល់ទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារមួយគឺ D157.13។ ជាឯកសារមួយថាជាសៀវភៅកំណត់ហេតុមកពីក្រាំងតាចាន់--

**លោក វិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កូប៉េ!

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំសូមឲ្យឆ្លើយបញ្ជាក់ទាក់ទងទៅនឹងឯកសារមុននេះ។ តើបើខ្ញុំមិនច្រឡំទេ លោកសហព្រះរាជអាជ្ញានិយាយពី វង សារុន ឬក៏ខ្ញុំស្ដាប់ច្រឡំ? ខ្ញុំទៅជាឈ្មោះ វ៉ង់ សារុន ឯណា?

[១៥:១០:៥៧]

**លោក ឌេល លីសាក់៖**

នេះជាបញ្ហាដែលយើងជួបក្នុងការបកប្រែជៀសមិនរួចហើយ យើងមានបញ្ជីគឺឈ្មោះ វង។ យើងមានសៀវភៅកត់ត្រាសួរចម្លើយគាត់ គឺគាត់ឆ្លើយថាគាត់ឈ្មោះ វង សារុន។ ហើយមានការយោងផ្សេងៗគ្នាទៅលើបុគ្គលរូបនេះពីឯកសារគុកក្រាំងតាចាន់។ វ៉ង់ គឺជាការយោងមួយផ្សេងខុសពីនេះ។ ដូច្នេះយើងខ្ញុំនឹងស្នើសុំឲ្យខាងផ្នែកគ្រប់គ្រងតុលាការកែប្រែ ប៉ុន្តែឈ្មោះ វង សារុន នេះឈ្មោះគេនិយាយភាគច្រើននៅទីនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំរីករាយក្នុងការទទួលនូវការពន្យល់បកស្រាយនេះ។ យើងខ្ញុំក៏សូមបញ្ជាក់គ្រាន់តែចង់ផ្ទៀងផ្ទាត់ថាលោកព្រះរាជអាជ្ញាកំពុងតែនិយាយអំពីអ្វី ហើយមួយឈ្មោះ វ៉ង ឬក៏ វង នេះវាខុសគ្នាយ៉ាងម៉េច។ អ៊ីចឹងខ្ញុំនឹងស្ដាប់តាមថាឈ្មោះ វង។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមចំណាយពេល២នាទី ដើម្បីជាប្រតិចារឹកចំពោះបុគ្គលរូបនេះ ដើម្បីឲ្យច្បាស់លាស់។ ទី១ នៅក្នុងឯកសារ E3/4164 គឺដូចខ្ញុំបានជម្រាបជូនហើយត្រូវ គេថាមានអាយុ២៧។ ខ្ញុំមិនដឹងថាខ្ញុំអាន -- គេនោះមកពីភូមិតាជ័យ មកជានារីពេទ្យនៅមន្ទីរពេទ្យ២២ ដោយសារពាក់ព័ន្ធជាមួយនឹងឈ្មោះ ជាប់ពាក់ព័ន្ធជាមួយឈ្មោះ ហង ហើយនិង កង។ ហើយនៅក្នុងឯកសារ E3/4145 ទំព័រទី១ដែរ មានបុគ្គលម្នាក់ទៀតឈ្មោះ អ៊ុច ឆន -- អ៊ុច ហាន ហើយគេថាឈ្មោះ វង សារុន អាយុ២៧ ជានារីពេទ្យ មកពីមន្ទីរ២២ដែរ ដែលជាក់ព័ន្ធជាមួយនឹងឈ្មោះ ហង់ ជាបុគ្គលិកមន្ទីរ២២។

[១៥:១៣:២៨]

ហើយនៅក្នុងឯកសារ D157.13 ជាសៀវភៅមកពីក្រាំងតាចាន់, ERN ជាភាសាខ្មែរ 0027 874, អង់គ្លេស 0086433 ដល់ 34, បារាំង 00872808 ដល់ 09 ដែលមាននៅក្នុងសៀវភៅសួរចម្លើយ -- សួរចម្លើយឈ្មោះ វង សារុន ស្ត្រីអាយុ២៦ឆ្នាំ ដែលធ្វើការនៅមន្ទីរ២២។ មានឯកសារយោងឈ្មោះ រឿន គឺនៅក្នុងឯកសារដែលខ្ញុំនឹងស្នើសុំលោកប្រធានដើម្បីបង្ហាញជូនសាក្សីម្ដងទៀត។ ដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្ដី វាជារឿងធម្មតាទៅហើយ ជាពិសេសពាក់ព័ន្ធទៅនឹងការប្រកបឈ្មោះមនុស្ស នៅពេលយើងបកប្រែពីភាសាមួយទៅភាសាមួយទៀត យើងខ្ញុំនឹងធ្វើតាមការបង្គាប់របស់អង្គជំនុំជម្រះ។ យើងខ្ញុំយល់ឃើញថា យើងមិនអាចសូមឲ្យកែប្រែរាល់មួយឈ្មោះម្ដងៗទេ នេះគឺជាឯកសារ D157.13 ដែលមានឈ្មោះខុសគ្នាបាទ។

*(សម្រាករយៈពេលខ្លី)*

**លោក ឌេល លីសាក់៖**

ខ្ញុំសូមបង្ហាញឯកសារនេះជូនដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៥:១៥:៥២]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ឯកសារដែលខ្ញុំទើបប្រគល់ជូនលោកនេះ គឺជាសៀវភៅកត់ត្រា ដែលមានកំណត់ត្រាសួរចម្លើយកម្មាភិបាលមកពីមន្ទីរពេទ្យ២២ ឈ្មោះ ហ៊ុន ហាន គឺខ្មែរ 00270827 ដល់ 29, អង់គ្លេស 01064174 ដល់ 76, បារាំង 00971285 ដល់ 288។ នេះជាបញ្ជី -- នៅក្នុងបញ្ជីអ្នកទោសដែលខ្ញុំបង្ហាញលោកនេះ ឈ្មោះ អ៊ុច ហាន នេះត្រូវបានគេឆ្លើយជាប់ពាក់ព័ន្ធទៅនឹងមនុស្សពីរនាក់ ឈ្មោះ ហង់ គឺលោកបានបញ្ជាក់ថា ស្គាល់ហើយ។ ហើយក៏មួយទៀតឈ្មោះ ហាន។ ខ្ញុំឱ្យលោកពិនិត្យមើលទំព័រនេះ ដែលពាក់ព័ន្ធទៅនឹង ហ៊ុន ហាន នេះ។ ហើយទី១ ថាតើលោកមានចាំឈ្មោះកម្មាភិបាលម្នាក់ឈ្មោះ ហាន ធ្វើការនៅមន្ទីរពេទ្យ២២ ដែរទេ?

[១៥:១៧:១៦]

**លោក វៀល សន៖**

**ឆ៖** បាទ ខ្ញុំមិនចាំ មិនស្គាល់ អត់ដែលទៅមន្ទីរពេទ្យ២២ ហ្នឹងផង។ ស្គាល់តែ តាកង។ ស្គាល់តែឈ្មោះទៀត អត់ដែលឃើញមុខ។

**ស៖** នៅក្នុងកំណត់ត្រារបស់ ហង់ គឺគេហៅថា "អាចារ្យកង"។ លោកដែលឮឈ្មោះ កង ដែលជាប្រធានមន្ទីរពេទ្យ២២ ដែលគេហៅថា អាចារ្យកង នេះដែរទេ? លោកធ្លាប់ឮទេ?

**ឆ៖** បាទ ខ្ញុំដែលធ្លាប់ឮថា កង ២២ហ្នឹងមានតែ កង ហ្នឹងមួយ ឬក៏ពីរបី ខ្ញុំអត់ដឹងៗ តែ កង ។ ហ្នឹងប្រធានមន្ទីរពេទ្យ២២។

[១៥:១៨:២៨]

**ស៖** លោកមើលទៅកំណត់ត្រាត្រង់ទំព័រដែលខ្ញុំផ្តល់ជូនលោក គឺមានបញ្ជីកម្មាភិបាលមកពី -- ជាបុគ្គលិកពេទ្យចំនួន១៦នាក់ គឺឈ្មោះ ១៦ដែលគេកំណត់ថា ជាពេទ្យដែលធ្វើការនៅមន្ទីរពេទ្យផ្សេងៗ រួមទាំងមន្ទីរពេទ្យត្រពាំងគល់ផង។ ហើយចង់សួរមើលថា តើលោកស្គាល់អ្នកណាខ្លះដែរ ក្នុងចំណោមអ្នកទាំងនេះ?

**ឆ៖** អ្នកណាឈ្មោះអីខ្លះ ខ្ញុំអត់ឃើញ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំកំពុងតែច្រឡំបន្តិចដែរ។ ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាផ្ដល់លេខឯកសារមកឲ្យយើងខ្ញុំម្ដងទៀតបាទ។

**លោក ឌេល លីសាក់៖**

បាទ គឺឯកសារដដែល D157.1.3។ លោកមើល ERN ទំព័រខ្មែរគឺ 00270828 ដល់ 29 លោកឃើញបញ្ជីរាយឈ្មោះមនុស្ស១៦នាក់ ហើយអង់គ្លេសគឺ 106175 ដល់ 76, ហើយបារាំងគឺ 00971285 ដល់ 88 ក៏ជាបញ្ជីរាយឈ្មោះមនុស្សទាំង១៦នាក់នេះដែរ។ សំណួររបស់ខ្ញុំ សូមឲ្យលោកមើលឈ្មោះមនុស្សទាំង១៦នាក់នេះជាកម្មាភិបាលមកពីមន្ទីរពេទ្យនានា ហើយសួរថាតើលោកមានស្គាល់កម្មាភិបាលណាម្នាក់ទេ ក្នុងចំណោមបញ្ជីឈ្មោះនេះ?

**ឆ៖** បាទ បញ្ជីឈ្មោះនេះមើលអត់ឃើញផង មើលអត់ច្បាស់។

**ស៖** បាទ មិនអីទេលោកសាក្សី។ នៅក្នុងចម្លើយរបស់លោកគឺ E3/5511 ត្រង់សំណួរ-ចម្លើយលេខ២១ លោកឆ្លើយអំពី កង។ "ខ្ញុំគិតថា កង គឺជាប្រធានមន្ទីរពេទ្យភូមិភាគ គាត់ត្រូវបានគេចាប់ខ្លួន និងសម្លាប់ដោយពួកខ្មែរក្រហម ហើយនារី ហាន ត្រូវបានចាប់ខ្លួនដោយសារតែគាត់នៅធ្វើការជាមួយឈ្មោះ កង។ លោកចាំទេថាឆ្នាំណាដែរដែលពួកខ្មែរក្រហមបានចាប់ខ្លួនឈ្មោះ កង នេះ?

**ឆ៖** បាទ ខ្ញុំបាទមិនចាំទេ មិនចាំឆ្នាំ មិនចាំថ្ងៃ ចាំខែទេ។

[១៥:២១:៥៥]

**ស៖** ខ្ញុំសូមអានជូនលោក គឺសម្រង់ចេញពីឯកសារ E3/2120។ គឺE3/2120 ជាសៀវភៅសរសេរដោយ អ៊ា ម៉េងទ្រី និយាយពីខ្សែចង្វាក់នៃការបញ្ជា។ ERN ជាអង់គ្លេស 00416443 ដល់ 444 គឺជាកិច្ចសម្ភាសន៍អ្នកបើកបររបស់ តាម៉ុក គឺដែលមានសារនិយាយដូចតទៅនេះ៖ "ថ្ងៃមួយនៅចុងឆ្នាំ១៩៧៦ ក្រោយពីត្រឡប់មកពីភ្នំពេញវិញ តាម៉ុក បានហៅសមាជិកគណៈកម្មាធិការភូមិភាគនិរតីក្នុងនោះមាន អាចារ្យកង។ ក្រោយពីនិយាយគ្នារួចមក តាម៉ុក ក៏បានបញ្ជាឲ្យកងទ័ពរបស់គាត់ចាប់អាចារ្យកងដាក់ខ្នោះដៃ ហើយដាក់ចូលទៅក្នុងឡាន។ អាចារ្យកង ចម្លើយសារភាពរបស់ អាចារ្យកង នៅស-២១ បានបញ្ជាក់ថាគាត់ចាប់ខ្លួននិងបញ្ជូនមកស-២១ ដើម្បីសួរចម្លើយនៅថ្ងៃទី២ តុលា ១៩៧៦"។ បញ្ចប់ការដកស្រង់។ លោកសាក្សី លោកបានបញ្ជាក់នៅក្នុងចម្លើយរបស់លោកជូនសហចៅក្រមស៊ើបអង្កេតនៅពេលមួយដែលថា កង ត្រូវបានចាប់ខ្លួនដោយ ប៉ុល ពត។ ហើយនៅក្នុងសម្រង់ទី២ ខ្ញុំអានជូន

លោកនេះវិញគឺថា៖ “គាត់ត្រូវបានខ្មែរក្រហមចាប់ខ្លួន និងសម្លាប់ចោល”។ សំណួររបស់ខ្ញុំ គឺថាលោកដឹងពីអ្នកណាដែលថា អាចារ្យកង ត្រូវបាន ប៉ុល ពត ចាប់ខ្លួននោះ? លោកឮពីអ្នកណា?

**ឆ៖** បាទ ខ្ញុំបាទឮពីប្រជាពលរដ្ឋនៅក្បែរមន្ទីរពេទ្យ២២ហ្នឹង។ និយាយគេដឹងទាំងអស់គ្នាតើប្រជាពលរដ្ឋនៅជុំវិញមន្ទីរហ្នឹង។

**ស៖** ឯកសារចុងក្រោយ ក៏ហើយក៏ជាសំណួរចុងក្រោយដែរ លោកប្រធានខ្ញុំសូមផ្ដល់ជូនឯកសារនោះ។ ឯកសារE3/1135 គឺE3/1135 ដែលជាឯកសារជាប់ពាក់ព័ន្ធទៅនឹង អាចារ្យកង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**លោក ឌេល លីសាក់៖**

លោកសាក្សីឯកសារដែលខ្ញុំប្រគល់ឱ្យលោកនេះ គឺជារបាយការណ៍ចុះថ្ងៃទី១៩ តុលា ១៩៧៦ មកពី មាស មុត។ ជារបាយការណ៍ពាក់ព័ន្ធទៅនឹងប្រពន្ធរបស់ អាចារ្យកង ដែលបានដេកពេទ្យនៅមន្ទីរពេទ្យកងពល១៦៤ ប៉ុន្តែក៏បានបាត់ខ្លួន ហើយមានមនុស្សមួយចំនួនដែលត្រូវគេ -- វាឆ្លើយពាក់ព័ន្ធទៅនឹងស្ត្រីរូបនេះ មានឈ្មោះ ប៊ិន, មានឈ្មោះ ជាង។ ហើយនៅក្នុងរបាយការណ៍នេះមានកំណត់ត្រាចុះថ្ងៃទី២០ តុលា ផ្ញើជូនបង នួន, និយាយថា៖ “ឥឡូវនេះ អាចារ្យកង បានចេញបាត់ពីមន្ទីរកងពលហើយសុំស្នើឱ្យរកឈ្មោះ ជាង ហើយនិងឈ្មោះ ប៊ិន ដែលជាប់ពាក់ព័ន្ធនេះ”។ សំណួររបស់ខ្ញុំថាតើអ្នកណាជាប្រពន្ធរបស់ អាចារ្យកង?

[១៥:២៦:០៤]

**ឆ៖** ខ្ញុំបាទមិនស្គាល់ទេ មិនស្គាល់ទាំងមុខតាកងហ្នឹងទៀតផង ឮតែឈ្មោះ គ្រាន់តែដឹងថាប្រធានមន្ទីរ២២។

**ស៖** តើលោកដឹងថាមានមន្ទីរពេទ្យមួយទេនៅកំពង់សោម? ហើយថា តើកម្មាភិបាលឬក៏ប្រជាជនពីភូមិភាគនិរតីជួនកាលគេបញ្ជូនទៅមន្ទីរពេទ្យនៅឯកំពង់សោមហ្នឹងដែរទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ គឺទាក់ទងទៅនឹងប្រជាជនពីរនាក់ដែលជាប់ពាក់ព័ន្ធទៅនឹងប្រពន្ធ អាចារ្យកង ដែលខ្ញុំបានកំណត់ឈ្មោះមកហើយ។ នៅក្នុងឯកសារនេះគឺបុរសម្នាក់ឈ្មោះ ឆេង

ហើយនិង ប៊ិន។ តើលោកស្គាល់អ្នកណាម្នាក់ក្នុងចំណោមមនុស្សពីរនាក់នេះ គឺឈ្មោះ ឆេង មួយនិង ឈ្មោះ ប៊ិន មួយ?

**ឆ៖** បាទ មនុស្សទាំងពីរនាក់នេះ ខ្ញុំអត់ស្គាល់ទេ។

**លោក ខេល លីសាក់៖**

សូមអរគុណច្រើនលោកសាក្សីដែលបានជួយឆ្លើយជូនអង្គជំនុំជម្រះ។

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធានខ្ញុំសុំការបញ្ជាក់ឯកសារចុងក្រោយ គឺឯកសារមុនមិនមែនឯកសារ ម៉េងទ្រី ចុងក្រោយទេគឺបញ្ជីឈ្មោះមនុស្ស ១៦នាក់។ យើងខ្ញុំទាំងអស់នៅទីនេះ គឺថាតាមដានឯកសារនេះ អត់ទាន់លោកប្រធាន។ ដូច្នេះ បើសិនណាមិនជាយល់ទាស់ទេ សូមឲ្យសហព្រះរាជអាជ្ញាចង្អុលបង្ហាញទំព័រមួយណាដែរនិយាយឈ្មោះ ១៦នាក់នេះ?

[១៥:២៨:០០]

**លោក ខេល លីសាក់៖**

មើលទំព័រជាអង់គ្លេសគឺ 01064175 និង 01064176 នៃឯកសារ D157.13 មានផ្នែកមួយដែលនិយាយ។ គឺទំព័រទី១ ជាប់មកទំព័របន្ទាប់គឺបញ្ជីឈ្មោះមនុស្ស១៦នាក់ចាប់ផ្តើមជាមួយពាក្យនេះ៖ “អ្នកដែលជាប់ពាក់ព័ន្ធជាមួយសកម្មភាពក្បត់របស់ កង ដែលត្រូវគេបញ្ជូនទៅរៀនវគ្គបច្ចេកទេសមានឈ្មោះដូចខាងក្រោម” ហើយបន្ទាប់ពីពាក្យនេះមក បានរាយឈ្មោះមនុស្សទាំង១៧នាក់នេះ។

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធាន ហេតុផលដែលយើងមិនអាចរកឃើញគឺថា ការបកប្រែគឺថា មិនអាចរកទុកឃើញបាន។ ហ្នឹងពាក់ព័ន្ធទៅនឹងឯកសារថ្មីៗដាក់ចូលទៅក្នុង -- ឯកសារគឺវាអានអត់ដាច់។

**លោក ខេល លីសាក់៖**

យើងដាក់បញ្ជីឯកសារនៅលើអ៊ីនធីហ្វេស។ ខ្ញុំក៏ទើបតែបោះពុម្ពចេញមកពី ហ្សាយឡេប ដែរ ហើយខ្ញុំអាចអានបាន។ ហេតុម៉េចក៏លោករកឯកសារនេះមិនបានមាននៅក្នុងហ្សាយឡេបស្រាប់ហើយ?

**ប្រធានអង្គជំនុំ៖**

បាទ រកមើលមានហើយ ហើយគួរតែមេធាវីជាតិហ្នឹង គួរជួយប្រឹងប្រែងដើម្បីស្វែងរកឯកសារ

យ៉ាងហោចណាស់ក៏បានឯកសារជាភាសាខ្មែរដែរ។ រៀបចំប្រព័ន្ធដើម្បីស្វែងរកឯកសារឲ្យបានទាន់ពេលវេលា។

បាទ ឥឡូវជាបន្តទៀតប្រគល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៥:៣០:២៣]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

បាទ សូមអរគុណ។ សូមគោរពអង្គជំនុំជម្រះទាំងមូល ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**ស៖** នៅពេលនេះ ខ្ញុំសូមជម្រាបសួរលោកសាក្សី។ ចំណុចទី១ ដែលខ្ញុំចង់ជម្រាបសួរទៅលោក គឺការពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈរបស់លោក។ ថាតើការដែលលោកបានទៅរៀននៅវគ្គបណ្ដុះបណ្ដាលទាំងពីរវគ្គហ្នឹង ហើយមានការពាក់ព័ន្ធទៅនឹងការសិក្សាមួយ ហៅថាការសិក្សាកាយវិភាគមនុស្ស។ អ៊ីចឹងសំណួរសួរថា តើការសិក្សានិងកាយវិភាគមនុស្សហ្នឹងតែទៅលើឯកសារ ឬក៏ទៅលើមនុស្សជាក់ស្ដែង?

**លោក វៀល សន៖**

**ឆ៖** ទៅរៀនកាយវិភាគ ទៅរៀនតែលើឯកសារទេ អត់មានទៅរៀនតួមនុស្សទេ អត់។

**ស៖** អ៊ីចឹងថាតើក្នុងវគ្គសិក្សាហ្នឹងមានអ្នកដែលត្រូវទៅសិក្សាហ្នឹងមានមួយវគ្គៗហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** ទៅរៀនមួយវគ្គមានគ្នាពេទ្យឃុំ១២នាក់ ហើយនិងពេទ្យស្រុកពីរនាក់។

**ស៖** បាទ អរគុណ។ ថាតើគ្រូដែលមកបង្វឹកហ្នឹង តើគ្រូហ្នឹងអញ្ជើញមកពីខាងណាដែរ ហើយបើអាចស្គាល់ឈ្មោះអាចជម្រាបបានបាទ?

**ឆ៖** បាទ គ្រូបង្វឹកហ្នឹងឈ្មោះ សី ជាប្រធានពេទ្យតំបន់ហ្នឹងតែម្ដង។

**ស៖** នៅពេលដែលលោកធ្វើការប្រព្រឹត្តិការណ៍នៅក្នុងពេទ្យនេះ ថាមានអ្នកជំងឺដ៏ច្រើនដែលចូលទៅ១ថ្ងៃប្រហែលជាគិតទៅបុរស និងស្ត្រី ប្រហែលចង់១០០នាក់។ តើបុគ្គលិកជំនាញផ្នែកពេទ្យរបស់លោកមានប៉ុន្មាននាក់? ខ្ញុំអត់លើកអំពីថា ព្រឹកមិញបានលើកអំពីបុគ្គលិកទូទៅ៨០នាក់។ ខ្ញុំចង់ដឹងថាតើបុគ្គលិកជំនាញផ្នែកពេទ្យតែម្ដងប៉ុន្មាននាក់?

[១៥:៣៣:៣៧]

**ឆ៖** បាទ បុគ្គលិកផ្នែកពេទ្យដែលជំនាញ ចេះព្យាបាលគួរសម បើខាងបុរសមានពីរនាក់។ អាហ្នឹងក្រោមពីខ្ញុំមានពីរនាក់ ហើយបើផ្នែកនារីមានប្រហែល កាលហ្នឹងខ្ញុំភ្លេចហើយ ប្រហែលជាប្រាំនាក់អីហ្នឹងទេ។ ប៉ុន្តែខ្ញុំនិយាយសំដៅថា១ថ្ងៃមក៣០នាក់ជំងឺ អ្នកជំងឺមក៣០នាក់ហ្នឹង ខ្លះគ្រាន់តែមកព្យាបាលហើយ យើងឲ្យថ្នាំឲ្យអីទៅបាត់ទៅ។ ប៉ុន្តែបើនៅដេកហ្នឹង តែបីបួនប្រាំនាក់ទេ។ កន្លែងនារីក៏អ៊ីចឹងដូចគ្នាដែរ មកសុំថ្នាំ មានថ្នាំអី សុំហើយទៅវិញទៅ ខ្ញុំថា១០០នាក់ជាងណ៎ាកន្លែងនារី ១ថ្ងៃ។ អ៊ីចឹងគ្រាន់តែមកសុំថ្នាំផឹក ថ្នាំលេបអីហ្នឹងទៅវិញទៅ ប៉ុន្តែនៅ មាននៅខ្លះបួន-ដប់-ម្ភៃនាក់អ៊ីចឹងទៅនៅដេក។

**ស៖** ចុះផ្នែកឱសថ ដែលយកមកប្រើប្រាស់ តើឱសថផ្នែកបុរាណ ឬមួយឱសថសម័យ ហើយបានការផ្គត់ផ្គង់ពីខាងណាដែរ?

**ឆ៖** បាទ ខ្ញុំនិយាយពីឱសថបុរាណ។ ឱសថបុរាណ ខ្ញុំមានតាសង្គមកិច្ចខ្ញុំពីរបីបួននាក់អ្នកធ្វើដើររកឫសឈើ ឫសព្រៃឈើ ហើយនិងនារី២បីបួននាក់ធ្វើខ្លួនឯងប្រើខ្លួនឯង។ ឯថ្នាំសម័យ មាននារីខ្ញុំភ្លេចទៅហើយ ប្រហែលប្រាំបីប្រាំបួននាក់ហ្នឹង ខ្លះបិទទឹក ខ្លះលាយថ្នាំ អាខ្លះលាងអំពូល អាខ្លះច្រកថ្នាំហ្នឹង ប្រើប្រាស់ខ្លួនឯង។ លាងសេរ៉ូម លាងអីហ្នឹង។

**ស៖** ចំណុចសំខាន់ ថាតើថ្នាំទាំងអស់នោះ ពេលដែលប្រើទៅមានប្រសិទ្ធភាពកម្រិតណាដែរ?

**ឆ៖** មិនទៀងទេថ្នាំទាំងអស់នោះ ជួនកាលពីថ្នាំដែលផលិតខ្លួនឯង ថ្នាំបុរាណហ្នឹង ជួនកាលអាខ្លះថាថ្នាំបំបាត់រាក ដល់ហូបទៅបាត់ អាខ្លះក៏អត់មានបាត់ដែរ។ ទាល់តែប្រើថ្នាំសម័យអ៊ីចឹងទៅ។ ហើយថ្នាំសម័យដែលធ្វើខ្លួនឯង លាយខ្លួនឯងហ្នឹង គឺមានថ្នាំប៉ុន្មានមុខពីរបីមុខហ្នឹង មានកង់ហ្វូ មានកាល់ស្យូម មានបេខូ មានបេអង អីអ៊ីចឹង។ អាហ្នឹងលាយថ្នាំ យើងទិញមេថ្នាំពីក្រៅមក អាហ្នឹងប្រើទៅយើងធ្លាប់ប្រើភ្លាមៗមានប្រសិទ្ធភាព ដល់យូរទៅមិនសូវមានប្រសិទ្ធភាពទេ។

[១៥:៣៦:៤៨]

**ស៖** បាទ អរគុណ។ ចុះលោកបានចាប់អារម្មណ៍ទេថា នៅពេលនោះមានកូនក្មេងដែលឈឺហ្នឹងចូលទៅមន្ទីរពេទ្យលោកហ្នឹងមានច្រើនដែរអត់ទេ?

**ឆ៖** កាលនោះ មានក្មេងៗច្រើន វាទៅរែកអាចម៍គោ ទៅរែកអ៊ីចឹងទៅ ត្រឡប់មកវិញវាដាក់អម្រែកអាចម៍គោនៅក្រៅពេទ្យ វាចូលទៅសុំថ្នាំឈឺក្បាល ថ្នាំរាកអាចម៍ អីហូបអ៊ីចឹងច្រើន ម៉្ងៃៗបួន

ដប់ម្ភៃនាក់ ព្រោះវាទៅរែកអាចម៍គោក្បែរៗពេទ្យហ្នឹង ចម្ងាយភូមិជិតហ្នឹង ហើយវាដើរមកវិញវាចូលសុំថ្នាំពេទ្យហើយ។

**ស៖** អរគុណ។ ចាតើជំងឺដែលលោកបានជួបប្រទះភាគច្រើនដែលលោកបានលើកឡើង គឺថាមានជំងឺហើម និងជំងឺរាក តើជំងឺពីរមុខនេះ ដែលធ្វើឲ្យអ្នកជំងឺរបស់លោកមកដេកពេទ្យហ្នឹងបាន -- ពេលដែលក្រោយព្យាបាលហ្នឹងបានជាសះស្បើយ ឬមួយត្រូវស្លាប់ដោយសារយើងអត់មានឱសថគ្រប់គ្រាន់?

**ឆ៖** បាទ អ្នកជំងឺហើម រាក ដែលមកសម្រាន្តពេទ្យហ្នឹងមិនមែនជាដោយសារថ្នាំទាំងអស់ទេ ជួនកាលអីអ្នកខ្លះគ្រាន់តែមក យើងឲ្យដូចថា ឈើខ្លាំងមានបុរសប៉ុន្មាននាក់ ស្ត្រីប៉ុន្មាននាក់ យើងធ្វើបាយឲ្យហូបគ្រប់គ្រាន់ទៅបួនដប់ថ្ងៃ បួនប្រាំថ្ងៃជាក៏មាន ខ្លះក៏ឲ្យថ្នាំ ដូចថា រាករូសហ្នឹងឲ្យថ្នាំទៅបាត់។ បើហូបបាយ ហូបអីច្រើនហើយនៅតែមិនឡើងទៀត ឲ្យថ្នាំៗមិនបាត់ទៀត អាហ្នឹងខ្ញុំបញ្ជូន ឬក៏អាចឈានដល់ការស្លាប់។

[១៥:៣៩:០៧]

**ស៖** តើមានការស្លាប់ច្រើនទេ?

**ឆ៖** ដល់ពេលចុងរបបខ្មែរក្រហមហ្នឹង ជិតចប់ នៅខ្វះប្រហែលមួយខែអីទៀតចប់ហ្នឹង ស្លាប់ច្រើនណាស់។ ខ្ញុំមិន រាប់មិនអស់ទេ ពីអ្នកកប់ហ្នឹងគ្នាអត់បាននៅស្ងៀមទេ គឺកាប់រណ្ដៅកប់រហូត ម្ភៃៗ បួនដប់ម្ភៃសាមសិបនាក់អីអ៊ីចឹងទៅ។ ហ្នឹងជិតៗផុតរបបខ្មែរក្រហម។

**ស៖** តើលោកដឹងមូលហេតុច្បាស់លាស់ដែរ ពីបញ្ហាដែលចុងក្រោយហ្នឹងស្លាប់ច្រើនហ្នឹងបាទ?

**ឆ៖** បាទដឹងព្រោះអង្កាល់ពីមុន អង្ករគេឲ្យរបបបានដល់ ២៥កំប៉ុង ៥០កំប៉ុង អ៊ីចឹងទៅ គ្នា ២០០នាក់ជាង ប៉ុន្តែដល់ចុងបញ្ចប់អត់មានអង្ករ អត់មានអ្នកណាឲ្យអង្ករ ឲ្យរបបអង្ករទេ គឺខ្ញុំរកពីនេះពីនោះបានមក ហើយទម្រាំបញ្ចេញអ្នកជំងឺហ្នឹងទៅមូលដ្ឋានវិញអស់ ហៅបងប្អូន អ្នកណាផ្ទះនៅឆ្ងាយពេកឲ្យមានអ្នកជូនទៅអ៊ីចឹងទៅ ដល់ទម្រាំតែអស់ ដល់ថ្ងៃរត់បណ្ដោយ។

**ស៖** ខ្ញុំសូមសួរមួយសំណួរទៀតដែលពាក់ព័ន្ធប្រធានបទនេះ គឺតើលោកនៅពេទ្យហ្នឹង គឺលោកមានដែលបានទទួលស្ត្រីដែលមានផ្ទៃពោះទៅសម្រាលកូនដែរអត់ទេបាទ?

**ឆ៖** បាទបាន បាទ។ បានជាញឹកញាប់ ជួនកាលទៅ ១ខែ ពីរដង បីដង អ៊ីចឹងទៅ។ ជួនកាលនារីខ្លះគេសម្រាលកូននៅតាមមូលដ្ឋាននោះ។ ខ្ញុំមានពេទ្យឆ្មប បីបួនប្រាំនាក់ នារីៗហ្នឹង ឆ្មបជំនាញ

ពីរបីប្អូនប្រាំ ប្រាំមួយនាក់ឯណោះ។ ហើយខ្លួនខ្ញុំបាទហ្នឹង ក៏ជំនាញខាងផ្ទបហ្នឹងដែរ។

**ស៖** ចុះពាក់ព័ន្ធនឹងបច្ចេកទេសសម្រាលហ្នឹង ថាតើមានការស្លាប់ដែរអត់ទេ?

[១៥:៤២:០៨]

**ធ៖** មកៗសម្រាន្តៗនៅពេទ្យមិនដែលមានស្លាប់ទេ បើតាមខ្ញុំគិតមើលទៅគឺអត់ដែលមានស្លាប់ បើមានស្លាប់ៗតែកូន កើតមកហើយកូនស្លាប់ ឬក៏កូនហ្នឹង យើងយកមិនបាន យើងបូម យើងខ្វេងក្បាល វះយកអាហ្នឹង ស្លាប់តែកូនមាន ប៉ុន្តែបើម្តាយគឺអត់ដែលមានទេ។

**ស៖** បាទ អរគុណ។ ចំណុចមួយទៀត ខ្ញុំសូមជម្រាបសួរ គឺពាក់ព័ន្ធលោកបានលើកឡើងអំពីសន្និសីទ ពាក់ព័ន្ធនឹងការកម្ទេចនិងបោសសម្អាត។ ថាតើសន្និសីទនោះមានការកោះហៅទៅចូលរួមប្រជុំហ្នឹង តើថ្នាក់ណាដែលកោះហៅទៅចូលរួមប្រជុំហ្នឹង ហើយការប្រជុំហ្នឹងមានប៉ុន្មាននាក់នៅក្នុងការប្រជុំផ្សព្វផ្សាយអំពីសន្និសីទហ្នឹង?

**ធ៖** បាទ នៅសន្និសីទ ពេលដែលធ្វើសន្និសីទហ្នឹង គឺលេខាស្រុក ចៅហ្វាយស្រុកអ្នកកោះហៅតាមរយៈប្រធានមន្ទីរស្រុក ហើយអ្នកទៅចូលរួមប្រជុំនោះមិនទៀង ស្រេចគណៈស្រុកគេហៅ ដឹងគេហៅមេភូមិ អ៎! មេឃុំគ្រប់ឃុំ មេភូមិ ជួនកាលមេភូមិខ្លះ មេភូមិខ្លះមិនហៅទេ។

**ស៖** ចុះក្រោយពីបានទទួលការផ្សព្វផ្សាយហ្នឹងហើយ តើខាងណាដែលជាអ្នកអនុវត្តនូវការផ្សព្វផ្សាយហ្នឹង?

**ធ៖** តាមពិតទៅគឺមេឃុំ មេភូមិ និងប្រធានកងគ្រប់កងទាំងអស់ដែលអនុវត្តផែនការនេះ។

**ស៖** តើនៅពេលនោះលោកបានជួបប្រទះនូវការអនុវត្តផែនការនេះទៅលើបុគ្គលណាមួយដែលលោកបានដឹងទេបាទ?

[១៥:៤៥:00]

**ធ៖** បាទ ខ្ញុំបាទដឹងដែលធ្លាប់បានផ្ទាល់នោះ តែពូខ្ញុំបាទ ហើយនិងបងថ្លៃដែលគេមកយកនៅផ្ទះខ្ញុំហ្នឹង ប៉ុន្តែខ្ញុំអត់ឃើញផ្ទាល់ភ្នែកទេ ទាល់ប្រពន្ធទៅប្រាប់ហើយ រត់មកមិនទាន់ គេយកទៅបាត់។ ឃើញតែប៉ុណ្ណឹង ហើយបើក្រៅពីហ្នឹង គឺអត់។

**ស៖** នៅចំណុចមួយទៀត ដែលលោកដូចជាបានឆ្លើយតបទៅនឹងសំបុត្រគណៈស្រុកថា បញ្ជូនឈ្មោះលោកស័ក្តិប្អូនណាមួយនោះ ដែលគាត់បានដេកពេទ្យហ្នឹងណ៎ា។ ហើយគាត់ -- គេបញ្ជូនមកលោក លោកបានឆ្លើយទៅគេវិញថាបានបញ្ជូនចេញមុនហើយ។ សួរថាតើថ្ងៃក្រោយទៅ លោកសក្តិប្អូន

ហ្នឹង គាត់មានវាសនាយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំបាទសង្ស័យថា លោកស័ក្តិប្អូននោះប្រហែលជាស្លាប់បាត់ ព្រោះពីយប់អ៊ីចឹង គាត់ដូចថាគាត់ស្រឡាញ់ខ្ញុំ នៅគាត់ដេកពេទ្យនៅបន្ទប់ជិតខ្ញុំហ្នឹង គាត់អង្គុយនិយាយលេងទាល់ជិតមួយយប់។ ហើយគាត់ប្រាប់រឿងសក្តិប្អូនហ្នឹង។ ដល់ហាក់ប្រាប់ស័ក្តិប្អូនហ្នឹង ប្រាប់ដឹងរឿងអ៊ីចឹង ស្រាប់តែដល់ថ្ងៃភ្លឺឡើងឃើញសំបុត្រចៅហ្វាយស្រុកសរសេរមកថា ឲ្យមានអ្នកជំងឺឈ្មោះហ្នឹងនៅឃុំរំចង់ហ្នឹង ឲ្យបញ្ជូនទៅផ្ទះវិញ។ មិន គេមិនបញ្ជាក់ថា ឈឺ -- ជាឬមិនជាទេ ថាឲ្យបញ្ជូនមកផ្ទះវិញ។ ខ្ញុំបាទដឹងថា ច្បាស់ជារឿង។ អ៊ីចឹងខ្ញុំបាទសរសេរសំបុត្រមួយភ្លាមឲ្យនីរសារយកទៅឲ្យចៅហ្វាយស្រុកថា អ្នកជំងឺនេះ ខ្ញុំបាទបញ្ជូនទៅផ្ទះវិញ៣ថ្ងៃទៅហើយ ហើយអ្នកជំងឺ -- ខ្ញុំទៅប្រាប់អ្នកជំងឺហ្នឹងឲ្យជិះរទេះសេះ។ កាលនុ៎ង ខ្ញុំមានរទេះសេះ ទៅដឹកម្ហូប ដឹកជ្រូក ឬក៏ដឹកអីទេភ្លេចហើយ ទៅនៅឃុំរំចង់ហ្នឹង ហើយគាត់នៅឃុំរំចង់ហ្នឹងដែរហ្នឹង។ ហើយរទេះសេះទៅហ្នឹង គាត់ជិះរទេះសេះទៅ ហើយមិនដឹងគាត់ទៅណាទេ បាត់រហូតដល់ឥឡូវមក អត់ឃើញ។ ខ្ញុំថាបើនៅរស់ ខ្ញុំដឹងថា ព្រោះគាត់ដូចជាមនុស្សល្អណាស់ បានជាខ្ញុំស្រឡាញ់គាត់មួយភ្លែត។ អ៊ីចឹងរឿងស័ក្តិប្អូនហ្នឹងអ៊ីចឹង។ អត់ដឹងថាឈ្មោះអីផង។

**ស៖** តាមយោបល់លោក គឺលោកស័ក្តិប្អូនហ្នឹង គាត់បានជិះរទេះសេះចេញ ហើយបាត់រហូតមកដល់ឥឡូវ។ បានន័យថាប្រហែលជាមានការបាត់ខ្លួន ឬមួយយ៉ាងណាហើយ។ អ៊ីចឹង ចូលនៅក្នុងឯកសារ E3/5511 ហើយចម្លើយរបស់លោកពូសាក្សី គឺចម្លើយទី១២ ដែលក្នុងនោះ លើកឡើងអំពីថា "គណៈឃុំមានសមាជិកបីនាក់ គឺប្រធាន អនុប្រធាន និង សមាជិក"។ ហើយរំលងមួយវាក្យខណ្ឌមកគឺចំណុចមួយហ្នឹង គឺថា "សមាជិកគណៈកម្មការ គឺជាប៉ូលិសក្នុងរបបខ្មែរក្រហមដែលទទួលបន្ទុក ក្នុងការចាប់ខ្លួនប្រជាជន"។ ចំណុចនុ៎ង ខ្ញុំបាទជម្រាបសួរថា អ៊ីចឹងមានន័យថានៅក្នុងគណៈកម្មការបីរូបហ្នឹង គឺមានម្នាក់ជាយោធា ឬមួយម្នាក់ជាអ្នកកាន់កាប់ ឬមួយផ្នែកចាប់ចង ឬមួយយ៉ាងម៉េចបាទ?

**ឆ៖** បាទទាំងបីនាក់នេះ គឺ អនុប្រធានជានគរបាល សម្រាប់ចាប់ចង។

[១៥:៥០:១៤]

**ស៖** មុននេះបន្តិចលោកបានបញ្ជាក់ហើយថា លោកបានទៅបាញ់ថ្នាំនៅគុកក្រាំងតាចាន់។ ថាតើពេលដែលទៅហ្នឹងប៉ុន្មាននាក់?

**ឆ៖** បាទ ទៅប្រាំនាក់ទាំងខ្ញុំ។

**ស៖** ហើយតើគុកហ្នឹងចម្ងាយពីមន្ទីរពេទ្យរបស់លោកសាក្សីហ្នឹងប៉ុន្មានគីឡូដែរ?

**ឆ៖** បាទ ប្រហែលជា៦-៧គីឡូ មិនដែលវាស់ទេ ប៉ុន្តែប្រហែល៦-៧គីឡូ។

**ស៖** ថាតើនៅពេលដែលលោកទៅដល់ទីនោះ បាញ់ថ្នាំសម្លាប់សត្វល្អិត ថាតើនៅក្នុងគុកហ្នឹងមានសត្វខ្លះនៅ -- សត្វល្អិតអ្វីខ្លះនៅទីនោះ បានប្រធានគុកហៅទៅបាញ់ហ្នឹង?

**ឆ៖** បាទ ប្រធានគុកគាត់មិនអ្នកហៅទេ គឺថៅហ្វាយស្រុកទេគាត់ហៅ។ មិនមែនឲ្យទៅបាញ់សត្វល្អិតក្នុងហ្នឹងទេ អ៎!បាញ់សត្វល្អិតទេ ប៉ុន្តែគាត់ឲ្យទៅបាញ់ព្រៃខាងៗផ្ទះហ្នឹងកុំឲ្យមានមូសដែកគោលមានគ្រុនឈាម គ្រុនចាញ់អីហ្នឹង។

**ស៖** តើលោក -- ពេលដែលលោកទៅដល់បាញ់ហ្នឹង បានន័យថាដើរបាញ់ហ្នឹងនៅជុំវិញគុកហ្នឹង តើមានបានសង្កេតទេថានៅទីនោះមានអគារប៉ុន្មានខ្នង?

[១៥:៥២:៤១]

**ឆ៖** បាទ ទៅដល់ ខ្ញុំបានសង្កេតឃើញអគារបីខ្នងធំ ហើយពីរខ្នងតូច។ អាធំហ្នឹងធំហើយវែង។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ សួរថាតើលោកសាក្សីនៅពេលដែលទៅដល់គុកហ្នឹងមានដឹងថាព័ត៌មានដែលពាក់ព័ន្ធនឹងគុកហ្នឹង គឺគេបានដាក់អ្នកទោសនៅទីនោះ ហើយគេមានធ្វើទារុណកម្មទៅលើអ្នកទោសហ្នឹងដែរអត់?

**ឆ៖** បាទ ខ្ញុំបាទមិនដឹងថាគេធ្វើទារុណកម្ម ឬមិនធ្វើ គឺអត់ដឹងទេ ព្រោះអត់ឃើញ ខ្ញុំបាទទៅហ្នឹងអត់ឃើញកន្លែងគេធ្វើទារុណកម្មទេ ប៉ុន្តែមានកន្លែងហាមឃាត់ គេអត់ឲ្យទៅបាញ់ទេកន្លែងហ្នឹងមិនបាច់ទៅបាញ់ទេ ផ្ទះមួយនៅពីត្បូងគេបង្អស់នៅប៉ែកខាងត្បូង ដូចថាទួលអ៊ីចឹង វានៅប៉ែកខាងត្បូងមិនបាច់ទៅបាញ់ទេហ្នឹង។ ដឹងកន្លែងអី អត់ដឹង ខ្ញុំបាទអត់ដឹង។

**ស៖** មានឃើញផ្ទះនុ៎ងទេ? ប៉ុនណាដែរ?

**ឆ៖** តូចល្មម។ បាទ តូចល្មមប្រហែលជា៥ម៉ែត្រ ៦ម៉ែត្រ ខ្ញុំមើលពីឆ្ងាយទៅ ប្រហែលដីប្រហែល៣០-៤០ម៉ែត្រ។

[១៥:៥៤:២៩]

**ស៖** តើមានធុំក្លិនអីប្លែកទេ?

**ឆ៖** បាទ ពេលនោះមិនធុំក្លិនទេ ព្រោះខ្ញុំបាញ់ថ្នាំ ថ្នាំនោះវាធុំក្លិន ដេ.ដេ.តេ វាធុំក្លិន អត់មានធុំក្លិនអី ហើយបាញ់ថ្នាំអស់មួយធុងម្នាក់ តែមួយធុងទេ បាញ់ថ្នាំតែមួយធុងទេ ក៏លាគេមកវិញមក។

**លោក ឡោ ជុនធី៖**

បាទ អរគុណលោកប្រធាន ខ្ញុំអស់សំណួរ។ សូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកខ្ញុំសូមអភ័យទោសដែលខ្ញុំត្រូវលើកបញ្ហានេះម្តងទៀត មកឡើងវិញ ព្រោះថា ខ្ញុំគិតថា វាមានបញ្ហាចម្លែកៗកើតឡើងនៅទីនេះ។ អ្វីដែលយើងមានជាឯកសារក្រដាស D157.13 គឺឯកសារនេះបានសរសេរថា៖ "មិនអាចអានបាន"។ ដូច្នេះ គឺអត់មានការបកប្រែនៅទីនេះ។ ដូច្នេះ ខ្ញុំគិតថា -- ដូច្នេះ ឯកសារ D157.13 គឺថាអត់មានការកែតម្រូវអ្វីបន្ថែមនោះទេ។ ដូច្នេះ យើងផ្អែកទៅលើឯកសារមួយនេះគឺ D157.13 ដែលជាឯកសារដែលសរសេរថា "មិនអាចមើលបាន"។ ប្រសិនបើយើងចូលទៅហ្វាយឡេប គឺយើងឃើញថ្ងៃបង្កើត ០៦ ឧសភា ២០១០។ ដូច្នេះហើយគឺមានន័យថា ឯកសារមួយនេះទើបតែត្រូវបានបកប្រែថ្មីៗនៅពេលក្រោយវិញ ដោយមិនមានការជូនដំណឹង។ ដោយសារតែវាមានការលំបាកនៅក្នុងការអានឯកសារដែលជាភាសាខ្មែរ។

[១៥:៥៦:៤៦]

អ្វីដែលខ្ញុំចង់និយាយគឺថា យើងមិនមែនថា យើងមិនបានរៀបចំឲ្យបានប្រុងប្រយ័ត្ននោះទេ ប៉ុន្តែឯកសារគឺវាមានភាពរញ៉េរញ៉ៃ។ ហើយយើងចង់ដឹងថា តើស្ថានភាពវាឈានទៅដល់ថ្នាក់ណាហើយ ព្រោះថាអ្វីដែលយើងឃើញគឺជាឯកសារថ្មីរបស់ D157.13 ដែលគេទើបតែបកប្រែថ្មីៗនេះ។ អ៊ីចឹងបាន យើងចង់ដឹងថា ហេតុអ្វីបានពីមុនគេដាក់ថា មើលមិនដាច់ ប៉ុន្តែឥឡូវបែរជាបកប្រែបាន។ ដូច្នេះ ខ្ញុំចង់ឲ្យមានការបកស្រាយចំពោះឯកសារថ្មី ដែលគេទើបតែបកប្រែបានថ្មីនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំគិតថា បញ្ហានេះគួរតែលើកឡើងជាមួយនឹងអង្គភាពគ្រប់គ្រងតុលាការ ព្រោះថាយើងឃើញថាគាត់ចំណាយពេលវេលាដែលអត់ប្រយោជន៍ជាច្រើន ហើយវាជាឯកសារ ដែលគាត់លើកឡើងជាឯកសារភាសាអង់គ្លេស។ ហើយខ្ញុំគិតថា យើងគួរតែលើកបញ្ហាហ្នឹងជាមួយនឹងផ្នែកគ្រប់គ្រងតុលាការ

សួរថា ហេតុអ្វីមើលដាច់មិនដាច់ ព្រោះថាឯកសារបារាំងក៏មាននៅក្នុងសំណុំរឿងផងដែរ ដែលយើងអាចផ្អែកទៅលើលេខឯកសារនៅពេលដែលឯកសារនេះត្រូវបានដាក់ចូលសំណុំរឿង។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំគិតថាគាត់មាន -- មេធាវីគួរតែលើកបញ្ហានេះជាមួយអ្នកបកប្រែ។ តាមដែលខ្ញុំយល់អ្នកបកប្រែពេលខ្លះគាត់បញ្ជូនឯកសារដែលមិនមែនជាការបកប្រែល្អ ហើយយើងត្រូវបញ្ជូនត្រឡប់ទៅវិញដើម្បីឲ្យបកប្រែឲ្យបានល្អ។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំមិនមែនជាអ្នកដែលអាចឆ្លើយទៅនឹងសំណួររបស់លោកបាននោះទេ។

[១៥:៥៨:៤៧]

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំរកឃើញឯកសារនេះនៅក្នុងហ្សាយឡេប នៅពេលដែលខ្ញុំត្រៀមរៀបចំការសួរសាក្សីនេះ។ ខ្ញុំយល់អំពីអ្វីដែលព្រះរាជអាជ្ញានិយាយ ប៉ុន្តែប្រសិនបើមិនមានការជូនដំណឹងអំពីការបកប្រែជាភាសាអង់គ្លេស។ ដូច្នេះយើងសន្មតថាឯកសារមួយនេះគឺមិនអាចអានបាន។ ប្រហែលជាគេបកប្រែពីភាសាបារាំងត្រឡប់មកវិញ ឬក៏យ៉ាងម៉េចខ្ញុំមិនដឹងនោះទេ។ ខ្ញុំមិនយល់ថាមានអ្វីកើតឡើងចំពោះឯកសារនេះទេ ខ្ញុំចង់ឲ្យមានការបញ្ជាក់បំភ្លឺ។

**លោក ឌេល លីសាក់៖**

ខ្ញុំមានចំណុចមួយទៀតដែលខ្ញុំចង់លើកឡើង។ គឺយើងដាក់ឯកសារនេះនៅក្នុងអ៊ីនធីហ្វេស ប្រសិនបើលោកមើលទៅក្នុងអ៊ីនធីហ្វេស ហើយគ្រាន់តែចុចទៅលើលីង ពេលហ្នឹងគឺថាលោកអាចឃើញ។ ប្រសិនបើលោកគ្រាន់តែចុចទៅលើលីង នៅក្នុងអ៊ីនធីហ្វេស គឺលោកចូលទៅដល់ឯកសារដែលបានបកថ្មីនេះរួចទៅហើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៩:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ ហើយអរគុណនៅការលើកឡើងនូវបញ្ហានេះ។ ហើយអង្គជំនុំជម្រះគិតថា ជាការសមស្រប សូមលោកមេធាវី វ៉ិរទ័រ កូប៉េ ដែលបានលើករឿងនេះជាញឹកញាប់ សូមលោកធ្វើសំណើសុំការបំភ្លឺពីអង្គភាពបកប្រែភាសាដើម្បីបញ្ជាក់អំពីបញ្ហាហេតុផលទាំងឡាយដែលវាមានបញ្ហាដូច្នេះ ដែលប្រឈមនឹងបញ្ហាឯកសារដែលក្រុមមេធាវីការពារក្តីជួបប្រទះម្តងទៀត ដើម្បីឲ្យគាត់ឆ្លើយបញ្ជាក់លើ

បញ្ហានេះជាផ្លូវការតែម្ដង វាច្បាស់លាស់ជាង។

បាទ សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធទី១៨ ខែមីនា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី រៀល សន សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោក រៀល សន ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សី នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនៅពេលនេះលោកអាចវិលត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅបានវិញហើយ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក រៀល សន វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឲ្យអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

ហើយអង្គជំនុំជម្រះសូមអរគុណលោកមេធាវី ឌុច ផារី មេធាវីប្រឹក្សាសាក្សី អង្គជំនុំជម្រះកោះអញ្ជើញលោកមេធាវីមកបន្តចូលរួមប្រឹក្សាសាក្សី រៀល សន ក្នុងអំឡុងពេលសាក្សីរូបនេះផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*